សម្រាប់អ្នកអធិប្បាយកម្ពុជា

# គោលការណ៍និងការអនុវត្តនៃ

# ការអធិប្បាយរបស់ពួករីហ្វម




វាយ យ៉ុង ជុន

មជ្ឈមណ្ឌលសេចក្ដីជំនឿរីហ្វមកម្ពុជា(CRFI)

# គម្រោង

1. ចំណងជើងសៀវភៅ: សម្រាប់ក្រុមជំនុំកម្ពុជា គោលការណ៍និងការអនុវត្តនៃការអធិប្បាយរបស់ពួករីហ្វម
2. គោលបំណង: មានគោលបំណងផ្តល់ផលប្រយោជន៍មួយចំនួនសម្រាប់ក្រុមជំនុំកម្ពុជាអ្នកអធិប្បាយដោយការយល់នូវគោលការណ៍និងវិធីសាស្រ្តនៃការអធិប្បាយរបស់ពួកបរិសុទ្ធ ការអនុវត្តនូវការអធិប្បាយទៅកាន់ក្រុមជំនុំសព្វថ្ងៃដើម្បីនឹងបើកសម្តែងនូវសេចក្តីពិត។
3. វិធីសាស្រ្ត:

1) ការបើកសម្តែងនៃការអនុវត្តសាសនៈវិទ្យាតាមបទគម្ពីរ - បង្ហាញពីគោលការណ៍នៃការអធិប្បាយតាមបទគម្ពីរ។
2) ការបើកសម្តែងសាសនៈវិទ្យាបែបប្រវត្តិសាស្រ្ត– ការយល់ដឹងពីការអភិវឌ្ឍនៃការអធិប្បាយរបស់ពួកបរិសុទ្ធនិងការអធិប្បាយពីការប្រោសលោះ។
3) ការបើកសម្តែងសាសនៈវិទ្យាអនុវត្ត - ការបង្កើតពេលស្ងៀមស្ងាត់នៅពេលដែលបង្កើតការអធិប្បាយ។

4. ការអធិប្បាយដែលសមស្របទៅនឹងស្ថានភាពពិតជាក់ស្តែង – ភាពប្លែកពីគេនៃ (ភាពរណ្តំ អារម្មណ៍ ភាពឆេះឆួល)ភាសាខ្មែរ។
5. ឧទាហរណ៍នៃការអធិប្បាយភាសាខ្មែរនិងការវាយតម្លៃ

# លំដាប់លំដោយ

1. សេចក្តីផ្តើម:
2. ភាពចាំបាច់នៃការអធិប្បាយរបស់ពួករីហ្វមបរិសុទ្ធនៅក្នុងក្រុមជំនុំកម្ពុជា

A. វិបត្តិ៨នៅក្នុងក្រុមជំនុំកម្ពុជា

1) គ្រូគង្វាលដែលត្រូវបានបង្កើតដោយមិនមានការបង្ហាត់បង្រៀន

2) ការលំបាកមួយចំនួនសម្រាប់អ្នកអធិប្បាយកម្ពុជា

3) បេសកកជនកម្ពុជាបានបោះបង់អាទិភាពនៃការទៅដល់ព័ន្ធកិច្ចមួយចំនួន។

4) ក្រុមជំនុំកម្ពុជាដេញតាមសម្ភារៈនិយម។

5) ស្ថានភាពត្រលប់មកវិញនៃអ្នកអធិប្បាយកម្ពុជាត្រូវបានត្រាស់ហៅដោយព្រះអម្ចាស់។

6) ការខ្វះខាតទស្សនៈដែលត្រឹមត្រូវរបស់ពួកជំនុំដែលមានអ្នកព័ន្ធកិច្ចដែលមិនបានទទួលការបង្វឹក។

7) គ្រូគង្វាលកម្ពុជាចង់បានព័ន្ធកិច្ចដែលឯករាជ្យនិងរកចំនូលដោយខ្លួនឯង។

B. វិធីសាស្រ្តសំខាន់នៃវិបត្តិនេះជាការស្តារឡើងវិញនូវការអធិប្បាយតាមបទគម្ពីរ។ វាជាគោលការណ៍នៃការអធិប្បាយរបស់ពួករីហ្វមបរិសុទ្ធនិងវិធីសាស្រ្តរបស់គេ។

3. គោលការណ៍នៃការអធិប្បាយរបស់ពួកវិហ្សមបរិសុទ្ធ – ទ្រឹស្ដីនៃការអធិប្បាយនៅក្នុងចំណុចកណ្ដាលនៃការពន្យល់និងការអនុវត្តដែលផ្ដល់ដោយលោក William Perkins។
4. វាផ្ទុកដោយការពន្យល់និងការអនុវត្ត - គោលការណ៍របស់លោក Lloyd Jones។

   អ្នកអធិប្បាយអាចអនុវត្តសេចក្ដីពិតដែលអ្នកអធិប្បាយយល់។
5. វិធីសាស្ត្រនៅក្នុងការបង្កើតការអធិប្បាយរបស់អ្នកអធិប្បាយកម្ពុជា។
6. 6 ជំហាន

   (1) ភ្ជាប់ការអធិប្បាយរបស់អ្នកទៅនឹងពេលស្ងៀមស្ងាត់ផ្ទាល់ខ្លួន។

   (2) អនុវត្តនូវគោលការណ៍ដែលរកឃើញដើម្បីបង្កើតការអធិប្បាយ។

   (3) ដើរតាមគ្រោងនៃត្រីកោណ (ការសង្កេត ការបកស្រាយ និងការអនុវត្ត) ដើម្បីនឹងប្រតិកម្មទៅលើអត្ថបទព្រះគម្ពីរ។

   (4) រៀបចំសេចក្ដីសរុបរបស់ការអធិប្បាយ *telos*

   (5) បង្កើតគ្រោងបែបអនុមានរួមនៃការអធិប្បាយ។

   (6) បន្ថែមការជជែកវែកញែកដែលសមស្របនិងឧទាហរណ៍ទៅកាន់គ្រោងនៃការអធិប្បាយ។

   (7) ភ្ជាប់សេចក្ដីសរុបរបស់ការអធិប្បាយទៅនឹងការផ្លាស់ប្រែរបស់ក្រុមជំនុំ។

7. ឧទាហរណ៍នៃការអធិប្បាយរបស់គ្រូអធិប្បាយកម្ពុជា។ (ការអធិប្បាយបែបពន្យល់ ការអធិប្បាយជាចំណងជើង ការអធិប្បាយផ្សាយដំណឹងល្អ និងការអធិប្បាយសម្រាប់ការលូតលាស់)

(1) គោលបំណងនៃការអធិប្បាយរបស់គ្រូអធិប្បាយកម្ពុជា – ការលូតលាស់របស់ក្រុមជំនុំ – យើងគួរតែទំនាក់ទំនងទៅកាន់ការអធិប្បាយដើម្បីនឹងបង្កើតក្រុមជំនុំរបស់ព្រះអម្ចាស់។

(2) ការធានាអះអាងរបស់អ្នកអធិប្បាយនៃពួកបរិសុទ្ធនិងជីវិតរបស់ពួកគេ - ទិសដៅជីវិតទាំងប្រាំរបស់កាល់វីន។ ជីវិតរបស់អ្នកអធិប្បាយចេញមកពីការធានាអះអាងរបស់គាត់។ ពួកគេត្រូវការទស្សនៈត្រឹមត្រូវពីបទគម្ពីរ ទិសដៅប្រាំនៃជីវិតបែបបទគម្ពីរ។

(3) គោលបំណងនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ។ - យើងគួរតែផ្តោតលើការប្រកាសសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់។

**សរុបសេចក្តី៖**

គោលបំណងនៃការអធិប្បាយរបស់ពួកបរិសុទ្ធផ្តោតលើការលូតលាស់នៃស្ថានភាពពិត។

# ជំពូក ១

# សេចក្តីផ្តើម

ពេសកកម្មព័ន្ធកិច្ចនៅប្រទេសកម្ពុជារបស់ខ្ញុំមានរយៈពេល១០ឆ្នាំមកហើយ តាំងពីឆ្នាំ ២០០៦ នៅក្នុងនាមជាបេសកកជនផ្នែកការអប់រំ។ ជំងឺស្លាប់មួយចំហៀងខ្លួន ជាព្រឹត្តិការណ៍មួយយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់ខ្ញុំដែលធ្លាប់មាន ជាគ្រាមួយដែលបានគ្រប់បាំងជីវិតរបស់ខ្ញុំដោយស្រមោលនៃសេចក្តីស្លាប់នៅអាយុ៥០ឆ្នាំ នៅក្នុងឆ្នាំ ២០០៤។ កាលនោះខ្ញុំមិនបានដឹងឡើយថា វាជាព្រឹត្តិការណ៍មួយដែលជំរុញខ្ញុំឱ្យមកបម្រើនៅក្នុងក្រុមជំនុំប្រទេសកម្ពុជា ដែលរូបកាលនៃក្រុមជំនុំនៅក្នុងប្រទេសដែលពេញដោយភាពអាថ៌កំបាំង ដែលដែលប៉ូលបានសារភាពថា ខ្ញុំខ្សោយ តែខ្ញុំមានកម្លាំងក្នុងកាលដែលចេញមកពីការដែលគ្មានសេចក្តីសង្ឃឹម។

គោលការណ៍នៃការអនុវត្តការអធិប្បាយរបស់ខ្ញុំ ដែលខ្ញុំបានទទួលនៅព័ន្ធកិច្ចថ្នាក់បណ្ឌិតនៅក្នុងឆ្នាំ ១៩៩៦នៅសាសា Westminster Theological Seminary in California ត្រូវបានចែករំលែកនៅសាលា Reformed Theological Seminary and International Theological College and Seminary in Cambodia ជាព័ន្ធកិច្ចដំបូងនៅក្នុងជំហានដំបូងនៅក្នុងការស្តារជីវិតរបស់ខ្ញុំឡើងវិញ។ ពេលនេះព្រះអម្ចាស់បានផ្តល់នូវសុខភាពយ៉ាងពិសេសដល់ខ្ញុំ ហើយបានធ្វើឱ្យខ្ញុំបានដើរក្នុងជំហានថ្មីអស់រយៈពេល១៥ឆ្នាំ។ "ព្រះយេហូវ៉ាគឺជាព្រះអម្ចាស់ ទ្រង់ជាកម្លាំងខ្ញុំ ទ្រង់នឹងធ្វើឱ្យជើងនៃខ្ញុំបានលឿន ដូចជាជើងឈ្លូស ហើយឱ្យខ្ញុំដើរនៅលើទីខ្ពស់របស់ខ្ញុំ។" (ហាបា

គុក 3:19) សេចក្តីសន្យារបស់ព្រះបានផ្តល់មកហាបាគុកត្រូវបានសម្រេចមកកាន់ខ្ញុំដោយភ្ញាក់ផ្អើល។

ចាប់ពីឆ្នាំ២០០៧មកខ្ញុំបានចាប់ផ្តើមព័ន្ធកិច្ចនៃការបង្រៀននៅ ITCS ដោយមានការហូបចុក ស្នាក់នៅ រៀន និងបង្រៀនផងដែរ ប្រសិនបើស្ថានភាពរបស់ខ្ញុំកាន់តែយ៉ាប់យឺន ខ្ញុំនឹងត្រលប់មកប្រទេសរបស់ខ្ញុំវិញ ជាប្រទេសអាមេរិក បន្ទាប់មកព្រះរបស់ខ្ញុំបានផ្តល់នូវព្រះគុណយ៉ាងអស្ចារ្យមកខ្ញុំហើយធ្វើឱ្យខ្ញុំអាចធ្វើដំណើរទៅកន្លែងផ្សេងទៀតបាន។ សុខភាពរបស់ខ្ញុំបានល្អទៀងអស់រយៈពេល៧ឆ្នាំហើយ រៀងរាល់ចុងសប្តាហ៍ខ្ញុំតែងធ្វើព័ន្ធកិច្ចផ្ទាល់ខ្លួន ខ្ញុំបម្រើបុគ្គលិកចំនួន១៥នាក់ និងមានក្រុមជំនុំសាខាចំនួន៧ និងក្រុមកោសិកាចំនួន២៧នៅក្នុង២៥ខេត្តរបស់កម្ពុជា ហើយខ្ញុំបានព្យាយាមនឹងបង្កើត វិទ្យាស្ថានកំណែទម្រង់កម្ពុជានៅក្នុងរាជធានីភ្នំពេញ ជាមជ្ឈមណ្ឌលនៃព័ន្ធកិច្ច និងសាសាសាខាចំនួនប្រាំនៅក្នុងក្រុងចម្បងនៅក្នុងប្រទេសកម្ពុជា ខេត្តប៉ៃលិន ពោធិ៍សាត់ រតនៈគីរី ស្ទឹងត្រែង ឧត្តរមានជ័យជាដើម។ ជាលទ្ធផលនៃការស្តាប់បង្គាប់ដោយបន្ទាបខ្លួនទៅកាន់ព្រះអម្ចាស់។ ពេលនេះខ្ញុំសង្ឃឹមថានឹងអភិវឌ្ឍព័ន្ធកិច្ចនៅកម្ពុជា ហើយត្រូវតែចែកចាយការអធិប្បាយរបស់ខ្ញុំនិងការអនុវត្តទៅកាន់គ្រូអធិប្បាយនៅកម្ពុជា ដោយជីកចូលទៅក្នុងកំណប់នៅក្នុងចិត្តដែលបិទជិតរបស់ខ្ញុំអំពីគម្រោងអធិប្បាយរបស់ខ្ញុំ ដែលត្រូវបានសម្រេចនៅក្នុងសាលា Westminster Theological Seminary in California សម្រាប់នឹងបោះពុម្ភសៀវភៅអធិប្បាយរបស់ខ្ញុំ។

បើទោះជាខ្ញុំជាគ្រូគង្វាលខាងវិញ្ញាណម្នាក់ដែលត្រូវបានត្រាស់ហៅធ្វើជាអ្នកអធិប្បាយដោយព្រះ បើទោះជាខ្ញុំមិនសារភាពថា "ខ្ញុំគិតថាខ្ញុំនឹងអធិប្បាយព្រះបន្ទូលរបស់ព្រះ

ម្តងទៀតនៅចំពោះពួកជំនុំ″ ដូចជាលោក Richard Baxter ក៏ដោយ ខ្ញុំនៅតែចង់អធិប្បាយព្រះបន្ទូលរបស់ព្រះនៅចំពោះព្រះ ហើយខ្ញុំក៏នឹងឈរចំពោះព្រះនៅក្នុងការអធិប្បាយព្រះបន្ទូលរបស់ទ្រង់។ ខ្ញុំបានបង្រៀនគម្ពីរសញ្ញាចាស់ (សៀវភៅទាំងប្រាំរបស់ម៉ូសេ ប្រវត្តិសាស្ត្រ ហោរាធំ ហោរាតូច និងកំណាព្យផងដែរ) ហើយលិទ្ធិរបស់ពួកបរិសុទ្ធ និងវិទ្យាដែលសិក្សាពីព្រះប្រវត្តិនៃសេចក្តីប្រោសលោះ និងសាសានៈវិទ្យាទាក់ទងនឹងការតាំងសញ្ញា និងសាសនៈវិទ្យាបែបបទគម្ពីរជាដើម ដោយនៅក្នុងការឱ្យតម្លៃរបស់លោកបណ្ឌិត Dr. Ezra Kim ជាដៃគូរការងាររបស់ខ្ញុំ។ ខ្ញុំមានការកោតសរសើរគាត់មែនទែនសម្រាប់ការលើកទឹកចិត្តនៅក្នុងការបម្រើនៅសាលា ITCS។ ប៉ុន្តែដោយសារការដឹកនាំរបស់ព្រះពួកយើងបម្រើនគររបស់ព្រះនៅទីកន្លែងខុសគ្នា ខ្ញុំមានចិត្តដែលកោតខ្លាចនៅក្នុងការបម្រើព្រះពីព្រោះការដែលទ្រង់បានបើកនូវព័ន្ធកិច្ចរីកធំដល់ខ្ញុំ ហើយខ្ញុំក៏មានការអរព្រះគុណដល់ព្រះផងដែរ។ និមិត្តដែលនឹងបង្កើតក្រុមជំនុំពេនីអែលនៅក្នុង២៥ខេត្តនោះបានចេញមកពីចិត្តដែលបន្ទាន់ ក្នុងកាលដែលខ្ញុំបានចូលទៅក្នុងខេត្តព្រះវិហារដើម្បីនឹងទិញគ្រាប់ចន្ទីថោកៗនៅត្បូងឃ្មុំក្នុងពេលបុណ្យចូលឆ្នាំដោយជិះតុកតុក នោះខ្ញុំបានទៅដល់ក្រុងមួយដែលមនុស្សមិនដែលស្គាល់ព្រះគម្ពីរ ឬព្រះយេស៊ូវគ្រីស្ទឡើយ ហើយខ្ញុំមានការបណ្តាលឱ្យមានការធ្វើការផ្សាយដំណឹងល្អដល់កម្ពុជា។ ដែលកិច្ចការនេះគួរតែប្រគល់ដល់បងប្អូនដែលក្មេងៗ និងមានសុខភាពល្អធ្វើ ប៉ុន្តែព្រះអម្ចាស់បានបង្គាប់ការនេះមកដល់ខ្ញុំដោយផ្ទាល់ ‟ឯងអាចធ្វើបាន″។ ហើយខ្ញុំបានស្តាប់បង្គាប់នៅក្នុងចិត្តដែលបន្ទាបខ្លួន។ ក្រុមកោសិកាចំនួន៣៤នៅក្នុង២៥ខេត្តត្រូវបានសាងសង់ឡើងដោយបានត្រួតពិនិត្យខេត្តចំនួន១០នៅក្នុងផ្នែកបន្ទាប់ក្នុងឆ្នាំនេះ។ ខ្ញុំក្រោកឈរនៅចំពោះព្រះ បើទោះជាខ្ញុំមិនមានថវិកា

ស្ថានភាពនិងគ្រប់ការទាំងអស់សុទ្ធតែអាក្រក់ឡើងក៏ដោយ ខ្ញុំនៅតែចង់ស្តាប់បង្គាប់ការបង្គាប់របស់ព្រះដោយសេចក្តីជំនឿ។

នៅពេលដែលបញ្ហាទាំងនេះបានកើតឡើងនៅក្រុមជំនុំកម្ពុជា ខ្ញុំចង់លើកទឹកចិត្តពួកគេ ហើយផ្តល់ចម្លើយមួយចំនួនទៅកាន់បញ្ហានោះ ដោយបង្កើតនូវសៀវភៅនេះជាកត្តាជំរុញ។ ខ្ញុំប្រាកដថាផ្លូវនៃការស្តារឡើងចម្បងចេញពីភាពនៃការបន្ធូរបន្ថយលើការត្រាស់ហៅរបស់ព្រះទៅកាន់ការស្រឡាញ់លុយនិងការពឹងផ្អែកនៅក្នុងការខាងលោកិយ នោះជាការត្រលប់ទៅកាន់ការត្រាស់ហៅនៃបទគម្ពីរនៃអ្នកអធិប្បាយ។ ជាអ្នកអធិប្បាយដែលស្តារឡើងវិញនូវការអធិប្បាយ នោះបញ្ហានោះនឹងត្រូវបានដោះស្រាយពិតប្រាកដ។

នេះជាការបញ្ជាក់ប្រាប់ឱ្យស្វែងរកផ្លូវនៃដំណោះស្រាយមួយចំនួនទៅកាន់បញ្ហាក្នុងព័ន្ធកិច្ចរបស់កម្ពុជានៅក្នុងព័ន្ធកិច្ចនៃការបង្រៀនរបស់គេនិងនៅក្នុងព័ន្ធកិច្ចគ្រូគង្វាលរបស់គេ។ ហើយគេក៏ចង់ទៅតាមផ្លូវនៃការលូតលាស់ដោយដើរតាមការដើរតាមការបង្គាប់ដ៏ធំរបស់ព្រះគ្រីស្ទ (ម៉ាថាយ 28:19-20 យ៉ូហាន 21:15-17 ) ហើយដោយការបើកសម្តែងក្នុងការបង្គាប់របស់ពួកសាវ័ក "ចូរអធិប្បាយព្រះបន្ទូល ចូររួចរាល់ទាំងនៅក្នុងរដូវនិងពេលខុសរដូវផង ចូរកែតម្រូវ ស្តីបន្ទោស និងជម្រុញ ដោយការអត់ធ្មត់និងការបង្រៀន" (២ធីម៉ូថេ 4:2)។

ចម្លើយរបស់អ្នកសរសេរត្រូវបានបង្ហាញដោយទ្រឹស្តីនៃការអធិប្បាយមួយនិងការអនុវត្តសម្រាប់អ្នកអធិប្បាយនៅកម្ពុជាផង ដែលមាននៅសាសនៈវិទ្យារបស់ពួកវីហ្វមបរិសុទ្ធ។ ហើយនៅក្នុងជំពូកពី ខ្ញុំចង្អុលពីស្ថានភាពនៃវិបត្តិនៃការអធិប្បាយនៅក្នុងក្រុម

ជំនុំកម្ពុជា ដែលធ្លាប់មានប្រវត្តិនៃក្រុមជំនុំអស់រយៈពេល១០០ឆ្នាំ ហើយខ្ញុំនឹងឆ្លើយថា វាជាការស្តារឡើងវិញនៃការអធិប្បាយបែបបទគម្ពីរដែលយកឈ្នះលើការនោះ។ ក្នុងកាលដែលការអធិប្បាយត្រូវបានស្តារឡើងតាមបទគម្ពីរ នោះគ្រប់ទាំងការច្របូកច្របល់នឹងត្រូវបានផ្លាស់ប្រែទៅកាន់លំដាប់លំដោយ។ ភាពទទេនឹងត្រូវបានប្តូរទៅជាបរិបូរណ៍ សេចក្តីងងឹតនឹងទៅជាភ្លឺ ដែលជារបៀបបង្កើតផលផ្លែនៅក្នុងសីលធម៌ សេចក្តីសុចរិត និងភាពស្មោះត្រង់តាមបទគម្ពីរ។ និយាយឱ្យខ្លី ខ្ញុំជឿថារូបឆ្លុះរបស់ព្រះនឹងត្រូវបានស្តារឡើងវិញនៅក្នុងប្រទេសកម្ពុជា។

ហើយនៅក្នុងជំពូកបី ខ្ញុំនឹងពន្យល់ពីការពន្យល់បែបបទគម្ពីររបស់ខ្ញុំដោយពឹងផ្អែកលើ "សិល្បៈនៃទំនាយ" ដែលបានសរសេរចុះ ដោយលោក William Perkins ដើម្បីដោះស្រាយជាមួយនឹងគោលការណ៍បែបប្រពៃណីនៃការអធិប្បាយ ដែលពួកគ្រូគង្វាលនៃអ្នកកំណែទម្រង់បរិសុទ្ធចូលចិត្តប្រើនៅក្នុងការអធិប្បាយរបស់ពួកគេនៅគ្រាចុងសតវត្សទី១៦និងដើមសតវត្សទី១៧។ បន្ទាប់មកខ្ញុំនឹងប្រើទ្រឹស្តីរបស់ William Perkins ទៅលើការនោះ ហើយធ្វើការពិនិត្យលើការរកឃើញ ដែល Lloyd-Jones ជាអ្នកដែលបានសង្កេតពីសេចក្តីពិតជាក់ស្តែង ដែលអ្នកមានជំនឿបែបកាល់វីនជាគ្រីស្ទានខាងមេតូឌីសពី ទីក្រុង Wales ជាមួយចំណាងជើងរបស់យើងអំពីការអធិប្បាយ ហើយខ្ញុំនឹងបង្ហាញពីគំរូនៃរូបឆ្លុះផ្ទាល់ខ្លួននៃអ្នកអធិប្បាយតាមបទគម្ពីរ។ បើទោះជាយើងរស់នៅថ្ងៃដើម្បីនឹងពិភាក្សានូវការវិវត្តន៍លើកទីបួននៃសប្បកម្មនិងភាពវៃឆ្លាតច្នៃប្រឌិតក៏ដោយ នៅក្នុងព័ន្ធកិច្ច នោះយើងដេញតាមការបង្រៀនរបស់ព័ន្ធកិច្ចនិងជីវិតនៃការអប់រំកិច្ចការព័ន្ធកិច្ច ព័ន្ធកិច្ចនៃការផ្គត់ផ្គង់ខ្លួនឯង និងព័ន្ធកិច្ចការអធិប្បាយដែលមានជារូបភាពជាដើម។ ជាការដែលសំខាន់ខ្លាំងណាស់នៅក្នុងពេលបច្ចុប្បន្ននេះ ប៉ុន្តែធាតុដែល

សំខាន់នោះគួរតែត្រូវបានផ្លាស់ប្តូរ។ បន្ទាប់មកអ្នកសរសេរនឹងចង្អុលពីធាតុពិតដែលនៅក្នុងចំណោមការផ្លាស់ប្តូរ ពីទំនោរនៃការសាសនៈវិទ្យាចំរុងចំរើន ដែលបានបង្កើតរូបឆ្លុះពិតប្រាកដនៃក្រុមជំនុំមានពពក ហើយខ្ញុំនឹងសង្កត់ធ្ងន់លើការស្តារឡើងវិញនៃការបង្រៀនរបស់ពួកសាវ័កតាមបទគម្ពីរ ជារបៀបនៃការលូតលាស់ ដែលយើងគួរតែដេញតាមនៅក្នុងប្រទេសកម្ពុជា។ វាលធ្វើព័ន្ធកិច្ចដែលមានពេញដោយពុទ្ធសាសនិកប្រហែល ៩៥%នៅក្នុងចំនួនប្រជាជន ប្រហែល១៥លាននាក់ ដែលវប្បធម៌របស់ពួកគេ។ ដូច្នេះវាគួរតែផ្តោតទៅលើការអធិប្បាយតាមបទគម្ពីរដែលសង្កត់លើការលូតលាស់នៃក្រុមជំនុំជារបៀបអធិប្បាយរបស់យើង។

នៅក្នុងជំពូក៤ ខ្ញុំនឹងរៀបចំរបៀបធ្វើការអធិប្បាយតាម៦ជំហានខ្លីៗ។ ខ្ញុំផ្តល់វិធីសាស្រ្តដែលរឹងមាំថែមទៀតដែលយើងអាចប្រើនៅក្នុងព័ន្ធកិច្ចរបស់គ្រូគង្វាល។ ប្រសិនបើអ្នកចង់ដឹងលម្អិតថែមទៀត សូមទំនាក់ទំនងទៅកាន់សៀវភៅពីររបស់ខ្ញុំគឺ ជំហានទាំងដប់សម្រាប់ការអធិប្បាយ (គោលការណ៍និងការអនុវត្តនៃការអធិប្បាយដោយការរែកញែកយ៉ាងជ្រៅ) និងការអធិប្បាយបុរាណ។

បន្ទាប់មកនៅក្នុងជំពូកចុងក្រោយ ជំពូក៥នឹងបង្ហាញថាខ្ញុំសង្កត់ថា អ្នកអធិប្បាយគួរតែផ្តោតលើការលូតលាស់ខាងវិញ្ញាណនិងជីវិតរស់នៅជាក់ស្តែងដែលថ្វាយបង្គំ និងការផ្សាយដំណឹងល្អនៅក្នុងលក្ខខណ្ឌពិសេសដែលក្រុមជំនុំកម្ពុជាមាន ដែលជាការដាស់ស្មារតីដែលពឹងផ្អែកលើហិរញ្ញវត្ថុសម្រាប់ជាសុវត្ថិភាពនៃជីវិតពិតប្រាកដរបស់គេ។ បន្ទាប់មកខ្ញុំនឹងផ្តល់ឧទាហរណ៍នៃការអធិប្បាយមួយចំនួននៃអ្នកអធិប្បាយនៅកម្ពុជា និងបេសកកជនកូរ៉េនៃព័ន្ធកិច្ចរបស់គ្រូគង្វាល។ សៀវភៅផ្សេងទៀតនឹងត្រូវបានបង្កើតឡើងដោយការសម្គាល់ការអធិប្បាយរបស់គេដោយលម្អិត និងធ្វើការវាយ

តម្លៃលើការទាំងនោះដោយទ្រឹស្តីតាមបទគម្ពីរនៅក្នុងពេលអនាគត។ ខ្ញុំអធិស្ឋានថា ព្រះអម្ចាស់នឹងចាក់បង្ហូរវិញ្ញាណនៃការលូតលាស់លើគ្រូអធិប្បាយកម្ពុជាសម្រាប់ការលូតលាស់ដល់ពួកជំនុំ។

27 តុលា 2019

នៅលើតុក្នុងផ្ទះបុគ្គលិក CEMF នៅខេត្តកំពត

White Young Jeon, បេសកកជនផ្នែកការអប់រំនៅកម្ពុជា

# ជំពូកទី ២

## ភាពចាំបាច់នៃការអធិប្បាយនៃការកំណែទម្រង់បរិសុទ្ធ

ហេតុផលដែលអ្នកសរសេរមានអារម្មណ៍ថាភាពចាំបាច់នៃគោលការណ៍នៃការអធិប្បាយបែបកំណែទម្រង់របស់ពួកបរិសុទ្ធ និងការអនុវត្តរបស់វា ដើម្បីនឹងស្វែងរកស្ថានភាពដែលបន្ទាន់ចំនួនប្រាំបីយ៉ាងនៅនៅក្នុងព័ន្ធកិច្ចគ្រូគង្វាលប្រទេសកម្ពុជា។ តើមានអ្វីខ្លះ?

1. វិបត្តិនៃការអធិប្បាយនៅក្រុមជំនុំប្រទេសកម្ពុជា

បើទោះជាប្រទេសកម្ពុជាមានពុទ្ធសាសនិក ៩៥%នៃចំនួនប្រជាជនទាំងអស់ក៏ដោយ ក៏ក្រុមជំនុំនៅតែអធិប្បាយព្រះបន្ទូលរបស់ព្រះតាមរយៈគ្រូគង្វាលដែលបានចាក់ប្រេងតាំងដែរ។ បន្ទាប់មកយើងបារម្មណ៍អំពីការនោះ ដល់អ្នកអធិប្បាយដែលមិនបានរៀនសូត្រ ដែលពួកគាត់មានចិត្តដែលទុកចិត្តលើខ្លួនឯងថាអធិប្បាយព្រះបន្ទូលរបស់ព្រះទៅកាន់ក្រុមជំនុំនៅក្នុងស្ថានភាពដែលគ្រោះថ្នាក់។ បើទោះជាពួកគេមានក្រុមជំនុំតូចមួយក៏ដោយ គ្រូគង្វាលគួរតែគិតពីព្រលឹងវិញ្ញាណរបស់មនុស្សតាមរយៈការអធិប្បាយ។ ប្រសិនបើពួកគេមានអារម្មណ៍ថាវាល្អល្មមហើយពីធាតុពិតនោះ ដែលពួកគាត់បានធ្វើការនោះនៅក្នុងក្រុមជំនុំតូចរបស់គាត់ដោយមិនសមរម្យនៅក្នុងលក្ខខណ្ឌអាក្រក់ណាមួយ នោះវាគ្រោះថ្នាក់ខ្លាំងណាស់នៅចំពោះព្រះ។ ដូច្នេះប្រសិនបើគិតថាការអធិប្បាយមិនត្រូវការការសិក្សាពីព្រះគម្ពីរនោះ វាបញ្ជាក់ថាគាត់មិនបានស្គាល់ពីរបៀបអធិប្បាយតាមបែបព្រះគម្ពីរសំខាន់ប៉ុណ្ណានោះទេ។

ជាទូទៅ នៅក្នុងចំណោមគ្រូអធិប្បាយបែបកំណែទម្រង់ដូចគ្នានោះ មួយចំនួនផ្តោតថាការបង្រៀននិងការអធិប្បាយនៅក្នុងកម្រិតតែមួយដូចគ្នា ជាការពិតយើងមិនអាចបំបែកការបង្រៀនចេញពីការអធិប្បាយបានឡើយ ប៉ុន្តែអ្នកអធិប្បាយរបស់ពួកកំណែទម្រង់ពួកបរិសុទ្ធ ដូចជាលោក Lloyd Jones ធ្វើការសង្កត់ធ្ងន់លើការបែងចែករវាងការអធិប្បាយនិងការបង្រៀននៅក្នុងព័ន្ធកិច្ចនៃការអធិប្បាយ។ ការបង្រៀនសង្កត់ធ្ងន់លើការបញ្ជូនពត៌មានទៅកាន់ពួកជំនុំ។ ជាបឋមនៅក្នុងភាសាក្រិក *didasko* មានន័យថាការប្រាប់ ការទំនាក់ទំនង។ វាសង្កត់លើការប្រាប់នូវពត៌មានមួយចំនួន ដូច្នេះការយល់ដឹងរបស់អ្នកអធិប្បាយនឹងបានផ្តល់ឱ្យដល់ពួកជំនុំ។ ប៉ុន្តែ ការអធិប្បាយសង្កត់លើសកម្មភាពនៃការប្រកាស និងធ្វើឱ្យពួកគេស្តាប់បង្គាប់នូវសារ និងធ្វើឱ្យពួកគេមានបទពិសោធន៍នូវនគររបស់ព្រះអម្ចាស់។ បើទោះជាយើងជួបប្រទះនឹងការមានកំណត់នៃភាសានៃការអធិប្បាយរបស់គ្រូអធិប្បាយក៏ដោយ យ៉ាងណា វាពិបាកណាស់ថា យើងមិនអាចជួបនឹងគំរូនៃការអធិប្បាយល្អនៅក្នុងប្រទេសកម្ពុជាឡើយ ពីព្រោះពួកគេមានដែនកំណត់នៅក្នុងចំណេះដឹងរបស់ពួកគេ អំពីការបន្ទាន់នៃការអធិប្បាយ។ ពួកគេមានកំហុសជាច្រើន ពីព្រោះពួកគេដើរតាមអ្វីដែលពួកគេបានស្តាប់នៅក្នុងស្ថានភាពដែលពួកគេមិនបានរៀនសូត្រ។

វាជាការពិតដែលសកម្មភាពអធិប្បាយរបស់គ្រូអធិប្បាយនៅកម្ពុជានៅក្នុងវាលនៃព័ន្ធកិច្ចនិងផ្នែកគ្រូគង្វាល ត្រូវបានធ្លាក់ចុះនៅក្នុងការច្របូកច្របល់នៅក្នុង សាសនៈវិទ្យា pastralogical ផ្នែកគ្រូគង្វាល និងផ្នែកវិធីសាស្ត្រក្នុងរង្វង់ដែលមិនល្អ។ ឧទាហរណ៍បែបនេះត្រូវបានបង្ហាញនៅក្នុងការបាក់ទឹកចិត្តនៃបេសកជននៅក្នុង

ព័ន្ធកិច្ចនៃការអធិប្បាយ។ បើទោះជាបេសកកជនដែលមានការហ្វឹកហាត់នូវដោយប្រើភាសារបស់ជាតិយ៉ាងល្អក៏ដោយ ក៏ពួកគេសារភាពថាមានកំណត់ដែរនៅក្នុងការបង្ហាញនៅក្នុងពាក្យភាសាខ្មែរនៅក្នុងការអធិប្បាយ។ ហើយក៏ពីប្រសិទ្ធិភាពនៃការយល់រវាងអ្នកបកប្រែភាសាខ្មែរនិងអ្នកបកប្រែកូរ៉េខុសគ្នាខ្លាំងណាស់ ពីព្រោះបើទោះជាគ្រូអធិប្បាយមានចំណេះដឹងខាងសាសនៈវិទ្យាល្អយ៉ាងណាក៏ដោយ ប្រសិនបើអ្នកបកប្រែមានកម្រិតទាបនៅក្នុងចំណេះដឹងខាង

សាសនៈវិទ្យា ហើយក្រុមជំនុំមិនមានចំណេះដឹងពីព្រះគម្ពីរ នោះខ្លឹមសារនឹងត្រូវប្រែទៅជាអ្វីផ្សេងទៀត។ នេះជាសេចក្តីពិតដែលអាចនឹងកើតមានឡើងនៅក្នុងព័ន្ធកិច្ចក្នុងប្រទេសកម្ពុជា។

ឧទាហរណ៍ ជាភស្តុតាង ក្រុមជំនុំកម្ពុជាដើរតាមការបង្រៀនចម្លែក ដែលត្រូវបានបង្កើតឡើងដោយការបង្រួបបង្រួមរវាងទស្សនៈនៃព្រះពរខាងក្រៅនៅក្នុងសាសនាព្រះពុទ្ធនិងព្រះពរខាងលោកិយ ហើយនោះជាសាសនៈវិទ្យាចម្រុងចម្រើន ដែលចេញមកពីសាសនាគ្រីស្ទានមិនតាមបទគម្ពីរ។ ដូច្នេះ ការពិតណាស់ពួកគេបានទទួលនូវបណ្តាញដែលពួកគេដេញតាមនោះ ដែលមានទ្រព្យសម្បត្តិខាងសំភារនិយម និងការស្វែងរកអំណររបស់ខាងសាច់ឈាមទុកជាព្រះពរពិតរបស់ពួកគេ ជាជាងព្រះពីដ៏ខ្ពង់ខ្ពស់នៃគ្រីស្ទានដោយការប្រើប្រាស់គ្រប់មធ្យោបាយនិងរបស់ទាំងអស់។ ដូច្នេះ ពួកគេបានទម្លាក់ចុះទីដែលឥតខ្វោះនៃការអធិប្បាយចេញ នៅក្នុងភាពអាក្រក់ទុក្ខសោកដើម្បីនឹងបំពេញចិត្តលោភរបស់គេ។ ពួកគេបានប្តូរកម្រិតដែលគួរឱ្យគោរពនៃការអធិប្បាយទៅក្នុងកម្រិតរបស់មនុស្សវិញ។

យើងមើលឃើញថា ហេតុដែលបណ្ដាលឱ្យមានរូបភាពដ៏ចម្លែករបស់ក្រុមជំនុំបែបនេះតាមរយៈការស្រាវជ្រាវនៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំរបស់កម្ពុជា។ នៅគ្រាដំបូងបង្អោះនៃក្រុមជំនុំកម្ពុជា ក្រុមជំនុំបាប់ទីស្ទភាគខាងត្បូងរបស់អាមេរិកបានសាងសង់ ព្រះវិហារ 500-1000 នៅកំពង់ស្ពឺ ដោយមិនមានការហ្វឹកហាត់ដល់អ្នកដឹកនាំគ្រីស្ទានអំពីការរកជំនួយពីដោយខ្លួនឯងនោះឡើយ ប៉ុន្តែពួកគេមិនបានយល់ពីការបង្រៀនរបស់ព្រះគម្ពីរឡើយ ដែលក្រុមជំនុំមិនអាចផ្គត់ផ្គង់ព័ន្ធកិច្ចពិតរបស់គ្រូគង្វាលបានឡើយ។ បើទោះជាពួកគេមានព្រះវិហារក៏ដោយ ប៉ុន្តែព័ន្ធកិច្ចនៃការអធិប្បាយធម្មតាអាចធ្វើបានដោយតែគ្រូគង្វាលប៉ុណ្ណោះ។ ហើយពូកគេក៏មានតួនាទីរបស់គ្រូគង្វាល ប៉ុន្តែមិនបានដឹងពីលក្ខណៈដ៏តតខ្វោះនៃការអធិប្បាយឡើយ ពីព្រោះគេមិនមានសុខភាពល្អខាងវិញ្ញាណ។ ក្រុមជំនុំខាងនិកាយបាប់ទីស្ទបានទទួលស្គាល់ពីកំហុសលើព័ន្ធកិច្ចរបស់ពួកគេ ហើយបានបញ្ឈប់ការបង្កើតក្រុមជំនុំរបស់ពួកគេ។

លើសពីនេះទៀតក្រោយមកព្រះវិហារកូរ៉េមួយបានសាងសង់អាគារព្រះវិហារប្រមាណ ៥០០ នៅលើកន្លែងតែមួយដើម្បីកសាងព្រះវិហារកម្ពុជាឡើងវិញនៅសម័យបច្ចុប្បន្ន។ ខ្ញុំគិតថាប្រសិនបើពួកគេលះបង់ខ្លួនឯងដើម្បីបង្រៀនគ្រូគង្វាលឱ្យបានក្លាយជាគ្រូអធិប្បាយ នោះក្រុមជំនុំនៅកម្ពុជាអាចត្រូវបានគេលើកឡើងនូវទិដ្ឋភាពផ្សេងទៀតសម្រាប់ជីវិតគ្រីស្ទបរិស័ទ។ ការបរាជ័យក្នុងការជ្រើសរើសអាទិភាពរបស់ពួកគេ បាននាំមកនូវលទ្ធផលបែបនោះ។

នៅថ្ងៃមួយនោះខ្ញុំបានទៅផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់ក្រុមជំនុំបាទីស្ទនៅឯបាត់ដំបង ខ្ញុំបានឃើញពួកគេថ្វាយតង្វាយពីរដងតាមលំដាប់

លំដោយការថ្វាយបង្គំរបស់ពួកគេ។ ខ្ញុំបានគិតថានៅពេលដែលសេចក្ដីពិតត្រូវបានយកមកអនុវត្តក្នុងវប្បធម៌របស់ពួកគេដោយមិនត្រឹមត្រូវ ពួកគេអាចធ្វើឱ្យជីវិតជាគ្រីស្ទានមានភាពចម្លែកដោយអនុវត្តវាខុសពីព្រះគម្ពីរ។

ដូច្នេះទោះបីយើងនិយាយល្អពីការលះបង់របស់អង្គការមិនមែនរដ្ឋាភិបាលសម្រាប់សកម្មភាពត្រឹមត្រូវទៅ នឹងស្ថានភាពបណ្ដោះអាសន្នក៏ដោយ ប្រសិនបើយើងនៅទីនោះហើយមិនមានការរីកចម្រើននៅក្នុងកិច្ចការរបស់គ្រូគង្វាលវាពិតជារឿងធ្ងន់ធ្ងរណាស់។ ដូច្នេះយើងគួរតែលើកយករូបភាពផ្ទាល់ខ្លួនរបស់គ្រូអធិប្បាយពិត ដែលគួរតែព្យួរជីវិតរបស់គេក្នុងការអធិប្បាយ ដោយទទួលស្គាល់ការពិតដ៏អស្ចារ្យ ដែលពួកគេបានបោះបង់តួនាទីសំខាន់បំផុតរបស់ គ្រូគង្វាលដោយការមើលងាយការចង្អុលបង្ហាញរបស់ព្រះគម្ពីរ។ បញ្ហាសំខាន់បំផុតនៃការអធិប្បាយគឺពឹងផ្អែកទៅលើអ្វីដែលគ្រូគង្វាលបានទទួលសារដែលចេញពីស្ថានសួគ៌ឬអត់។

2. ស្ថានភាពរបស់គ្រូគង្វាលដោយមិនមានការហ្វឹកហាត់នៃគ្រូអធិប្បាយនៅក្រុមជំនុំកម្ពុជា

បច្ចុប្បន្នវាពិបាកណាស់សម្រាប់យើងក្នុងការរកឃើញបេក្ខជនគ្រូគង្វាលមួយចំនួននៅក្នុងក្រុមជំនុំកម្ពុជា។ ហើយយើងក៏បានរកឃើញសភាពដ៏ពេញនិយមមួយដែលប្រជាជន ដែលមានការអធិប្បាយព្រះបន្ទូលរបស់ព្រះដោយមិនទទួលបានការតែងតាំងនៅក្នុងក្រុមជំនុំកម្ពុជា។

ក្នុងការបម្រើដើម្បីបង្រៀនមុខវិជ្ជាខាងទ្រឹស្ដីសាសនៈវិទ្យាខាងបទព្រះគម្ពីរដល់សិស្សរបស់ខ្ញុំអស់រយៈពេល ១៣ ឆ្នាំហើយទោះបីជាខ្ញុំបានសួរទៅកាន់ការត្រាស់ហៅទៅកាន់ពួកគេ ខ្ញុំបានលឺចម្លើយវិជ្ជមានរបស់ពួកគេ ប៉ុន្តែនៅពេលពួកគេបានជួបពេលវេលាត្រឹមត្រូវនៃការតែងតាំង ពួកគេបានពន្យារពេល។ សម្របខ្លួនទៅនឹងស្ថានភាពបច្ចុប្បន្នរបស់គេ ដោយមិនបង្ហាញចំណាប់អារម្មណ៍ដ៏រុងរឿងរបស់ពួកគេ។ ដូចដែលខ្ញុំសង្កេតមើលពួកគេ ទោះបីមាននរណាម្នាក់មានកម្រិតគ្រប់គ្រាន់ គាត់ចូលចិត្តពន្យារពេលដោយមិនស្ទាក់ស្ទើរចំពោះបញ្ហាជាច្រើន។ បញ្ហាចំបងគឺរដ្ឋហិរញ្ញវត្ថុដែលពួកគេអាចបង្កើតសម្រាប់ខ្លួនគាត់និងគ្រួសាររបស់គាត់ជាដើម។ បន្ទាប់មកកិច្ចការនៃគ្រូគង្វាលដែលគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់បំពេញតំរូវការនៃបេសកកម្មតាមរយៈថ្នាក់សិក្សាខ្លីបានធ្វើឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនៃការផ្សព្វផ្សាយ។

ពួកគេបានបំបែកស្តង់ដារនៃកន្លែងសំរាប់ការថ្វាយបង្គំសាធារណៈរបស់ គោលលិទ្ធិនៃសេចក្ដីជំនឿ ដែលជាគ្រូគង្វាលគឺជាមនុស្សដែលមានពរដ៏អស្ចារ្យ ប៉ុន្តែពួកគេបានធ្វើឱ្យការអធិប្បាយមានលក្ខណៈសាមញ្ញ ឬត្រូវបានមើលងាយ។ សេចក្ដីពិតទាំងស្រុងដែលក្រុមជំនុំគួរតែត្រូវបានរីកលូតលាស់ដោយការអធិប្បាយដែលមានទំនាក់ទំនងគ្នាផងដែរ ហើយទិសដៅនៃការការអធិប្បាយរបស់ពួកសាវកបានបាត់បង់យ៉ាងខ្លាំង។

3. ការលំបាកមួយចំនួនទៅកាន់គ្រូអធិប្បាយនៅក្នុងក្រុមជំនុំកម្ពុជា

ក្រុមជំនុំកម្ពុជាដែលត្រូវបានទទួលយកកាលពី ១០០ឆ្នាំមុន ពេលនេះពិតជាខ្សោយខ្លាំងណាស់ខាងបរិស្ថានខាងវិញ្ញាណនៅក្នុងការបង្កើតនូវអ្នកអធិប្បាយដែលឥតខ្ចោះ ដែលជាគ្រូគង្វាលដែលស្មោះត្រង់ និងជាអ្នកវិទូខាងសាសនៈវិទ្យាដូចជាប្រទេសកូរ៉េ។ ខ្ញុំមិនដែលបានលឺពីអ្នកអធិប្បាយណាឡើយ ហើយមិនដែលនឹងមាននរណាដែលត្រូវបានលើកឡើងនៅលំនាំនៃការដោះស្រាយខាងសាសនៈវិទ្យាអ្វីឡើយរហូតមកដល់ពេលនេះ។ ខ្ញុំមិនដែលឃើញអ្នកដឹកនាំខាងវិញ្ញាណ ដូចជាគ្រូគង្វាល ចាស់ទុំ អ្នកអធិប្បាយ និងអ្នកបម្រើខាងការលូតលាស់អ្វីឡើយ បើទោះជាមានកម្មវិធីភាពជាអ្នកដឹកនាំគ្រូគង្វាលពីរដងនៅក្នុងមួយឆ្នាំក៏នៅ ITCS ដែលជាសាលាដែលខ្ញុំបានបម្រើអស់រយៈច្រើនជាង១០ឆ្នាំដោយខំប្រឹងប្រែង ដែលប្រហែលជាមានសិស្សជាមធ្យម១០០នាក់មកជួបជុំគ្នា ហើយមានគណៈកម្មាធិកាប្រេសប៊ីធារៀនត្រូវបានបង្កើតឡើងកាលពីប៉ុន្មានឆ្នាំមុន ខ្ញុំមិនដែលឃើញមានគ្រូអធិប្បាយណាមួយដូច្នោះសោះ។

ថ្ងៃមួយខ្ញុំបានសួរសំណួរទៅកាន់បេសកកជនម្នាក់ពីការនោះ គាត់បានឆ្លើយមកខ្ញុំថាដោយសារ បេសកកជនមុនបានផ្គត់ផ្គង់សម្ភារៈច្រើនទៅកាន់ក្រុមជំនុំកម្ពុជាដើម្បីនឹងសម្រេចគោលបំណងរបស់ពួកគេនៅក្នុងព័ន្ធកិច្ច។ ប៉ុន្តែខ្ញុំគិតថានោះជាចម្លើយដែលអវិជ្ជមានមួយ។ តើអ្វីទៅជាហេតុផលចម្បង? ខ្ញុំគិតថាដោយសារពួកគេបានបាត់បង់ការអធិប្បាយព្រះបន្ទូលទៅតាមបទគម្ពីរនៅក្នុងព័ន្ធកិច្ចរបស់ពួកគេ។ ពួកគេបានជំនួសការអធិប្បាយដោយសារកាដូរ ការសរសើរដំកើង ការធ្វើអំណោយជាដើម។ ហើយពួកគេបានធ្វើឱ្យគ្រីស្ទានកម្ពុជាត្រឡប់ការសម្លឹងមើលរបស់ពួកគេទៅកាន់ការផ្សេងដែលមិនមែនជាការស្ដាប់ទៅកាន់ព្រះបន្ទូលរបស់

ព្រះ។ អ្នកអធិប្បាយធំៗនៅក្នុងព័ន្ធកិច្ចគ្រូគង្វាលពួកបរិសុទ្ធ និងអ្នកអធិប្បាយកូរ៉េល្អៗបានលះបង់ខ្លួនរបស់ពួកគេដើម្បីនឹងយល់ព្រះបន្ទូលរបស់ព្រះ ដែលជាជីវិតបែបជាយញ្ញបូជាជាការអធិស្ឋាន ការប្រកាសការអធិប្បាយរបស់ពួកគេដោយប្រឹងប្រែង ប៉ុន្តែសម្រាប់ក្រុមជំនុំកម្ពុជាក៏ដេញតាមដែរ តែបែរទៅរកភាពមនោសញ្ចេតនាជ្រុល ហើយការអធិប្បាយបានត្រឡប់ទៅជាខ្សោយ។ លោក Baxter ដែលជាអ្នកអធិប្បាយម្នាក់នៅក្នុងពួកបរិសុទ្ធបានគិតថា មុនដែលគាត់ឡើងទៅកាន់ទីអធិប្បាយ គិតថាគិតនឹងមានបានអធិប្បាយទៅដល់ក្រុមជំនុំរបស់គាត់ម្តងទៀតនោះឡើយ។ ហើយក្រុមជំនុំក៏មានអារម្មណ៍ថាដូចជាបន្ទាន់ដែលគាត់បានអធិប្បាយព្រះបន្ទូលរបស់ព្រះនៅទីកន្លែងមួយក្បែរភ្លើងនៃស្ថាននរក។ តើមានគ្រូអធិប្បាយណាដូចជាគាត់នៅប្រទេសកម្ពុជាដែរឬទេ?

ក្រុមជំនុំថ្មីៗនេះ សិក្ខាសាលា និងសាលាគម្ពីរ ហាក់បីដូចជាបាត់បង់ការសំខាន់ៗមួយចំនួនដោយងាយ ដោយសារការអភិវឌ្ឍខាងសេដ្ឋកិច្ច។ ដូចជាសិស្សដែលចូលរៀនរួចមក ហើយបានត្រឡប់ទៅផ្ទះរបស់ពួកគេវិញនៅក្នុងពេលវ៉ាកង ហើយពួកគេបានបោះបង់ការសិក្សាជាប់លាប់របស់ពួកគេ ដោយសារបញ្ហាលុយកាក់ដោយសារឪពុកម្តាយ ឬគេខ្លួនឯងផ្ទាល់មានបន្ទុកទទួលខុសត្រូវខាងសេដ្ឋកិច្ច ហើយបានបោះបង់ចោលការសិក្សា ដើម្បីនឹងរកចំណូល។ ខ្ញុំពិតជាមានការលំបាក់នៅក្នុងការដោះស្រាយនូវបញ្ហានេះណាស់។

ហើយវាក៏ពិបាកនៅក្នុងការស្វែងរកបេក្ខជនធ្វើជាគ្រូគង្វាល និងជាពិសេសបុគ្គលក្មេងៗនៅកម្ពុជាមិនចូលចិត្តធ្វើជាគ្រូគង្វាលប៉ុន្មានណាស់នោះទេ។ នៅថ្ងៃមួយខ្ញុំបានទៅលេងវិទ្យាស្ថានបាត់ដំបង និងបេសកកជនកូរ៉េ ខ្ញុំទៅលេងពួកគេហើយ

បានសួរទៅកាន់ពួកគេពីស្ថានភាពរបស់សិស្ស ពួកគេមានភាពអវិជ្ជមាន ពីព្រោះពួកគេបានបោះបង់ការសិក្សារបស់ពួកគេដើម្បីនឹងរកប្រាក់ដើម្បីគ្រួសាររបស់ពួកគេ។ ដូច្នេះបេសកកជនព្យាយាមជួយដោះស្រាយបញ្ហាថវិការរបស់ពួកគេដោយការធ្វើកសិកម្ម ចិញ្ចឹមត្រីនៅក្នុងអាងរបស់សាលារៀន។ បើទោះជាអាគារដ៏ធំត្រូវបានសាងសង់ឡើងនៅលើផែនដីនៅលើដីក៏ដោយ តែបើមិនមានសិស្ស តើមានន័យអ្វីទៅ?

ហើយមានសិស្សមួយចំនួនចង់ក្លាយជាគ្រូគង្វាលបន្ទាប់គេមានមុខរបរបន្ទាប់ពីបញ្ចប់ការសិក្សាជំនាញនៅសាលារួច។ វាបញ្ជាក់ថាចិត្តដែលដេញតាមការត្រាស់ហៅជាគ្រូអធិប្បាយត្រូវបានរលាយបាត់បង់។ តើអ្វីទៅជាបញ្ហាចម្បងទៅលើការនេះ? ដូចដែលយើងបានប្រៀបធៀបការលំបាក់ខាងថវិការនៅក្នុងថ្ងៃរបស់ពួកបរិសុទ្ធនៅប្រទេសអង់គ្លេស ដែលពួកគេបានលូតលាស់នៅក្នុងគ្រាដែលមានបញ្ហា និងទទួលឥទ្ធិពលមកដល់ពេលបច្ចុប្បន្នក្នុងនាមពូកគេជាដូជាយក្សខាងព្រលឹងវិញ្ញាណ ប៉ុន្តែក្រុមជំនុំកម្ពុជានៅតែរវល់ធ្វើការសុំទានរបស់របរពីជនបរទេស ហើយលូតលាស់ឡើងនៅក្នុងសភាពដូចជាកូនក្មេង ហើយត្រូវបានធ្លាក់ចុះនៅក្នុងគំនរសម្រាមនៃការដេញតាមលុយ។

លើសពីនោះទៀត ដោយសារគ្រូគង្វាលបម្រើក្រុមជំនុំនៅក្នុងការថែរក្សាមុខរបរធ្វើកសិកម្មផ្ទាល់ខ្លួនផង និងការលក់ដូរផងដើម្បីនឹងមើលថែរគ្រួសាររបស់គាត់ នោះវាពិតជាលំបាកនៅក្នុងការផ្តោតទៅលើការអធិប្បាយព្រះបន្ទូលរបស់ព្រះនៅក្នុងកាលដែលមានថ្មជំពប់ជាច្រើន។

4. បេសកកជនបោះបង់ចោលអាទិភាពនៅក្នុងការអធិប្បាយដោយសារភាពជាក់ស្តែងរបស់ព័ន្ធកិច្ច

នៅក្នុងលំនាំនៃទីធ្វើព័ន្ធកិច្ចជាបន្ត ព័ន្ធកិច្ចរបស់បេសកកជនមិនអាចជួយអ្វីឡើយ មានតែធ្វើព័ន្ធកិច្ចជាច្រើន។ ដូច្នេះថ្មីៗនេះខ្ញុំបានរៀបចំព័ន្ធកិច្ចនៅកម្ពុជារបស់ខ្ញុំសម្រាប់រយៈពេល ១៣ឆ្នាំ នោះខ្ញុំបានរកឃើញថាខ្ញុំមានព័ន្ធកិច្ចទាំងអស់១៦ប្រភេទដូចជា ការបង្រៀនសិក្ខាសាលា កិច្ចការគ្រូគង្វាលនៅក្រុមជំនុំតាមតំបន់ បង្កើតក្រុមជំនុំសាខា ព័ន្ធកិច្ចនៃការផ្គត់ផ្គង់ខ្លួនឯង (CMF) ព័ន្ធកិច្ចផ្សាយដំណឹងល្អ ព័ន្ធកិច្ចនៃការបកប្រែ ការកែសម្រួលសៀវភៅពីបទគម្ពីរ វិទ្យាស្ថានខាងសេចក្តីជំនឿបែបកំណែទម្រង់របស់កម្ពុជា ការថ្វាយបង្គំលូតលាស់ក្នុងរយៈពេលមួយថ្ងៃ ព័ន្ធកិច្ច IT (កុំព្យូទ័រ និងទូរស័ព្ទដៃ) ការអោយជាគម្ពីរ ការឱ្យសម្ភារៈព្យាបាលបែបបុរាណនិងការដឹកនាំក្រុមបេសកកជនជាដើម។ ទាំងនេះមិនមែនជាព័ន្ធកិច្ចដែលខ្ញុំសំដៅទៅរកមុនមេដែលខ្ញុំចាប់ផ្តើមព័ន្ធកិច្ចនេះនោះទេ ប៉ុន្តែខ្ញុំបានធ្វើតាមការត្រូវការរបស់ពួកគេនៅក្នុងព័ន្ធកិច្ចបែបទូទៅរបស់ខ្ញុំនៅក្នុងការដេញតាមការងារបច្ចុប្បន្នរបស់ខ្ញុំ។

ជាទូទៅខ្ញុំចាប់ផ្តើមជាមួយការបង្រៀនមុខវិជ្ជារបស់ខ្ញុំទៅកាន់ថ្នាក់ភាពជាអ្នកដឹកនាំគ្រូគង្វាលមួយដោយមានពីរដងនៅក្នុងមួយឆ្នាំនៅក្នុងសភាពទន់ខ្សោយខាងរូបកាយរបស់ខ្ញុំ ហើយបន្ទាប់មកខ្ញុំបង្រៀនថ្នាក់ BA និង M.Div។ ហើយបន្ទាប់មកខ្ញុំបានគិតថា ប្រសិនបើព្រះបង្គាប់ឱ្យរៀបចំស្បែកជើងរបស់សិស្ស នោះខ្ញុំនឹងធ្វើដោយបន្ទាបខ្លួន។ ខ្ញុំគិតថា ប្រសិនបើខ្ញុំត្រូវបានធ្លាក់ចុះនៅក្នុងសភាពដ៏ទន់ទាប នោះខ្ញុំនឹងត្រលប់ទៅកាន់សហរដ្ឋអាមេរិក ដូច្នេះប្រពន្ធរបស់ខ្ញុំនឹងមើល

ថៃរខ្ញុំទ្វេរដង។ ទោះជាយ៉ាងណាក៏ដោយ ភាពទន់ខ្សោយរបស់ខ្ញុំត្រូវបានប្រសើរឡើងបន្តិចម្តងៗដោយសារព្រះគុណរបស់ព្រះ។ ខ្ញុំបានចូលនិវត្តន៍នៅអាយុ៦២ ឆ្នាំពីក្រុមជំនុំពេនីអែលប្រែសប៊ីធារៀន ហើយញុំាអាហារ ដេក បង្រៀន និងសិក្សានៅ ITCS អស់រយៈពេល៧ឆ្នាំដែលជាជីវិតជាប្រចាំថ្ងៃរបស់ខ្ញុំ។ នៅចុងសប្តាហ៍ ខ្ញុំបានទៅតាមសិស្សៗហើយបម្រើក្រុមជំនុំចំនួនប្រាំបីដោយអំណរទៅកាន់ព្រះអម្ចាស់។

បន្ទាប់មកខ្ញុំបានពិចារណាក្នុងការជួយពួកគេដោយការណាមួយ ហើយបានចាប់ផ្តើមជាមួយព័ន្ធកិច្ចកុំព្យូទ័រដើម្បីជួយសិស្សឱ្យមានការសិក្សាដែលប្រសើរឡើង ដោយវិធីសាស្ត្រនៃការប្រើប្រាស់កុំព្យូទ័រ។ ដូច្នេះពេលណាដែលខ្ញុំទៅលេងសហរដ្ឋអាមេរិក ខ្ញុំបានយកកុំព្យូទ័រចាស់ៗនិងជុសជុលពួកវា ហើយបានផ្តល់ដល់សិស្សខ្ចីដោយមានការចុះកិច្ចកុងត្រា។ នៅក្នុងទំនាក់ទំនងជាមួយពួកគេ នោះខ្ញុំព្យាយាមបង្រៀនការលំបាកបីយ៉ាងដូចជា ចិត្តដែលចេះអរគុន ការនិយាយថាខ្ញុំសុំទោស និងការធ្វើរបាយការណ៍ពីជីវិតរបស់ពួកគេដោយស្មោះត្រង់ជាដើម។ ហើយខ្ញុំក៏បានព្យាយាមជួយជីវិតខាងព្រលឹងវិញ្ញាណរបស់ពួកគេផងដែរ។ ខ្ញុំនៅតែបន្តស្មោះត្រង់នៅក្នុងព័ន្ធកិច្ច។ ខ្ញុំបន្តបន្ថែមព័ន្ធកិច្ចនៃការផ្តល់គម្ពីរ សៀវភៅវេយ្យាករណ៍អង់គ្លេស សៀវភៅដែលលក់ដាច់ជាងគេជាដើម។ ឥលូវនេះបន្ទាប់ពីខ្ញុំបានប្រកាសពីព័ន្ធឯករាជ្យរបស់ខ្ញុំរួចមក ខ្ញុំចាប់ផ្តើមបង្កើតក្រុមជំនុំតាមតំបន់នៅក្នុងកន្លែងមួយចំនួន។ អស់រយៈពេលប្រាំឆ្នាំ ខ្ញុំបានផ្តោតលើការផ្សាយដំណឹងល្អទៅកាន់អ្នកធ្វើការរោងចក្រនៅក្នុងផ្ទះជួលពីរល្វែង ប៉ុន្តែដោយស្មោះត្រង់ខ្ញុំមិនបានវាយប្រហារពួកគេនោះទេ ដោយសារគម្រោងជាច្រើន។ ដោយសារខ្ញុំបានរក

ឃើញថា ខ្ញុំមានការលំបាកខាងថវិការនៅក្នុងការថែរក្សាបុគ្គលិកនិងក្រុមជំនុំជាច្រើន។ ដូច្នេះខ្ញុំបានសម្រេចចិត្តធ្វើការរើទៅកន្លែងមួយទៀត ដែលមានតែមួយល្វែងដើម្បីនឹងកាត់បន្ថយគម្រោងចំណាយដើម្បីឱ្យមានសេរីភាពខ្លះ។ ក្នុងកាលដែលខ្ញុំចំណាយប្រហែល១០០០ដុល្លានៅក្នុងមួយខែ ខ្ញុំមានអារម្មណ៍ថាអាចទ្រាំទ្របានល្អនៅក្នុងបញ្ហានោះ។ ជួនកាលខ្ញុំមានបញ្ហាសុខភាពរបស់ខ្ញុំ ហើយខ្ញុំចង់ត្រលប់ទៅសហរដ្ឋអាមេរិកវិញ។ បន្ទាប់មកព្រះអម្ចាស់បានធ្វើឱ្យសុខភាពរបស់ខ្ញុំបានប្រសើរឡើងជាមុនដោយព្រះគុណរបស់ទ្រង់។ បន្ទាប់មកខ្ញុំបានរៀបចំព័ន្ធកិច្ចរបស់ខ្ញុំ ហើយបានចាប់ផ្ដើមពង្រីកវាឡើងដើម្បីទៅដល់គោលបំណងរបស់ខ្ញុំ។ ពេលនេះខ្ញុំមានបុគ្គលិកប្រហែលជា១៥នាក់និងក្រុមជំនុំជំនួន៧ ហើយមានក្រុមកោសិកាចំនួន២៧ ដែលមានទីតាំងស្ថិតនៅ២៥ខេត្តនៅក្នុងប្រទេសកម្ពុជា។ ហើយខ្ញុំក៏នឹងចាប់ផ្ដើមបង្កើតវិទ្យាស្ថានអប់រំកំណែទម្រង់កម្ពុជាផងដែរនៅក្នុងទីកន្លែងចំនួន៨ ភ្នំពេញ ប៉ៃលិន ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពត រតនៈគីរី ស្ទឹងត្រែងជាដើមនៅឆ្នាំ២០២០។ ទាំងនោះនឹងក្លាយជាព័ន្ធកិច្ចដែលផ្ដែកលើការផ្សាយដំណឹងនៅ២៥ខេត្តដើម្បីនឹងបង្កើតក្រុមជំនុំពេនីអែលប្រេ៊ីសប៊ីធារៀនកម្ពុជា។

បន្ទាប់មក ព័ន្ធកិច្ចរបស់ខ្ញុំនៅក្នុងការសរសេរ១០ផ្នែករបស់ព្រះគម្ពីរនឹងត្រូវបន្តរហូតដល់២០២០ដើម្បីនឹងបញ្ចប់ការកែសម្រួលគ្រប់សៀវភៅដែលមានចំណងជើង "ពិភពនៃបទគម្ពីរ" ដែលមានបីភាសា ហើយខ្ញុំតែងតែព្យាយាមសរសេរលើកុំព្យូទ័រ។ លើកលែងពីការទាំងនោះ ខ្ញុំរវល់នៅក្នុងការបង្កើតសៀវភៅបែបសាសនៈវិទ្យាសម្រាប់ក្រុមជំនុំកម្ពុជា ដែលជាមានភាពសមស្របទៅនឹងកម្រិតរបស់ពួក

គេ។ បន្ទាប់មកខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចទ្រាំធ្វើមិនអើរពើនឹងព័ន្ធកិច្ចនៃការអធិប្បាយបានឡើយ។ នេះជាបញ្ហាចម្បងដែល បេសកកជនទទួលរងគ្រោះនៅក្នុងទីធ្វើព័ន្ធកិច្ច។ ដូច្នេះពួកគេអាចនឹងទេរទៅរកការផ្ដល់អំណោយ ដើម្បីនឹងថែរក្សាសុខភាពរបស់យើងនិងរៀបចំរដ្ឋបាលក្រុមជំនុំជាដើម ជាជាងការសិក្សាព្រះគម្ពីរ ការអធិប្បាយព្រះបន្ទូលរបស់ព្រះនៅក្នុងចិត្តដែលក្រេវក្រោធទៅកាន់ក្រុមជំនុំដែលត្រជាក់។ បើទោះជាខ្ញុំបង្រៀនទៅកាន់សិស្សរបស់ខ្ញុំឱ្យចេះអធិប្បាយព្រះបន្ទូលរបស់ព្រះដោយខ្លាំងក្លា យ៉ាងស្មោះត្រង់ទៅដល់ពួកគេ ការពិតខ្ញុំបានរកឃើញថាខ្ញុំនៅឆ្ងាយពីការបង្រៀនរបស់ខ្ញុំណាស់។ ដូច្នេះក្រុមជំនុំកម្ពុជា យើងឃើញថាអំណាចនៅក្នុងការអធិប្បាយត្រូវបានបាត់បង់ដោយការប្ដូរការដែលចម្បងជាមួយនឹងការផ្សេងៗទៀត ដូចជាការធ្វើអំណោយ ការអប់រំ និងការខាងរដ្ឋបាលជាដើម។

5. ក្រុមជំនុំកម្ពុជានៅក្នុងការដេញតាមសម្ភារៈនិយម

ការចុះចាញ់នៃព័ន្ធកិច្ចការអធិប្បាយ យើងពិបាកដោះស្រាយណាស់ដោយសារបញ្ហាថវិកានៃសង្គមកម្ពុជា។ ដូច្នេះការអះអាងថាព័ន្ធកិច្ចត្រូវតែពឹងផ្អែកលើថវិកា។ មានអំណាចតែមិនអាចគេចផុតពីអន្ទាក់នៃសម្ភារៈនិយម មិនដូចជាវិធីសាស្ត្ររបស់ពួកកំណែទម្រង់សម្រាប់ព័ន្ធកិច្ចរបស់ក្រុមជំនុំឡើយ។ ការពិតដែលយើងបាត់បង់ការនោះបើទោះជាយើងមានមានលុយ នោះព័ន្ធកិច្ចនៅតែបន្តដោយការអធិប្បាយព្រះបន្ទូលរបស់ព្រះអម្ចាស់គឺសំខាន់ណាស់។ នៅពេលដែលបេសកកជនសារភាពថា ព័ន្ធកិច្ចគួរតែធ្វើដោយសារមានថវិកា វាជាការលំបាកយ៉ាងធ្ងន់ធ្ងរទាស់នឹងការអះអាងរបស់ពួកសាវក។ ជាការពិតណាស់ បេសកកម្មនៅកម្ពុ

ជានឹងត្រូវតែផ្តោតទៅលើព័ន្ធកិច្ចដែលក្រីក្រដោយសារបេសកកជនក្រមួយចំនួន នោះយើងមានតែផ្តោតលើព័ន្ធកិច្ចខាងលុយកាក់។ ដូច្នេះកម្មករកម្ពុជាមិនបានផ្តោតលើការយល់ពីព្រះបន្ទូលរបស់ព្រះនោះឡើយ តែហាក់ដូចជាមានភាពសុំនៅក្នុងការទទួលលុយមួយចំនួនពីអ្នកដទៃ។ ដូច្នេះព័ន្ធកិច្ចរបស់គ្រូគង្វាលបានធ្លាក់ចុះទៅក្នុងស្ថានភាពដែលអាក្រក់ ដែលព្យាយាមសុំជំនួយចេញពីភាពកំសោយរបស់បេសកកជន។ វិធីសាស្រ្តខុសឆ្គង នាំពួកគេទៅកាន់ភាពស្មោគគ្រោកល្បិកកិចកល ភាពលោភលន់និងអំពើបាប។ លើសពីនោះទៀត មនុស្សមួយចំនួនមិនអើពើនឹងការលះបង់យ៉ាងច្រើនដែលបេសកកជននិងក្រុមជំនុំបានរៀបចំអស់មួយជីវិតរបស់គេ ដោយមើលងាយព្រះបន្ទូលរបស់ព្រះដូចជាចោរ ហើយព្យាយាមទាញរកចំណេញពីក្រុមជំនុំដោយវិធីសាស្រ្តរបស់ពួកលោកិយ។

ដូចដែលវាត្រូវបានធ្វើឡើងដោយអ្នកអធិប្បាយ តើគាត់អាចនឹងអធិប្បាយព្រះបន្ទូលរបស់ព្រះដែលជាភាសាខាងគតិទៅកាន់ក្រុមជំនុំបានយ៉ាងដូចម្តេច? វាមិនអាចទៅរួចឡើយ។ ដូច្នេះ បើទោះជារូបភាពរបស់ពួកគេហាក់ដូចជាត្រូវបានដោះស្រាយ ប៉ុន្តែការពិតគេមិនមានការធានាអះអាងចេញពីសេចក្តីពិតពីការអធិប្បាយរបស់គេឡើយ។ ការបង្រៀនដែលគ្រូអធិប្បាយដែលអធិប្បាយដោយមានការអនុវត្តសេចក្តីពិត គួរតែឈរមាំនៅលើផ្លូវរបស់ព្រះអម្ចាស់ នោះគេនឹងមិនត្រូវផ្លាស់ប្តូរសេចក្តីពិតនៅក្នុងអ្នកអធិប្បាយនោះឡើយ។ "តែ ឱអ្នកសំណប់នៃព្រះអើយ ចូរឱ្យអ្នករត់ចៀសចេញពីសេចក្តីទាំងនោះ ហើយដេញតាមសេចក្តីសុចរិត សេចក្តីគោរពប្រតិបត្តិដល់ព្រះ សេចក្តីជំនឿ សេចក្តីស្រឡាញ់ សេចក្តីខ្ជាប់ខ្ជួន និងសេចក្តីសំឡូតវិញ" (១ធីម៉ូថេ ៦៖១១)។ ដូចជាគ្រាប់ពូជដុះនៅក្នុងបន្លា ដែលគ្រប់ដណ្តប់លើការលូតលាស់ដោយអំណាច នោះបញ្ហាថវិកា ការខ្វល់ខ្វាយនិង

សប្បាយនៅក្នុងម៉ាថាយជំពូក១៣ ការទាំងនោះធ្វើឱ្យការអធិប្បាយរបស់គ្រូអធិប្បាយមិនលូតលាស់ ទាំងនោះជាការដែលរារាំងដល់ការប្រកាសការអធិប្បាយនិងការអនុវត្តរបស់ការអធិប្បាយ។ ដូចដែលចិត្តដែលគោរពព្រះក្លែងក្លាយដែលបម្រើដល់សម្ភារៈ នោះព្រះនឹងត្រូវរលាយបាត់នៅក្នុងចិត្តរបស់ពួកគេ ការអធិប្បាយជាការដែលចេញមកពីចេស្តារបស់ព្រះ។ ហើយលំនាំនៃការអធិប្បាយរបស់គ្រូអធិប្បាយកម្ពុជាក្នុងការដើរតាមសម្ភារៈនឹងត្រូវបានព្យាបាលដោយការស្តារឡើងវិញនូវការអធិប្បាយតាមបទគម្ពីរ ជាការផ្ទុយគ្នានឹងវិធីសាស្រ្តដោយកំហឹងទាស់នឹងភ្លើងដែលកំពុងឆេះសន្ធោរសន្ធៅ។

6. ស្ថានភាពនៃការបះបោររបស់អ្នកដែលត្រូវបានត្រាស់ហៅ

ហើយខ្ញុំក៏ធ្វើការសម្គាល់នៅខាងលើ មនុស្សមួយចំនួនធ្វើការពន្យានៅក្នុងការចាក់ប្រេងតាំងរបស់គេ បើទោះជាគេទទួលការរៀបចំយ៉ាងស្កប់ស្កល់នៅក្នុងស្ថានភាពរបស់គេយ៉ាងខ្លាំងក្លាយក៏ដោយ។ នៅក្នុងភាពខ្មៅងងឹតនៃការធានាអះអាងខាងថវិកាជាបញ្ហាដ៏ធំ ប៉ុន្តែការដ៏ធំជាងទៀតនោះគឺជាការមិនមានចិត្តចង់ក្លាយជាគ្រូគង្វាលដែលចាក់ប្រេងតាំង ដែលមិនសម្រាប់ជាការស្វែងរករបស់គេនៅក្នុងអំណាចដែលគួរឱ្យមានកិត្តិយស។ គួរឱ្យសោកសៅណាស់។ ការពិតនោះ ការអធិប្បាយនិងពេលបង្រៀនធ្វើឱ្យយើងមានបទពិសោធន៍នូវអំណាចនៃការព្យាបាលនៅក្នុងចិត្តរបស់យើង និងមានបទពិសោធន៍នូវស្ថានសួគ៍នៅក្នុងវិញ្ញាណ។ ដូច្នេះ លោក B.B Warfield អះអាងថាទីអធិប្បាយរបស់គ្រូអធិប្បាយប្រៀបបីដូចជាបល្ល័ង្កស្ថានសួគ៌។ ដូច្នេះ បើទោះជាគ្រូអធិប្បាយដែលបានត្រាស់ហៅមានបញ្ហាច្រើននៅក្នុងពេលអធិប្បាយក៏ដោយ ដោយសារលុយ គាត់នឹងទេរ

ទៅរកទិសដែលវិជ្ជមានជា នោះជាការអធិប្បាយ។ ដូច្នេះ អ្នកដែលត្រូវបានត្រាស់ហៅនឹងបះបោរ។ ដូច្នេះបើទោះជាគាត់ឈប់រៀននៅក្នុងកម្មវិធីសិក្ខាសាលាក៏ដោយ គាត់នៅតែអាចអធិប្បាយនៅក្រុមជំនុំផ្សេងទៀតជាការងារបន្ថែម។ ហើយបេសកកជនមិនអើពើនិងទទួលពួកគេ ពីព្រោះពួកគេមានដែលកំណត់ដោយគ្រូគង្វាលជំនួយនៅកម្ពុជាសម្រាប់ភាសា វប្បធម៌ជាដើម។ ពីព្រោះពួកគេគិតថា ការអធិប្បាយជាមុខរបររបស់ពួកគេ ហើយការបង្រៀនជាចំណូលដែលសមស្របសម្រាប់ពួកគេ។ ពួកគេគិតដូច្នេះដោយមិនមានការត្រាស់ហៅ គេអាចធ្វើការទាំងអស់បានយ៉ាងល្អ។

7. ភាពខ្វះខាតនូវទស្សនៈដែលត្រឹមត្រូវនៃក្រុមជំនុំរបស់បេសកកជនសាមញ្ញ

បេសកកជនសាមញ្ញធម្មតាមិនត្រូវបានបញ្ជូនចេញដោយក្រុមជំនុំ ឬតម្រូវឱ្យធ្វើបេសកកម្មដោយកត្តាជម្រុញដែលខុសពីធម្មតាដូចជាពួកចាស់ទុំនោះ អ្នកមើលថែរក្សា និង ទៀយ kwon Sa និងគ្រូបង្រៀនជាដើមនោះឡើយ អាចនឹងរលុបបានទៅកាន់ទស្សនៈនៃក្រុមជំនុំដែលមានទំនាក់ទំនងទៅកាន់បេសកកម្មជំនួញរបស់គាត់។ ពួកគេគិតថាព័ន្ធកិច្ចនឹងអភិវឌ្ឍដោយសារអំណាចខាងទឹកប្រាក់។ ដូច្នេះពួកគេពួកគេប្រឈមនឹងការល្បួងនៅក្នុងការបន្ធូរបន្ថយជាមួយនឹងការយល់បែបបទគម្ពីររបស់ក្រុមជំនុំ។

បេសកកជនត្រូវបានហៅថាគ្រូគង្វាលសម្រាប់គ្រូវគង្វាល។ មានន័យថាបេសកកជនគួរតែជាគ្រូគង្វាលជាប្រាកដ។ អេភេសូ ៤ ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញបានប្រទានអំណោយមួយចំនួនទៅកាន់ក្រុមជំនុំមាន សាវក ហោរា អ្នក

ផ្សាយដំណឹងល្អ គ្រូគង្វាលនិងគ្រូបង្រៀន។ នៅទីនេះសាវកសំដៅលើសាវកទាំង ១៣។ ហោរាជាម្នាក់នៅក្នុងសញ្ញាថ្មីដែលមានតួនាទីស្មើនឹងសាវកដែរ ដូចជា ម៉ាកុស បាណាបាស់ ស៊ីឡាស់ ស្ទេផាន និងភីលីព។ អំណាចរបស់ពួកគេជាសាវក ពីព្រោះ ពួកគេត្រូវបានប្រើជាពិសេសដោយសារព្រះអម្ចាស់នៅក្នុងការសម្រេចនូវផ្នែកនៅក្នុងក្រុមជំនុំដើម។

នៅប៉ៃលិនមានបេសកកជនចាស់ម្នាក់បានមកកាលពី១០ឆ្នាំមុន គាត់បានសាងសង់ក្រុមជំនុំនៅក្នុងទីក្រុងដូចជាសណ្ឋាគារដ៏ល្អ ហើយបង្កើតក្រុមជំនុំសាខាយ៉ាងល្អដោយជំនាញសញ្ជាតិរបស់គេ។ ហើយគេក៏ឧបត្ថម្ភក្រុមជំនុំសម្រាប់គ្រូគង្វាលដើម្បីនឹងដឹកនាំគ្រប់ក្រុមជំនុំនីមួយៗ។ ប៉ុន្តែគ្រូគង្វាលកម្ពុជាចង់ចាកចេញដើម្បីទទួលបានព័ន្ធកិច្ចឯករាជ្យ បើទោះជាពួកគេមានប្រយោជន៍យ៉ាងច្រើនពីក្រុមជំនុំក៏ដោយ។ ជាការពិត ពួកគេត្រូវការឈរមាំដោយខ្លួនរបស់ពួកគេផ្ទាល់នៅក្នុងជីវិតរបស់ពួកគេដោយមិនមានជំនួយ។ បញ្ហារបស់ពួកគេ គឺជាការផ្តោតទៅលើបញ្ហាលុយកាក់។បោះទោះជាបេសកកជនចាស់ទុំចង់ឈររឹងមាំដើម្បីនឹងថ្វាយខ្លួនរបស់គាត់ទៅក្នុងព័ន្ធកិច្ចរបស់គ្រូគង្វាល ពួគគេមិនចង់បាននរណាឱ្យគ្រប់គ្រងដោយចាស់ទុំម្នាក់ទៀតនោះឡើយ។ គាត់បានស្រែកឡើងថា វាជាបញ្ហានៃការត្រាស់ហៅ។ ដូច្នេះវាពិបាកណាស់ដែល អ្នកអធិប្បាយគួរតែផ្តោតលើលារអធិប្បាយនិងព័ន្ធកិច្ចនៃការអធិប្បាយនិងព័ន្ធកិច្ចនៃការអធិប្បាយដែលនឹងត្រូវបានប្តូរទៅជាជម្រើសនៃព័ន្ធកិច្ចគ្រូគង្វាលរបស់គាត់។

8. គ្រូគង្វាលកម្ពុជាចង់ដេញតាមព័ន្ធកិច្ចឯករាជ្យ

គ្រូគង្វាលកម្ពុជាចង់ឈររឹងមាំដោយឯករាជ្យ។ ក្នុងកាលដែលពួកគេមានវិធីសាស្ត្រមួយចំនួននៅក្នុងព័ន្ធកិច្ចគ្រូគង្វាល យើងគួរតែសហការណ៍ជាមួយពួកគេដើម្បីនឹងថ្វាយសិរីល្អដល់ព្រះ។ ការទាំងនេះចេញមកពីការបោះបង់ចោលអាទិភាពនៃការអធិប្បាយនៅក្នុងព័ន្ធកិច្ចគ្រូគង្វាលរបស់ពួកគេ។ ក្នុងកាលដែលក្រុមជំនុំដើរទៅកាន់ចំនុចកណ្តាលនៃសម្ភារៈនិយម និងសុវត្ថិភាពនៃជីវិត ដែលមិនបានយកព្រះបន្ទូលរបស់ព្រះជាចំនុចកណ្តាល នោះគេនឹងបាត់បង់ចរិតលក្ខណៈបរិសុទ្ធ។ ពួកគេមានបន្ទុកជាច្រើននៅក្នុងការថ្វាយខ្លួនរបស់គេដាច់ទៅក្នុងការអធិប្បាយព្រះបន្ទូលរបស់ព្រះ។ ការមួយនេះជាការដ៏គ្រោះថ្នាក់នាពេលបច្ចុប្បន្នរបស់គ្រូអធិប្បាយ ដែលផ្តោតទៅលើការរកប្រាក់ឧបត្ថម្ភដោយខ្លួនឯងនៅក្នុងព័ន្ធកិច្ច។ ប្រសិនបើគេពន្យាកិច្ចការដែលចម្បង ដើម្បីនឹងដេញតាមសុវត្ថិភាពនៃជីវិតចុងក្រោយគឺជាការស្លាប់។ ជាលទ្ធផល ពួកគេមិនអាចធ្វើព័ន្ធកិច្ចនៅក្នុងចំណុចកណ្តាលដែលជាព្រះបន្ទូលរបស់ព្រះទៀតនោះឡើយ។ មហន្តរាយទាំង៨នៃក្រុមជំនុំកម្ពុជាត្រូវបានជំនួសដោយការផ្តល់យោបល់ ឱ្យត្រឡប់ទៅកាន់ព្រះគម្ពីរនិងការស្តារឡើងវិញនៃការអធិប្បាយតាមបទគម្ពីរ។ ដូចជាកាលដែលយើងត្រឡប់ទៅកាន់គម្ពីរ កិច្ចការថ្មីនឹងកើតឡើង បញ្ហាចម្បងរបស់ក្រុមជំនុំកម្ពុជានោះត្រូវតែត្រលប់ទៅកាន់បទគម្ពីរ។ បន្ទាប់មកតើការអធិប្បាយបែបណាដែលសមស្របទៅនឹងក្រុមជំនុំកម្ពុជា? ចម្លើយគឺការអធិប្បាយបែបកំណែទម្រង់របស់ពួកបរិសុទ្ធ។ ជំពូកបន្ទាប់នឹងនិយាយពីការលូតលាស់បែបប្រវត្តិសាស្ត្ររបស់ការអធិប្បាយបែបកំណែទម្រង់របស់ពួកបរិសុទ្ធ។

# ជំពូកទី ៣

## ទ្រឹស្តីរបស់ពួកបរិសុទ្ធ ការអធិប្បាយរបស់ពួកកំណែទម្រង់

លោកបណ្ឌិត Joseph Pipa ជាអ្នកដែលណែនាំនៅក្នុងព័ន្ធកិច្ចថ្នាក់បណ្ឌិតនៅ Westminster Theological Seminary នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាពីឆ្នាំ ១៩៩៣ ដល់១៩៩៦ គាត់បានចង្អុលប្រាប់ថាអ្នកអធិប្បាយជាច្រើននិងមានការអធិប្បាយជាច្រើននៅក្នុងគ្រាបច្ចុប្បន្ននេះបានទទួលឥទ្ធិពលពី "សិល្បៈនៃការទស្សទាយ" ដែលត្រូវបានសរសេរដោយ លោក William Perkins នៅក្នុងសារណារបស់គាត់ "ការអភិវឌ្ឍនៃការអធិប្បាយរបស់ William Perkins "។

គោលការនៃការអធិប្បាយរបស់គាត់ដែលចេញមកពីសិល្បៈនៃការទស្សទាយដែលសាមញ្ញ។ គោលការណ៍ត្រូវបានសង្ខេបដោយចំណុចពីរ ការបកប្រែ និងការដាក់អនុវត្ត ឬ ការពន្យល់និងការអនុវត្ត។ ម្យ៉ាងទៀតនិយាយបានថា ជាការបកប្រែបទគម្ពីរនិងការដាក់អនុវត្តនៅក្នុងជីវិត។ ការចេញចូលរបស់ការបកប្រែនិងការអនុវត្ត ការអនុវត្តនិងការបកប្រែ វាជាវិធីសាស្រ្តដើម្បីនឹងទំនាក់ទំនងទៅកាន់ក្រុមជំនុំដែលទទួលការអធិប្បាយដោយផ្ទាល់។

គោលការណ៍របស់លោក Lloyd Jones ដែលជាអ្នកដែលមានឥទ្ធិពលលើអ្នកអធិប្បាយកូរ៉េយ៉ាងច្រើននៅក្នុងប្រមាណពីរបីទស្សវត្សគឺជារឿងមួយនេះហើយ។ យើងគួរតែធ្វើការពីរបៀបនៃគោលការណ៍ពីររីកចម្រើននៅក្នុងសៀវភៅដូចតទៅនេះ "សិល្បៈនៃការទស្សទាយ" ដើម្បីអនុវត្តការទាំងនេះទៅក្នុងក្រុមជំនុំកម្ពុជានៅក្នុជំពូកនេះ។

1. តើអ្វីទៅជាបទគម្ពីរ?

តាមប្រវត្តិសាស្រ្តគ្រូអធិប្បាយមិនបានអានអត្ថបទបានអធិប្បាយព្រះបន្ទូលរបស់ព្រះ ជាទូទៅបន្ទាប់ពីអានអត្ថបទ បកប្រែអត្ថបទជាការចាប់ផ្តើមនៃការអធិប្បាយ ។ ដូច្នេះអ្នកអធិប្បាយបានចាប់ផ្តើមជាមួយការបង្កើតការអធិប្បាយទៅកាន់អត្ថបទដែលបានជ្រើសរើស។

បន្ទាប់មកមានកិច្ចការចម្បងទៀតជាការធ្វើឱ្យប្រាកដថាព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះពិតប្រាកដ។ ការធានាអះអាងថាអត្ថបទជាព្រះបន្ទូលរបស់ព្រះ ជាគ្រឹះនៃការបកប្រែនៃបទគម្ពីរ។ ចំណុចចាប់ផ្តើមដែលអ្នកអធិប្បាយបានពិចារណានោះ ជាគោលគំនិតមួយដែលមិនច្បាស់លាស់ ដែលថាព្រះបន្ទូលរបស់ព្រះត្រូវបានលាយឡំនៅក្នុងអត្ថបទនឹងបង្ករឱ្យមានកំហុសមួយចំនួន។ គាត់នូវតែមិនអាចស្គាល់ពីសេចក្តីសង្គ្រោះពីបទគម្ពីរដូចជាមនុស្សទូទៅដែរ ដូច្នេះគាត់មិនអាចអធិប្បាយទៅកាន់ក្រុមជំនុំបានទេ ពីព្រោះគាត់មិនអាចគ្រប់គ្រងលើសីលធម៌តាមបទគម្ពីរបាននៅឡើយ។ ហេតុអ្វី? ពីព្រោះការអធិប្បាយគឺជាការយល់ពីបទគម្ពីរដើម្បីនឹងពន្យល់ពីបទគម្ពីរ និងអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ដើម្បីធ្វើឱ្យពួកគេរក្សានៅក្នុងជីវិតរបស់ពួកគេដោយស្មោះត្រង់ ដោយមិនមានការបកប្រែព្រះគម្ពីរមិនមានការអធិប្បាយ។

សព្វថ្ងៃនេះ បញ្ហាមួយចំនួននៃការច្របូកច្របល់ជាច្រើនដែលក្រុមជំនុំកម្ពុជាទទួលរងគ្រោះនៅក្នុងការអធិប្បាយត្រូវបានកើតឡើងនៅក្នុងប្រវត្តិសាស្រ្តរួចទៅហើយ។ បញ្ហាសំខាន់នៃការច្របូកច្របល់គឺជាទស្សនៈរបស់បទគម្ពីរ។ វាជាសេច

ក្តីពិតបញ្ហាដែលមិនជឿបទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះ ឬការទទួលព្រះគម្ពីរទុកជាពាក្យរបស់មនុស្សនិងគំនិតរបស់មនុស្ស ឬដោយការគិតថាបទគម្ពីរបែបដូចជាក្លែងក្លាយហាក់ដូចជាគេបានជឿព្រះគម្ពីរថាជាព្រះបន្ទូលរបស់ព្រះពិតប្រាកដមែន មានដំណឹងមួយចំនួនដែលនឹងកើតឡើង។ ការជាក់ស្តែងនោះគ្រូក្លែងក្លាយកើតចេញពីការមិនទទួលស្គាល់លក្ខណៈច្បាស់លាស់នៃបទគម្ពីរ ដែលជាចរិតដែលមានអំណាចរបស់ព្រះគម្ពីរនិងភាពពេញលេញនៃបទគម្ពីរដែលពួកកំណែទម្រង់បានអះអាង។ និយាយដោយខ្លី វាត្រូវបានពឹងលើ "ព្រះបន្ទូលរបស់ព្រះ (បទគម្ពីរ) ដែលជាវិញ្ញាណនិងជាជីវិត" (យ៉ូហាន ៦៖)។ ដូចជាលោក Herman Bavinck បានធ្វើដូច្នោះដែរ ដូចដែលយើងបានអានអត្ថបទនៅក្នុងបទគម្ពីរ យើងស្តាប់ទៅកាន់សូរសៀងរបស់ព្រះដោយផ្ទាល់ចេញពីស្ថានសួគ៌ នោះយើងដើរតាមទស្សនៈនេះទៅលើបទគម្ពីរ។

គ្រូរបស់ខ្ញុំ លោក Jung Am, Dr. Yun Sun Park ដែលជាបណ្ឌិតខាងសាសនៈវិទ្យាដ៏អស្ចារ្យ ជាអ្នកសរសេរការបកស្រាយបទគម្ពីរ ដែលក្រុមជំនុំកូរ៉េចាប់ផ្តើមមានការអះអាងថា មានតែមួយគត់ដែលជាអ្នកពឹងផ្អែកលើការបើកសម្តែង (បទគម្ពីរ) ដែលនឹងត្រូវបានសង្គ្រោះនៅក្នុងសៀវភៅរបស់គាត់ "សាសនៈវិទ្យាតាមបទគម្ពីរ"។ នៅទីនេះ ការបើកសម្តែងនោះជាបទគម្ពីរ។ ជាការពឹងផ្អែកមានន័យថាសេចក្តីជំនឿដែលបានដាក់ខ្លួនរបស់គាត់ទៅលើព្រះបន្ទូល ជាការពិចារណាមានន័យថាជាគំនិតរបស់គាត់ ជាគ្រឹះមានន័យថាសកម្មភាពរបស់មនុស្ស។ គំនិតនេះជាចរន្តដើម្បីនឹងបញ្ជាក់ពីមនុស្សទាំងមូល ដែលជាឫសគល់និងជាគ្រឹះ ដែលជាចិត្ត។ ទស្សនៈនេះចេញមកពីសកម្មភាពដែលប្រច្រាស់នឹងទស្សនៈរបស់ពួករ៉ូមាំង

កាតូលិកពីបទគម្ពីរនៅក្នុងពេលកំណែទម្រង់ ដែលត្រូវបានដោះស្រាយពីចរិតលក្ខណៈរបស់ក្រុមជំនុំពួកកំណែទម្រង់។ ពួកប្រូតេស្តង់ជាក្រុមដែលជឿលើបទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះដោយមិនមានកំហុសអ្វីសោះ។

2. តើការបកប្រែបទគម្ពីរត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច?

តើគម្ពីរគួរតែត្រូវបានបកប្រែយ៉ាងដូចម្តេច? តាមប្រពៃណីរបស់សាសនៈវិទ្យារបស់ពួកកំណែទម្រង់គេបានពិចារណាពីការបកប្រែគម្ពីរនៃសេចក្តីប្រោសលោះ។ វាមានន័យថាគម្ពីរមានលំនាំនៃសេចក្តីប្រោសលោះឡ។ កាលដែលយើងបកប្រែអត្ថបទនៅក្នុងចំណុចកណ្តាលរបស់ព្រះគ្រីស្ទ យើងគួរតែមើលទៅអត្ថបទនៅក្នុងទស្សនៈរបស់ព្រះគ្រីស្ទ។ ការនេះត្រូវបានហៅថាការបកប្រែពីប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះ ឬការបកប្រែនៃចំណុចកណ្តាលនៃការតាំងសញ្ញា។ ការបកប្រែនេះត្រូវបានទទួលស្គាល់ដោយ Westminster Theological Seminary ដែលជាចំណុចកណ្តាលនៃសាសនៈវិទ្យាខាងកំណែទម្រង់នៅក្នុងលោកិយនិងសាលាកំណែទម្រង់ដែលបានដើរតាមដោយជាប់លាប់ ដែលត្រូវបានសង់ឡើងនៅលើសាសនៈវិទ្យាតាមបទគម្ពីរដែលបានសរសេរដោយលោក Gerrhardus Vos ដែលជាបណ្ឌិតសាសនៈវិទ្យានៃសាសនៈវិទ្យាតាមបទគម្ពីរ។

1) លោក Vern Poythress ដែលជាសាស្ត្រាចារ្យខាងការបកស្រាយព្រះគម្ពីរនៅ Westminster Theological Seminary ចូលចិត្តបកប្រែវានៅក្នុងវិធីមួយដែលអភិវឌ្ឍថែមទៀត នៅក្នុងគ្រឹះនៃការបកប្រែនេះ ហើយជាអ្នកដែលនិយាយពីអន្តរទំនាក់ទំនងនៃព្រះជាម្ចាស់ជាកណ្តាល។ ចំណុចកណ្តាលនៃ

លំនាំនៃសេចក្តីប្រោសលោះជាព្រះគ្រីស្ទ គាត់បានអះអាងថាយើងគួរតែបកប្រែអត្ថបទនៅលើជួរនៃប្រវត្តិសាស្ត្រនៃការប្រោសលោះ ដោយការបត់បែននៅក្នុងការដែលយើងសិក្សាពីសញ្ញាចាស់ នោះយើងគួរតែបកប្រែក្រឹត្យវិន័យនិងនិមិត្តរូបអាចជាផ្តេកទៅរកការបកប្រែដែលយកមនុស្សជាទីកណ្តាល ដែលនោះជាការយកមនុស្សជាកណ្តាល ឬជាសីលធម៌និងពិធីដែលមិនមែនជាដំណឹងល្អ។ បន្ទាប់ពីនោះមកគាត់អះអាងពីការបកប្រែដែលយកព្រះត្រៃឯកជាកណ្តាលនៅលើគ្រឹះនៃប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះ។

2) អ្នកអធិប្បាយបែបកំណែទម្រង់របស់ពួកបរិសុទ្ធដែលមានទស្សនៈរបស់កាល់វីនបកប្រែអត្ថបទបែបជាវេយ្យាករណ៍ ប៉ុន្តែដេញតាមការបកប្រែដែលយកការតាំងសញ្ញាជាកណ្តាល។ លោក J.I Packer បានរៀបចំដូចតទៅ៖ "១ បកប្រែគម្ពីរដោយន័យត្រង់ៗនិងតាមវេយ្យាករណ៍ ២បកប្រែគម្ពីរដោយទៀតត្រង់និងមានភាពសមស្របគ្នា ៣ បកប្រែគម្ពីរបែបជាគោលសេចក្តីជំនឿនិងយកព្រះជាកណ្តាល។ ៤ បកប្រែគម្ពីរបែបអំពីព្រះគ្រីស្ទនិងបែបផ្សាយដំណឹងល្អ ៥បកប្រែគម្ពីរដោយមានការសង្កេតនិងការអនុវត្ត។ ៦ បកប្រែគម្ពីរជាមួយការដាក់អនុវត្តដែលស្មោះត្រង់និងពិតប្រាកដ។" ដោយសារការបកបែពីព្រះគ្រីស្ទជារូបរាងនៃការបកប្រែ បើទោះជាទស្សនៈរបស់ពួកគេខុសគ្នាក៏ដោយ វាបានមកដល់ការសន្មត់ដូចគ្នា ប៉ុន្តែវាអាចនឹងធ្លាក់ចុះនៅក្នុងស្ថានភាពដែលគ្រោះថ្នាក់ក្នុងកាលដែលពួកគេគិតទៅលើគម្ពីរសញ្ញាចាស់។ បន្ទាប់មកក្នុងកាលដែលពួកគេមានទស្សនៈនៃប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះសម្រាប់ការបកប្រែ ពួកគេនឹងមានផលប្រយោជន៍នៅក្នុងការបកប្រែនោះ។

3) ខ្ញុំដេញតាមការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះជាចំណុចកណ្ដាលនៃការបកប្រែ។ វាមានន័យថា បោះទោះជាវាមានឫសដូចគ្នាទៅនឹងការបកប្រែទាំងពីរខាងលើក៏ដោយ តែវាបានសង្កត់ធ្ងន់លើផ្នែកដែលអនុវត្តថែមទៀត ហើយផ្ដោតទៅលើសីលធម៌របស់គ្រីស្ទាន។ ខ្ញុំប្រាកដថាគ្រប់ទាំងសាសនៈវិទ្យាទាំងអស់និងសេចក្ដីជំនឿរបស់វាផងគួរតែបង្ហាញនៅក្នុងជីវិត សេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពស្មោះត្រង់ ពីព្រោះរបៀបដែលបទគម្ពីរទាមទារគឺជាជីវិតបែបបទគម្ពីរនិងសីលធម៌របស់វា។ និយាយម្យ៉ាងទៀត ដោយសារវាគួរតែត្រូវបានបង្ហាញបែបជាផលផ្លែដែលរឹងមាំនិងកែវថ្លារបស់វានៃសេចក្ដីប្រោសលោះ។ វាជាការបញ្ជាក់មួយទៀតនៃសិរីល្អរបស់ព្រះដែលជាចំណុចកណ្ដាលនៃការបកប្រែ។

(២) វាត្រូវបានបង្ហាញដោយការសួរសំណួរមួយចំនួនទៅកាន់ការបកប្រែសំណួររបស់លោក Vern Poythress មានដូចតទៅ

(១) តើសេចក្ដីសុចរិតរបស់ព្រះត្រូវបានបង្ហាញនៅក្នុងអត្ថបទនេះដូចម្ដេច?

(២) តើអ្វីទៅជាសេចក្ដីមេត្តារបស់ព្រះត្រូវបានបង្ហាញនៅក្នុងអត្ថបទ?

(៣) តើអ្វីទៅជាសេចក្ដីស្មោះត្រង់របស់ព្រះដែលបង្ហាញនៅក្នុងអត្ថបទ?

(៤) តើអត្ថបទនិយាយអ្វីពីការស្ដារឡើងវិញនូវរូបឆ្លុះរបស់ព្រះមកកាន់យើង?

សំណួរទាំងនេះនឹងធ្វើឱ្យយើងបកប្រែអត្ថបទជាមួយទស្សនៈដែលត្រឹមត្រូវ ដើម្បីឱ្យពួកគេរក្សាតុល្យភាពនៅក្នុងការអធិប្បាយ។ ជីវិតដែលមានព្រះគ្រីស្ទជាកណ្តាលគួរតែជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងជីវិត។ ពីព្រោះវាជាផលផ្លែនៃសេចក្តីប្រោសលោះនិងការបញ្ជាក់របស់វា។

6) យើងអាចសំដៅទៅលើគោលការណ៍នៃការបកប្រែតាមរយៈក្រាបនៃការបកប្រែនៃអត្ថបទនៅក្នុងចំនុចបន្ថែម។

3. តើយើងអនុវត្តការបកប្រែរបស់យើងបានដោយរបៀបណា?

វាជាការធម្មតាដែលការបកប្រែមនិងការដាក់អនុវត្តចេញមកពីការយល់នូវស្ថានភាពដែលទំនាក់ទំនងទៅកាន់ក្រុមជំនុំបច្ចុប្បន្ន។ ក្រុមជំនុំកម្ពុជាមិនអាចគេចផុតពីវប្បធម៌របស់កម្ពុជានិងសាសនារបស់គេនោះទេ។ បើទោះជាការយល់ដឹងចេញពីការត្រួតពិនិត្យសៀវភៅមួយចំនួននិងជីវិតរបស់ពួកគេ ជនជាតិកម្ពុជានៅក្នុងទស្សនៈនៃបទគម្ពីរគឺនៅតែជាអ្នកមានបាបនៅក្រោមសេចក្តីក្រោធរបស់ព្រះ។ ដូច្នេះយើងគួរតែយល់ពីសភាពដ៏វេទនារបស់ពួកគេនិងព្យាបាលពួកគេដោយព្រះបន្ទូលរបស់ព្រះ។ យើងគួរតែជ្រើសរើសអត្ថបទដែលចាំបាច់និងបង្ហាញនូវឧទាហរណ៍របស់ពួកគេនៅក្នុងការអធិប្បាយ។

ឧទាហរណ៍ តើយើងអាចមើលទៅលើបញ្ហានេះដើម្បីផ្តល់ការជ្រមុជទៅកាន់អ្នកចាប់ផ្តើមដំបូងដូចម្តេច? យើងគួរតែបកប្រែវាដោយការស្វែងរកបទគម្ពីរនិងបកប្រែវាតាមបទគម្ពីរ។

ជាទូទៅ ការបកប្រែនិងការអនុវត្តត្រូវបានកើតឡើងក្នុងពេលតែមួយ។ មុនការនេះត្រូវបានអនុវត្តទៅកាន់ការរៀបរៀងនៃសេចក្តីអធិប្បាយ វាត្រូវមានកំណត់នូវការអនុវត្តទៅកាន់ការបកប្រែនៃអត្ថបទដោយខ្លួនវាផ្ទាល់។ ការអនុវត្តនឹងត្រូវបានទទួលបានប្រតិកម្មលើនៅពេលដែលគិតពីការសញ្ជឹងគិតផ្ទាល់ខ្លួន និងការថ្វាយបង្គំផ្ទាល់ខ្លួន។ បោះទោះជាអ្នកអធិប្បាយមានការលំបាកនៅក្នុងការដាក់ការអនុវត្តក៏ដោយ ពីព្រោះដោយសារការគិតខ្លាំងពេករបស់គាត់ ប៉ុន្តែដំបូងបង្អោះ យើងអាចអនុវត្តវាទៅកាន់គាត់ផ្ទាល់និងក្រុមជំនុំរបស់គាត់។ នៅក្នុងដំណើរការនេះ អ្នកអធិប្បាយនឹងទទួលបានប្រយោជន៍ជាច្រើនពីការនោះ។ នេះជាស្នូលនៃការអធិប្បាយនិងជាគន្លឹះទៅកាន់ការអនុវត្តទៅកាន់ក្រុមជំនុំ។

ក្រុមជំនុំកម្ពុជាត្រូវបានបង្ហាញរូបរាងមួយចំនួនទៅកាន់ការបកប្រែខុសឆ្គងនៃបទគម្ពីរ។ ពួកគេមាននិម្មិតជាច្រើននៃបទគម្ពីរ និងការលំបាកជាច្រើនសម្រាប់ការបកប្រែនៃពាក្យសព្ទនៅមានដែនកម្រិត។ ហើយដោយសារពួកគេមិនអាចគ្រប់គ្រងលើប្រភេទនិងនិមិត្តរូបរបស់បទគម្ពីរ ធ្វើឱ្យពួកគេស្ថិតនៅក្នុងស្ថានភាពដែលពិបាក។ ដូច្នេះយើងត្រូវការបកប្រែប្រភេទនិងនិមិត្តរូប ដែលជាចំណុចពីរដែលត្រឹមត្រូវ ជាការបញ្ជាក់នៃការបើកសម្តែងនៅក្នុងសញ្ញាចាស់។ យើងអាចប្រតិកម្មលើវានៅក្នុងទស្សនះរបស់លោក Gerrhardus Vos ជាគ្រឹះទូទៅ។

ឧទាហរណ៏ វាមានប្រយោជន៍នៅក្នុងការពន្យល់ពីព្រឹត្តិការណ៍នៅក្នុងការក្រលេកមើលពស់ដ៏គួរឱ្យខ្លាចនិងពស់លង្ហិននៅវាលរហោស្ថាន។ នៅទីនេះពស់លង្ហិនផ្ទាល់បង្ហាញពីប្រភេទដែលជាប្រភេទសំដៅទៅលើព្រះគ្រីស្ទ។ ហើយការដែលមើលទៅកាន់វាដែលត្រូវបានព្យួរនៅលើដំបងគឺគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ។ តាមរយៈនិមិត្តរូបនេះ

យើងអាចរៀនអ្វីទៅជាការផ្សាយដំណឹងល្អ។ សកម្មភាពបង្ហាញពីជីវិតនៃសេចក្តីជំនឿនៅវាលរហោស្ថាននិងក្នុងពេលតែមួយ វាបង្ហាញពីរបៀបដែលជឿដល់ព្រះគ្រីស្ទពិតប្រាកដ។ ការជឿលើព្រះគ្រីស្ទជាឧទាហរណ៍ដែលពួកគេបានថ្វាយខ្លួនរបស់ពួកគេនាទីបច្ចុប្បន្ននេះ។ សកម្មភាពដែលពួកគេដាក់ខ្លួនរបស់ពួកគេទៅសម្លឹងមើលពស់យ៉ាងពេញលេញជាសេចក្តីជំនឿរបស់យើង។ នៅក្នុងព្រឹត្តិការណ៍ដែលសាមញ្ញនិមិត្តរូបនិងប្រភេទត្រូវបានស៊ីគ្នា ជាសេចក្តីពិតដែលមានតែព្រះគ្រីស្ទប៉ុណ្ណោះដែលជាព្រះសង្គ្រោះរបស់យើង និងដោយសេចក្តីជំនឿទៅកាន់ទ្រង់យើងអាចទទួលបានការសង្គ្រោះ ហើយនឹងបានជាបរិបូរនិងកាន់តែច្បាស់នៅក្នុងការយល់ដឹងរបស់យើង។ បែបដូច្នោះហើយ ដែលការបើកសម្តែងជារូបភាពធ្វើឱ្យយើងយល់ពីសេចក្តីពិតយ៉ាងបរិបូរណ៍។

ព្រឹត្តិការណ៍នៃការឆ្លងសមុទ្រក្រហមត្រូវបានយល់ថាជាការជ្រមុជនៃក្រុមជំនុំនៃទីរហោស្ថាន។ (១ កូរិនថូស 10:1-2) អត្ថបទនេះទាមទារការបកប្រែនៃនិមិត្តរូប។ អេស៊ីពចង្អុលទៅកាន់លោកិយ អារក្ស និងសាច់ឈាម។ ហើយសមុទ្រក្រហមជាលំនាំនៃអំពើបាប។ ហើយក៏ពីព្រឹត្តិការណ៍នៃការញែក មានន័យថាជាកិច្ចការរបស់ព្រះនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់។ និយាយម្យ៉ាងទៀត វាជារូបរាងថា រាស្ត្ររបស់ព្រះបានទទួលពិធីជ្រមុជ។ វាពន្យល់នូវការកើតជាថ្មីដែលគេបានស្លាប់ ត្រូវបានបញ្ចុះនៅក្នុងបាបរបស់គេ ហើយត្រូវបានរស់ឡើងម្តងទៀតនៅក្នុងកំណើតខាងវិញ្ញាណ។ សមុទ្រក្រហមនៅក្នុសញ្ញាថ្មី ជាសេចក្តីស្លាប់ ជាលទ្ធផលនៃអំពើបាបដែលត្រូវបានដកចេញ ហើយមានជីវិតថ្មីត្រូវបានផ្តល់មកដោយសេចក្តីជំនឿតាមរយៈកិច្ចការរបស់ព្រះគ្រីស្ទ។ ដូច្នេះ យើងបកប្រែថាព្រឹត្តិការណ៍នៃការឆ្លងកាត់សមុទ្រក្រហមមានន័យថាជាជ្រមុជ

ទឹករបស់ក្រុមជំនុំ។ ពីព្រោះពួកសាវ័កបានបកប្រែវា នោះយើងទទួលយកវាបែបដូច្នេះ នៅក្នុងចិត្តរបស់យើង។

ប្រសិនបើយើងទទួលយកនិមិត្តរូបបែបត្រង់ៗ ដូចជាការយកឈ្នះលើបញ្ហា ឬដោយសង្ឃឹមរងចាំការអស្ចារ្យណាមួយដោយការចុះចូលទៅក្នុងទន្លេមេគង្គ និងបឹងទន្លេសាបទុកជាពាក្យនៅក្នុងការដាក់អនុវត្ត នោះយើងបានទាសចេញឆ្ងាយពីការបកប្រែរបស់ពួកសាវ័ករួចទៅហើយ។ អ្នកអធិប្បាយដែលមិនដើរតាមពួកសាវ័កមិនអាចអធិប្បាយពីព្រះគ្រីស្ទបានឡើយ។ គាត់បានត្រឹមតែបង្ខំឱ្យជឿលើគំនិតរបស់គាត់មិនមែនដល់ព្រះគ្រីស្ទដល់ក្រុមជំនុំរបស់គាត់។

ចេញពីការមួយនេះហើយដែលលេចចេញពួកគ្រូក្លែងក្លាយ និងដោយការបញ្ចូលការមួយនេះទៅកាន់គ្រីស្ទានដែលមិនសូវបានរៀនសូត្រសាសនៈវិទ្យាខុសឆ្គងនឹងត្រូវបានផ្តុំឡើងនិងទាស់ទៅនឹងព្រះគ្រីស្ទ ហើយចុងក្រោយគេនឹងចាកចេញពីព្រះគ្រីស្ទ។

ការបកប្រែរបស់គ្រូអធិប្បាយជាគន្លឹះនៃការបង្កើតខ្លឹមសារនៃការអធិប្បាយ។ កាលដែលគេស្គាល់អត្ថបទនិងពន្យល់វានៅក្នុងការតាមអារម្មណ៍របស់គាត់ នោះគេអាចនឹងទាស់នឹងព្រះគ្រីស្ទ ហើយបង្ខំការបង្រៀនក្លែងក្លាយទៅកាន់ក្រុមជំនុំទាស់នឹងព្រះគ្រីស្ទ ហើយគេអាចបង្កើតប៉មបាបិលរបស់ពួកគេ។ ដូច្នេះគេគួរតែសិក្សាអត្ថបទយ៉ាងច្បាស់លាស់និងយល់ពីវាអោយច្បាស់ ហើយគួរតែត្រលប់ទៅកាន់របៀបនៃការបង្កើតខ្លឹមសារនៃការអធិប្បាយ។

នៅក្នុងសេចក្តីសង្ខេប អ្នកអធិប្បាយជាអ្នកដែលស្មោះត្រង់នៅក្នុងការធ្វើឱ្យបទគម្ពីរមានបន្ទូលទៅកាន់ក្រុមជំនុំផ្ទាល់។ ពីព្រោះដោយសារអ្នកនាំសាររបស់ស្តេច គាត់គួរ

តែស្មោះត្រង់ទៅកាន់ស្តេច។ ការអធិប្បាយរបស់ពួកបរិសុទ្ធជាការប្រកាសសេចក្តីពិត ដែលគេរកឃើញដោយការចេញចូលតាមរយៈការពន្យល់ដោយរុករកយ៉ាងម្មត់ចត់និង ការដាក់អនុវត្តដោយមានទំនុកចិត្តនិងដោយក្លាហាន។ នេះជាវិធីសាស្ត្ររបស់អ្នក អធិប្បាយដ៏អស្ចារ្យ លោក Lloyd Jones ។ អ្នកអធិប្បាយអាចអនុវត្តតែអ្វីដែលគាត់ បានយល់ពីព្រះបន្ទូលរបស់ព្រះប៉ុណ្ណោះ។

# ជំពូក ៤

## របៀបបង្កើតខ្លឹមសារនៃការអធិប្បាយសម្រាប់គ្រូអធិប្បាយកម្ពុជា

រហូតមកដល់ពេលនេះ យើងបានគិតពីមហន្តរាយនៃការអធិប្បាយ ហើយយើងបានប្រតិកម្មលើបញ្ហានៃការបកប្រែបទគម្ពីរ ពេលនេះយើងគិតពីរបៀបបង្កើតខ្លឹមសារនៃការអធិប្បាយនៅលើគ្រឹះ។ អ្នកសរសេរបានទទួលកម្រិតបណ្ឌិតចេញពី Westminster Theological seminary នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដោយសិក្សាពីគោលការណ៍នៃការបន្សល់ការអធិប្បាយនិងជំហានទាំងដប់នៅក្នុងការបង្កើតវានៅ ឆ្នាំ ១៩៩៦ ហើយក្នុងកាលដែលខ្ញុំបម្រើនៅសាលា ITCS នៅក្នុងប្រទេសកម្ពុជា ខ្ញុំបានសរសេរអំពីការអធិប្បាយដែលស៊ីគ្នានៅឆ្នាំ ២០០១។ តាមរយៈសៀវភៅពីរនោះខ្ញុំនឹងប្រតិកម្មលើជំហានទាំង៦ដើម្បីនឹងបង្កើតខ្លឹមសារនៃការអធិប្បាយ។

1. ដំណាក់កាលទាំងប្រាំមួយនៅក្នុងការបង្កើតខ្លឹមសារនៃការអធិប្បាយ
   1) ភ្ជាប់ពេលនៃការសញ្ជឹងគិតទៅកាន់ខ្លឹមសារនៃការអធិប្បាយ

ពេលស្ងៀមស្ងាត់ ឬពេលសញ្ជឹងគិតនៅក្នុងលក្ខណៈនៃពួកជំនុំកូរ៉េត្រូវទទួលបានឥទ្ធិពលដោយក្រុមជំនុំផារ៉ា CCC, Navigator, SFC, UBF ជាដើម។ ទៅកាន់ក្រុមជំនុំបែបប្រពៃណី។ ពីព្រោះខ្ញុំបានរស់នៅក្នុងគ្រានោះ ខ្ញុំស្គាល់ពីដំណើរនោះយ៉ាងល្អ។ បន្ទាប់មកក្រុមជំនុំដែលមានចិត្តឆេះឆួលបានស្វែងរកដំណោះស្រាយសម្រាប់បំណងខាងវិញ្ញាណរបស់ពួកគេនៅក្នុងការអធិស្ឋានពេលព្រលឹមឡើង និងការអធិស្ឋាននៅក្នុងផ្ទះលើភ្នំ។ ដោយការលូតលាស់របស់ក្រុមជំនុំដែលបានរក្សាពេលស្ងៀមស្ងាត់នោះក្រុមជំនុំបានព្យាយាមអនុវត្តព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេ

បន្តិចម្តងៗ។ បន្ទាប់មកក្រុមជាច្រើនព្យាយាមនៅជាប់នឹងពេលវេលាស្មៀមស្ងាត់យ៉ាងច្បាស់លាស់។ ហើយក្រុមជំនុំបានទទួលកម្មវិធីដោយវិជ្ជមាន។ ទៅតាមបេសកកម្មព័ន្ធកិច្ចបានទទួលពួកគេជាកម្មវិធីចម្បងដើម្បីនឹងរក្សាជីវិតដែលកោតខ្លាចដល់ព្រះ។

បន្ទាប់មកព្រះគម្ពីរប្រចាំថ្ងៃដែលគម្ពីរបានរួបរួមត្រូវបានបោះពុម្ពនិងជីវិតដែលរស់នៅដែល Tyrannus បានបោះពុម្ពដែលផ្តោតលើជីវិតដែលស្ងៀមស្ងាត់នៅក្នុងក្រុមជំនុំកូរ៉េនៅក្នុងមជ្ឈមណ្ឌលនៃកម្រិតមហាវិទ្យាល័យ។ ពេលនេះគ្រីស្ទានដែលឆេះឆួលមួយចំនួនមានជីវិតដែលស្ងៀមស្ងាត់ជាគ្រឹះ។

នៅពេលដែលអ្នកនិពន្ធបម្រើក្រុមជំនុំនៅកូរ៉េខាងត្បូងនិងអាមេរិក ខ្ញុំបានសង្កត់ធ្ងន់ទៅលើការរក្សាជីវិតផ្ទាល់ខ្លួននៅក្នុងជីវិតរបស់ពួកគេអស់រយៈពេល៣០ឆ្នាំនៅក្នុងគ្រឹះនៃទស្សនៈរបស់កាល់វីន និងនៅក្នុងបេសកកម្មសម្រាប់បុគ្គលិកនិងក្រុមជំនុំ ពីព្រោះខ្ញុំជឿថាកាលដែលការនេះត្រូវបានអនុវត្តទៅកាន់ក្រុមជំនុំ ជាទូទៅផលប្រយោជន៍នឹងចេញពីការនោះមក។

ដូច្នេះគោលការណ៍នេះដែលខ្ញុំបានសង្កត់ធ្ងន់លើនៅក្នុងជំហានដំបូង ភ្ជាប់ជីវិតដែលស្ងៀមស្ងាត់របស់អ្នកទៅនឹងការអធិប្បាយ។ វាមានន័យថាជីវិតស្ងៀមស្ងាត់ផ្ទាល់ខ្លួនដែលគ្រូអធិប្បាយបានជ្រើសរើសអត្ថបទអធិប្បាយ ហើយប្រើទស្សនៈត្រីកោណ ការសង្កេត ការបកស្រាយ និងការអនុវត្ត ហើយចុងក្រោយគាត់រកឃើញអ្វីនៅថ្ងៃនេះ សេចក្តីពិតចម្បងចេញពីព្រះនៅក្នុងការដំណើរការនោះ។ ប្រៀបដូចជាគំនិតសំខាន់ ពាក្យនិងគោលគំនិតបានក្លាយទៅជាខ្លឹមសារអធិប្បាយ។ ហើយគាត់ក៏សរសេរគំនិតជា

ច្រើនដែលចេញមកពីការសញ្ជឹងគិតផ្ទាល់ខ្លួនសម្រាប់ជាសម្ភារៈនៅក្នុងការបង្កើតខ្លឹមសារនៃការអធិប្បាយ។

នៅក្នុងស្នាយនៃការបកស្រាយរបស់ខ្លឹមសារនៃការអធិប្បាយ ឬខ្លឹមសារនៃការអធិប្បាយបែបជាចំណងជើង ការអធិប្បាយគួរតែត្រូវបានពិចារណាដោយសេចក្តីពិតដែលដែលលេចមក ដែលគាត់បានរកឃើញចេញពីជីវិតដែលស្មៀមស្ងាត់។ ពីព្រោះយើងជឿថាតាមរយៈជីវិតដែលស្ងៀមស្ងាត់ដែលរឹងមាំ នោះខ្លឹមសារនៃការអធិប្បាយនឹងត្រូវបានបង្កើតឡើងជាពិតប្រាកដ។ ដូចដែលយើងចង់បង្កើតខ្លឹមសារនៃការអធិប្បាយដោយមានចំណងជើង នៅក្នុងការសញ្ជឹងគិតដែលទាក់ទងទៅនឹងចំណងជើងដែលយើងគិត នោះយើងនឹងរៀបចំនៅក្នុងអត្ថបទមួយដែលសមស្រប ហើយទៅកាន់ខ្លឹមសារនៃការអធិប្បាយ (សរុបសេចក្តី) តាមរយៈទស្សនៈនៃត្រីកោណ។ ការសង្កេត ការបកស្រាយ និងការអនុវត្ត។ វាជាច្រកដើម្បីរកឃើញសរុបសេចក្តីនៃខ្លឹមសារនៃការអធិប្បាយ ការអធិប្បាយរបស់លោក Jay Adams ជាមួយគោលបំណងដែលបង្ហាញពីសេចក្តីពិតយ៉ាងច្បាស់លាស់។ គាត់បានពន្យល់ពីផ្នែកដាក់អនុវត្តនិងភាពចាំបាច់នៃការអនុវត្តដែលក្រុមជំនុំបច្ចុប្បន្នជួបនៅក្នុងគោលការណ៍អធិប្បាយរបស់ពួកបរិសុទ្ធ។

2. ផ្តោតទៅលើខ្លឹមសារនៃការអធិប្បាយមួយដោយគ្រោងនៃត្រីកោណ

ជំហានបន្ទាប់នៅក្នុងការរៀបចំខ្លឹមសារនៃអត្ថបទ ជាការប្រើត្រីកោណដែលជា ទស្សនៈបិនៃការសង្កេត ការបកប្រែ និងការអនុវត្តដើម្បីយល់ពីអត្ថន័យនៃអត្ថបទឱ្យបាន

ច្បាស់លាស់។ វិធីសាស្រ្តទាំងបីនេះគួរតែបានប្រើដើម្បីនឹងប្រតិកម្មទៅលើអត្ថបទមួយឱ្យបានត្រឹមត្រូវ។

1) ទីមួយ ការសង្កេត –នេះជាការពិនិត្យលើអត្ថបទដោយមើលលើវេយ្យាករណ៍ ប្រវត្តិសាស្រ្ត និងការយល់ឃើញ។ បន្ទាប់មកយើងគួរតែអនុវត្តគោលការណ៍នៃការបកប្រែ។ យើងអាចប្រើគោលការណ៍ពីរនៃការបកប្រែ ដែលអះអាងដោយលោក Augustine ទាំងនោះជា ការបកប្រែគម្ពីរដោយគម្ពីរ ហើយបកប្រែគម្ពីរដោយគំនិតនៃគ្រប់បទគម្ពីរទាំងអស់ជាទូទៅ និងអាចបញ្ចូលគោលការណ៍នៃការបកប្រែរបស់លោក Vern Porthress នៅទីនេះ។ សំដៅទៅលើក្រាបនៃការបកប្រែនៅក្នុងសេចក្តីបន្ថែម។
ដើម្បីស្គាល់ពីខ្លឹមសារនៃអត្ថបទឱ្យបានច្បាស់ យើងគួរតែស្គាល់ពីអត្ថន័យនៃប្រយោគ ពាក្យ ការប្រើប្រាស់ អត្ថបទដែលស្រដៀងគ្នានៅក្នុងការប្រៀបធៀបការបកប្រែ។ ក្នុងកាលដែលយើងសង្កេតនូវខ្លឹមសាររួចមកដោយសំណួរគោលការណ៍ទាំងប្រាំមួយ (តើនរណា តើជាអ្វី តើនៅពេលណា ដោយរបៀបណា ដូច្នេះ) ទៅកាន់អត្ថបទដើម្បីនឹងស្វែងរកចម្លើយពិតប្រាកដ។ ពីព្រោះសំណួរល្អជាគន្លឹះនៅក្នុងការបកប្រែបទគម្ពីរ។
2) ទីពីរ ការបកប្រែនៅពេលយើងសង្កេតអត្ថបទជាក់ស្តែង យើងអាចស្វែងរកសេចក្តីពិតដោយឯកឯង ប៉ុន្តែយើងគួរតែប្រើតួនាទីនៃប្រាជ្ញាដោយប្រើសម្ភារៈមួយចំនួនតាមរយៈដំណើរការនៃការសិក្សាសេចក្តីពិត ដែលអាចជាបរិបូរណ៍នៅក្នុងការយល់ដឹងរបស់យើង។ នៅក្នុងកាលដែលយើងធ្វើកិច្ចការរបស់យើង ខ្ញុំសូមណែនាំផបសាយមួយចំនួននៅក្នុងអ៊ីនធឺណិត ដូចជា Hub

Biblos ជាដើម។ យើងរកឃើញការបកប្រែជាច្រើននិងការសិក្សាសភាពនៃពាក្យនីមួយៗតាមរយៈវចនានុក្រមជាច្រើននិងកម្រងពាក្យ។ ការបកប្រែបែបវេយ្យាករណ៍ដោយត្រង់ៗដូចនោះត្រូវការការសង្កេតពីដំណែងនៅក្នុងលំនាំនៃសេចក្ដីប្រោសលោះ និងការសួរសំណួរ ពីរបៀបដែលព្រះគ្រីស្ទត្រូវបានបង្ហាញនៅក្នុងអត្ថបទ និងដើម្បីស្វែងរកចម្លើយចេញពីបរិបទឬពីខ្លឹមសារ។ ឧទាហរណ៍ ចូរយើងបកប្រែ យ៉ូហាន 6:35។ យោងទៅតាមសំណួរនៃក្រាបបកប្រែ នោះយើងអាចស្វែងរកចម្លើយដែលស្មោះត្រង់ចេញពីពួកគេ។ "ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកគេ ខ្ញុំជានំបុ័ងជីវិត អ្នកដែលមកឯខ្ញុំនឹងមិនឃ្លានទៀតឡើយ ហើយអ្នកដែលជឿដល់ខ្ញុំនឹងមិនស្រេកទៀតឡើយ។"

(1) តើអ្វីទៅជាការដែលផ្ទុយគ្នាទៅកាន់អត្ថន័យនៃខនោះ? – ការផ្ទុយគ្នានៃនំបុ័ងជីវិតជានំបុ័ងនៃសេចក្ដីស្លាប់ ដែលជាលោកិយនិងអ្វីដែលលោកិយមាននិងសេចក្ដីលោភលន់របស់មនុស្ស។

(2) តើអ្វីជាចំណុចដែលសង្កត់ធ្ងន់លើនៃអត្ថន័យនោះ? – ព្រះគ្រីស្ទទ្រង់ជាជីវិត។

(3) តើការដូចគ្នានោះចេញមកពីណា? –ទឹករស់ ជាជីវិតអស់កល្បជានិច្ច។

(4) តើអ្វីទៅជាចរិតលក្ខណៈនៃខ្លឹមសារ? – វាជាពាក្យប្រៀបប្រដូចទៅនឹងការបកប្រែវា។

(5) តើអ្វីទៅជាចំណុចសំខាន់? – ព្រះយេស៊ូវទ្រង់ជាជីវិត។

(6) ទើអ្វីទៅជាតួនាទីនៃអត្ថបទនេះ? តាមរយៈព្រឹត្តិការណ៍នៃការប្រៀបធៀប គាត់បានសង្កត់ថាព្រះយេស៊ូវជាជីវិត។

(7) តើខនេះនិយាយពីធាតុដែលកត់ត្រាពីប្រវត្តិសាស្ត្រឬទេ? – នៅក្នុងព័ន្ធកិច្ចជាសាធារណៈរបស់ព្រះយេស៊ូវវាត្រូវបង្ហាញចេញមក។

(8) តើនៅក្នុងខនេះមាននិមិត្តរូបនិងប្រភេទដែរឬទេ? – ព្រឹត្តិការណ៍នំប៉័ងប្រាំដើម និងត្រីពីរ និងព្រឹត្តិការណ៍នំម៉ាន៉ានៅក្នុងវាលរហោស្ថានបង្ហាញពីនិមិត្តរូបនិងប្រភេទ និងធាតុពិតគឺជាព្រះគ្រីស្ទ។

(9) តើអ្វីទៅជាបរិបទនៃខនោះ? – បន្ទាប់ពីព្រះយេស៊ូវធ្វើឱ្យមានព្រឹត្តិការណ៍នំប៉័ងប្រាំដើមនិងត្រីពីរកន្ទុយ ហើយព្រះអម្ចាស់បានពន្យល់ពីការនោះ។

(10) តើប្រភេទអ្វីដែលខនេះមាន? – បែបជាការពន្យល់។

(11) តើប្រភេទនៃភាសាអ្វីដែលខនេះបានសរសេរចុះ? – នៅក្នុងការសន្ទនា។

(12) តើវាមានធាតុដែលនិយាយពីអារម្មណ៍ទេ? – មិនមាន។

(13) តើអ្វីទៅជាការបង្រៀនដែលខនេះផ្តល់ទៅកាន់ក្រុមជំនុំដើម? ខគម្ពីរត្រូវបានបង្ហាញថាព្រះយេស៊ូវជាព្រះមេស៊ី ដែលធ្វើឱ្យពួកគេជឿ ដោយការដក់ចេញនូវភាពមានពុតរបស់ពួកគេនិងទម្រង់ក្លែងក្លាយចេញ ហើយបានផ្តល់សេចក្តីជំនឿពិត។ ដោយមិនមានការសារភាពចំណេះដឹងពីព្រះគ្រីស្ទ នោះក៏គ្មានសេចក្តីសង្រ្គោះពិតដែរ។

(14) តើអ្នកណាខ្លះជាក្រុមជំនុំដើមនៅក្នុងខនេះ? – គ្រីស្ទានជាសាសន៍យូដា។

(15) តើអ្វីទៅជាជីវប្រវត្តិនៃខនេះ? – បន្ទាប់ពីព្រឹត្តិការណ៍នំប៉័ងប្រាំដើមនិងត្រីពីរកន្ទុយ ទ្រង់បង្រៀនពីអត្ថន័យពិតនៃព្រឹត្តិការណ៍ទៅកាន់ពួកសាវ័កនៅកន្លែងនោះ។

(16) តើអ្វីទៅជាជីវប្រវត្តិនៃប្រវត្តិសាស្ត្រនៃការប្រោសលោះនៃខនេះ? – ព្រះគ្រីស្ទជាអង្គដែលយាងមកនៅលើផែនដី ជាសេចក្តីពិតនៃសេចក្តីប្រោស

លោះដែលត្រូវបានពន្យល់ពីការនោះដោយពាក្យប្រៀបប្រដូចនិងព្រឹត្តិការណ៍មួយចំនួន។

(17) តើអ្វីទៅជាជីវប្រវត្តិនៃជីវិតនាពេលនេះ? – ជាពេលដែលមានភាពក្រីក្រ ដែលរងចាំព្រះមេស៊ីនៅក្នុងសង្គមដែលធ្វើកសិកម្មនិងមានសភាពខាងវិញ្ញាណវេទនាដោយសារភាពមានពុតរបស់អ្នកដឹកនាំខាងសាសនា។

បើទោះការលះបង់របស់យើងពីការបកប្រែខាងលើក៏ដោយ យើងបានរកឃើញចំណងជើងចម្បងនៅក្នុងនោះ។ នៅពេលសេចក្តីពិតសំខាន់មួយចំនួនត្រូវបានរកឃើញ នោះយើងត្រូវតែដាក់កំណត់ទៅកាន់ខ្លឹមសារនិងរៀបចំពាក្យ ខគម្ពីរជាដើមជាប្រយោគមួយ។ – នៅក្នុងអត្ថបទ ព្រះគ្រីស្ទជាជីវិត។ ព្រះគ្រីស្ទអះអាងទ្រង់ផ្ទាល់ថាជាជីវិត។

ទីបី ការដាក់អនុវត្ត។ ការនេះអាចជាធ្លាក់ចុះទៅក្នុងការអនុវត្តទៅកាន់ក្រុមជំនុំដែលជាថាក្រុមជំនុំជាកម្មវត្ថុនៃការអធិប្បាយ មិនមែនជាការអនុវត្តផ្ទាល់ខ្លួននៅក្នុងជីវិតនៃការសញ្ជឹងគិត។ ការសង្កេតខិតទៅកាន់ការបកស្រាយ ហើយការបកស្រាយទៅកាន់ការដាក់អនុវត្ត។ យើងគួរតែរៀបចំនៅក្នុងចន្លោះដែលជាសេចក្តីដែលយើងបានរកឃើញ សេចក្តីពិតដែលបានផ្តល់សេចក្តីពិតដ៏គួរឱ្យកោតសរសើរបំផុតដែលជា អ្វីដែលព្រះបានផ្តល់មកខ្ញុំនៅពេលនេះ។ ពេលមុននេះយើងដាក់អនុវត្តសេចក្តីពិតជីវិតស្ងៀមស្ងាត់ផ្ទាល់ខ្លួន ប៉ុន្តែពេលនេះយើងអាចដាក់អនុវត្តវាទៅកាន់ក្រុមជំនុំ។ បន្ទាប់មកយើងអាចដាក់កំណត់វាទុកជាសំណួរតៅកាន់សេចក្តីពិតមួយ។ យើងសួរសំណួរ "តើសេចក្តីពិតនិយាយអ្វីទៅកាន់ក្រុមជំនុំ?" ហើយយើងអាចឆ្លើយសំណួរហើយរៀបខ្លឹមសារក្នុងមួយប្រយោគ។

ឧទាហរណ៍ នៅពេលដែលយើងគិតអត្ថបទខាងលើជាបន្ត នោះអត្ថបទនិយាយថា មានតែព្រះគ្រីស្ទតែមួយប៉ុណ្ណោះដែលជាជីវិត តើអត្ថន័យជាក់ស្តែងអ្វីដែលខគម្ពីរផ្តល់ទៅកាន់ក្រុមជំនុំ? ខ្ញុំបានពន្យល់ពីព្រះយេស៊ូវជានរណាម្តងទៀត ហើយឱ្យព្រះយេស៊ូវជាចំណុចកណ្តាលរបស់ពួកគេ នៅក្នុងគំនិតរបស់ពួកគេនិងជីវិតរបស់ពួកគេ និងគ្រប់គ្រងពួកគេ។ (កាឡាទី 2:20)

ហើយនៅក្នុងបែបនៃ យ៉ូហាន 1:51ជណ្តើរនៅក្នុងអត្ថបទចង្អុលទៅកាន់ការអង្វរជំនួសរបស់ព្រះគ្រីស្ទ តើអត្ថន័យអ្វីដែលវាបានផ្តល់ដល់ក្រុមជំនុំ? វាមានន័យថា យើងអាចរីករាយគ្រប់ទាំងព្រះពរខាងវិញ្ញាណទាំងអស់ដែលព្រះបានរៀបចំនៅក្នុងស្ថានសួគ៌ ដោយការទំនាក់ទំនងតាមរយៈការអធិស្ឋាននិងការស្តាប់បង្គាប់។ ដូច្នេះក្រុមជំនុំអាចរីករាយនូវព្រះគុណដោយជីវិតនៃការអធិស្ឋានដោយស្មោះត្រង់តាមរយៈការអនុវត្តនៃការអង្វរជំនួសនៃកិច្ចការរបស់ព្រះគ្រីស្ទ។ យើងគួរតែរីករាយនូវព្រះគុណដើម្បីនឹងជួយនៅក្នុងពេលណាមួយដោយមានការចេញចូលនៅក្នុងព្រះគ្រីស្ទ។ (ហេព្រើរ 10:19-20)

នេះជាកិច្ចការដែលត្រូវអនុវត្តសេចក្តីពិតដែលរកឃើញតាមរយៈការបកប្រែទៅកាន់ការអធិប្បាយ។ និយាយឱ្យខ្លី ជាជំហានចុងក្រោយរបស់អ្នកអធិប្បាយ នោះជាការរៀបចំសេចក្តីពិតសម្រាប់ការអនុវត្តនៅក្នុងខ្លឹមសារនៃការអធិប្បាយ។ បន្ទាប់មក យើងគួរតែភ្ជាប់សេចក្តីពិតនេះទៅកាន់ខ្លឹមសារនៃការអធិប្បាយពិត។

តើអ្នកអធិប្បាយអនុវត្តចំណងជើងសំចម្បងនេះ "ព្រះគ្រីស្ទជាជីវិត" ទៅកាន់ក្រុមជំនុំបច្ចុប្បន្នដោយរបៀបណា? ព្រះគ្រីស្ទ ជានំប៉័ងជីវិតគួរតែត្រូវបានទទួលដោយផ្ទាល់ដូច

ជាការបរិភោគអាហារមួយចំនួន នោះពួកគេត្រូវមានការប្រកបដែលជ្រាលជ្រៅដោយការរួបរួមជាមួយព្រះគ្រីស្ទ។ ជីវិតជាព្រះយេស៊ូវគ្រីស្ទតែមួយប៉ុណ្ណោះ។

3. រៀបចំគោលបំណងនៃខ្លឹមសារអធិប្បាយ

មុនពេលយើងរៀបចំអត្ថបទនៃខ្លឹមសារការអធិប្បាយនិងអនុវត្តសេចក្តីពិតតាមរយៈការសង្កេត និងការបកប្រែគួរតែបានសម្រេចទៅកាន់គោលបំណងនៃសេចក្តីអធិប្បាយ។ គោលបំណងនៃការអធិប្បាយគួរតែត្រូវបានបង្កើតឡើងដោយការពន្យល់ Exegesus (ជាប្រភេទនៃការបកស្រាយដែលយល់ចេញពីអត្ថបទទៅកាន់ការខាងក្រៅ) ប៉ុន្តែការពន្យល់ Eiagesis (ជាប្រភេទនៃការបកស្រាយដែលគ្រប់គ្រងអត្ថបទដោយគោលគំនិតនិងគំនិតពីខាងក្រៅ) ដែលជាគ្រោះថ្នាក់ ពីព្រោះវាមិនអាចទំនាក់ទំនងទៅកាន់អត្ថន័យនៃអត្ថបទ ហើយអាចគ្រប់គ្រងលើអត្ថបទ។ នេះមិនមែនជាព្រះបន្ទូលរបស់ព្រះដែលអត្ថបទបានបង្ហាញនោះឡើយ។

ដូច្នេះគោលបំណងនៃខ្លឹមសារគួរតែបង្កើតឡើងនៅក្នុងប្រយោគមួយដែលច្បាស់ជាមួយនឹងប្រធាននិងកិរិយាសព្ទ។ វាជាកិច្ចការដែលទំនាក់ទំនងរវាងសេចក្តីពិតនិងបំណងរបស់ពួកជំនុំ ពីព្រោះនៅចំកណ្តាលនៃសេចក្តីអធិប្បាយ សេចក្តីពិតនេះនឹងត្រូវបានឆ្លើយតបដោយការអនុវត្តសេចក្តីពិតទៅកាន់សេចក្តីត្រូវការរបស់ពួកជំនុំ។ ដូច្នេះយើងត្រូវការពេលច្រើន។ ជួនកាល បន្ទាប់ពីយើងបង្កើតជំនួយនិងរៀបចំការដែលសរុបរួចហើយ ហើយធ្វើការកែសម្រួលវាដោយច្បាស់លាស់ ជាចុងក្រោយគោលបំណងនៃខ្លឹមសារអធិប្បាយនឹងត្រូវបានបង្កើតឡើង។ ពីព្រោះការសរុបនៃការអធិប្បាយជាគោលបំណងដែលអ្នកអធិប្បាយព្យាយាមដើម្បីទទួលបាននៅពេលនោះ

អ្នកអធិប្បាយបានផ្តល់ពេលច្រើនទៀតហើយដើម្បីនឹងពង្រឹង។ ដើម្បីនឹងសម្រេចការមួយនេះ យើងត្រូវការបង្កើតខ្លឹមសារអធិប្បាយជាចំណុចៗនិងជាចំនុចរាយរងផងដែរ។ ពួកគេអាចត្រូវបានបង្កើតនៅកំឡុងពេលនោះឬពេលថែមទៀត។ យោងទៅតាមបទពិសោធន៍របស់ខ្ញុំ សេចក្តីពិតដែលត្រូវបានអនុវត្តតាមរយៈការសញ្ជឹងគិត និងពេលស្មៀមស្ងាត់របស់ខ្ញុំបានក្លាយជាគោលបំណងនៃខ្លឹមសារអធិប្បាយរបស់ខ្ញុំនៅក្នុងស្ថានភាពជាច្រើនដោយឯកឯង។

សេចក្តីសរុបនៃការអធិប្បាយអាចជាមិនមែនជាសេចក្តីសរុបរបស់អត្ថបទនិងចំណងជើងអត្ថបទ។ វាត្រូវការចំណេះដឹងមួយចំនួន ដោយសារវានឹងត្រូវបានបង្កើតដោយការតភ្ជាប់ទៅកាន់ការចាំបាច់របស់ពួកជំនុំ។ ខ្ញុំអាចបង្កើតគោលបំណងបីពីខ្លឹមសារអធិប្បាយដោយចំណងជើងមួយដើម្បីនឹងបំពេញសេចក្តីត្រូវការរបស់ពួកជំនុំ។

(1) សេចក្តីសរុបនៃទំនួលខុសត្រូវដែលបានផ្តល់មក "អ្នកគួរតែធ្វើវា ពីព្រោះ..."
(2) សេចក្តីសរុបនៃទំនួលខុសត្រូវដែលបានផ្តល់មក "អ្នកអាចធ្វើអ្វីមួយដោយ..."
(3) សេចក្តីសរុបនៃតម្លៃដែលត្រូវបានផ្តល់មក៖ អ្នកគួរតែស្គាល់ថាការមួយនេះមានតម្លៃខ្លាំងជាងការមួយនោះ។

យោងតាមបទពិសោធន៍របស់អ្នកសរសេរ ប្រភេទនៃខ្លឹមសារអធិប្បាយនីមួយៗស្ទើរតែត្រូវបានគ្របដណ្តប់ដោយការផ្តល់គំនិតបីនោះ។ ប្រសិនបើវាមិនបានដើរតាមការណែនាំនោះទេ ខ្ញុំបានរកឃើញថាគោលបំណងនៃការអធិប្បាយធ្វើឱ្យការគិតរបស់ក្រុមជំនុំច្របូកច្របល់ ហើយប្តូរទៅជាបែបបទនៃការបង្រៀនមេរៀនវិញដែលធ្វើឱ្យបាត់បង់ភាពស្និតស្នេរ។ ការអធិប្បាយគួរតែចែកដាច់ពីការបង្រៀន។ ដូច្នេះសេចក្តី

សរុបនៃការអធិប្បាយគួរតែបង្កើតឡើងដោយបែបបទនៃការដាក់អនុវត្តសេចក្តីពិតដែលអាចផ្តល់ខ្លឹមសារទៅកាន់ការទាមទារដល់ក្រុមជំនុំ រាប់បញ្ចូលការទំនាក់ទំនងនៃព័ត៌មាន។ ចូរយើងគិតពីឧទាហរណ៍មួយ។

នៅក្នុងកាលដែលយើងបង្កើតខគម្ពីរខាងលើជាការផ្តល់គំនិត នោះយើងអាចនិយាយថា "អ្នកអាចធ្វើ...ដោយធ្វើការណាមួយ" "អ្នកគួរតែធ្វើ...ដោយសារការណាមួយ។" "អ្នកគួរតែនិយាយថាការណាមួយមានតម្លៃជាការណាមួយផ្សេងទៀត។"

(1) អ្នកអាចរួបរួមជាមួយនឹងព្រះគ្រីស្ទយ៉ាងជ្រាលជ្រៅដោយការស្តាប់បង្គាប់ព្រះបន្ទូលរបស់ទ្រង់។
(2) អ្នកគួរតែថ្វាយខ្លួនរបស់អ្នកទៅកាន់ព្រះគ្រីស្ទ ពីព្រោះទ្រង់ជាប្រភពនៃជីវិត។
(3) អ្នកគួរតែស្រឡាញ់ព្រះយេស៊ូវដែលទ្រង់ជាជីវិត ដែលប្រសើរជាងទ្រព្យសម្បត្តិលោកិយនេះ។

ឧទាហរណ៍មួយទៀត នៅពេលដែលយើងរៀបចំ យ៉ូហាន 3:16 ជាអត្ថបទនៃការអធិប្បាយ នោះយើងអាចបង្កើតដូចតទៅនេះ។ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់បានប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឱ្យអស់អ្នកណាដែលជឿដល់ទ្រង់ នោះមិនត្រូវវិនាសឡើយ តែនឹងមានជីវិតអស់កល្បជានិច្ចវិញ។"

ការសរុបនៃខ្លឹមសារអធិប្បាយៈ

(1) ការផ្តល់យោបល់ពីតួនាទីៈ អ្នកគួរតែស្រឡាញ់ព្រះអម្ចាស់ពីព្រោះ ១) សេចក្តីស្រឡាញ់របស់ព្រះវរបិតាមិនចេះបាត់បង់ឡើយ ២) សេចក្តីស្រឡាញ់នៃការ

ស្តាប់បង្គាប់របស់ព្រះរាជបុត្រា និង៣) សេចក្តីស្រឡាញ់នៃការអនុវត្តរបស់ព្រះវិញ្ញាណបរិសុទ្ធដែលធ្វើឱ្យអ្នកទទួលបានជីវិតអស់កល្បជានិច្ចដោយសេចក្តីជំនឿ។

(2) ការផ្តល់យោបល់ពីលទ្ធភាព៖ អ្នកអាចប្រកាសពីសេចក្តីស្រឡាញ់ទៅកាន់លោកិយដោយដឹងថា ១) សេចក្តីស្រឡាញ់របស់ព្រះវរបិតា ២) សេចក្តីស្រឡាញ់របស់ព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធ

(3) ការផ្តល់យោបល់ពីតម្លៃ៖ អ្នកគួរតែផ្សះផ្សារជាមួយនឹងសេចក្តីស្រឡាញ់របស់ព្រះ ១) សេចក្តីស្រឡាញ់ដែលឱបក្រសោប ២) សេចក្តីស្រឡាញ់ដែលសកម្ម និង ៣)ការសម្រេចសេចក្តីស្រឡាញ់ មានតម្លៃជាងសេចក្តីស្រឡាញ់របស់មនុស្ស។

សេចក្តីពន្យល់ – ការសញ្ជឹងគិតនៃខមួយហាក់បីដូចជាការអធិប្បាយមួយមានអត្ថបទដ៏វែង ពីព្រោះចំណងជើងនៃការសញ្ជឹងគិតពីអត្ថបទដែលវែងអាចសង្ខេបជាអត្ថបទដែលពិសេសមួយ។ ចេញពីអត្ថបទមួយ យើងអាចបង្កើតការផ្តល់យោបល់បី មានតួនាទី លទ្ធភាព និងតម្លៃ។ ការផ្តល់យោបល់ទាំងបីនេះមានទំនាក់ទំនងទៅកាន់ចំណងជើងទាំងអស់នៃគ្រប់ខ្លឹមសារអធិប្បាយទាំងអស់។

យោងតាមបទពិសោធន៍របស់ខ្ញុំ ទីមួយ នៅពេលដែលខ្ញុំរៀបចំការផ្តល់យោបល់របស់ខ្ញុំ ខ្ញុំមានគោលបំណងចាប់ផ្តើមជាមួយនឹងពាក្យ "អ្នក" វាជាការដើរតាមទស្សនៈរបស់លោក Jay Adams ។ គាត់អះអាងថាដោយការរៀបចំបែបនេះការអធិប្បាយរបស់យើងអាចផ្លាស់ប្តូរទៅជាបែបនៃការបង្រៀនចេញពីខ្លឹមសារនៃការអធិប្បាយ ឬបែបជាការអធិប្បាយទៅជាការបង្រៀន។ ហេតុផលដែលត្រូវមាន

ប្រភេទជាការបង្រៀនច្រើនចេញពីសរុបសេចក្តីរបស់ការអធិប្បាយនោះគឺ វាមិនមានបែបបទដែលមុត។ ក្នុងកាលដែលយើងនិយាយ "អ្នក" ជាកម្មវត្ថុនៃការអធិប្បាយយ៉ាងរឹងមាំ ការផ្តល់យោបល់អាចត្រូវបានបង្កើតដោយមុតមាំ។

ការផ្តល់យោបល់ពីតួនាទីធ្វើឱ្យយើងមកដល់ការសរុបនៃការអធិប្បាយដោយការផ្តល់បន្ទុកពីព្រះ។ ដូច្នេះវាគួរតែត្រូវបានបង្កើតឡើងជាប្រភេទនៃ ដូច្នេះគួរតែធ្វើវាពីព្រោះការណាមួយ។ ហើយចំណុចដែលថាដោយសារនោះត្រូវតែទាញចេញពីអត្ថបទផ្ទាល់។ ខ្ញុំទាញចេញមក ១) ពីព្រោះសេចក្តីស្រឡាញ់របស់ព្រះវរបិតាចេញមក "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក" វាមិនមែនជាសេចក្តីស្រឡាញ់ដែលត្រូវបានពិភាក្សាការណាមួយនោះឡើយ កាលដែលយើងជាមនុស្សមានបាប ព្រះទ្រង់បានស្រឡាញ់យើងដោយមិនបានពិភាក្សាគំនិតអ្វីឡើយ។ វាបង្ហាញពីសេចក្តីស្រឡាញ់ដើមរបស់ព្រះ។ ហើយហេតុផលទីពីរជាសេចក្តីស្រឡាញ់នៃការស្តាប់បង្គាប់របស់ព្រះរាជបុត្រា។ ព្រះរាជបុត្រាបានធ្វើការយ៉ាងពេញលេញទៅតាមការទាមទាររបស់ព្រះវរបិតា។ ដូច្នេះទ្រង់បានក្លាយជាមួយអង្គនិងបានស្រឡាញ់ព្រះវរបិតាដោយការស្តាប់បង្គាប់និងរាស្ត្ររបស់ទ្រង់ផ្ទាល់ជាមួយការលះបង់របស់ទ្រង់។ វាជាសេចក្តីស្រឡាញ់ដែលបានប្តូរជាមួយអំពើបាបរបស់ពួកគេ។ ទីបី សកម្មភាពនៃសេចក្តីស្រឡាញ់របស់ព្រះវិញ្ញាណបរិសុទ្ធបង្ហាញថា ទ្រង់បានធ្វើឱ្យមនុស្សម្នាក់ជឿនៅក្នុងសេចក្តីស្រឡាញ់ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច។ តាមរយៈដំណើរការនៃការផ្សះផ្សារផ្ទាល់និងការបកប្រែ នោះយើងអាចធ្វើការផ្តល់យោបល់ដោយគោលការណ៍នេះ។

ហើយការផ្តល់យោបល់ពីការដែលអាចធ្វើបានត្រូវបានបង្កើតឡើងដោយគោល បំណងដើម្បីនឹងកំសាន្តចិត្តដល់ក្រុមជំនុំនិងលើកទឹកចិត្តពួកគេ។ ទម្រង់នេះគឺ ដើម្បីក្លាយជាទម្រង់មួយ "ដោយធ្វើអ្វីម៉្យាង នោះអ្នកអាចធ្វើបាន"។ អត្ថបទ និយាយថា "ខ្ញុំ..." បីដង។ នៅទីនេះ យើងអាចបង្កើតអ្វីមួយដោយដឹងពីសេចក្តី ស្រឡាញ់របស់ព្រះវរបិតា សេចក្តីស្រឡាញ់របស់ព្រះរាជបុត្រា និងសេចក្តី ស្រឡាញ់របស់ព្រះវិញ្ញាណ។ ការពិតណាស់យើងគួរតែប្រាកដថាសេចក្តី ស្រឡាញ់ទាំងបីសុទ្ធតែចេញមកពីអត្ថបទ។ កាលដែលយើងមិនអាចរកឃើញ នោះយើងគួរតែបញ្ជាក់ឱ្យបានច្បាស់តាមរយៈការទាញយកពីបទគម្ពីរដែលស្រ ដៀងគ្នានោះ។ នៅទីនេះ យើងអាចឆ្លើយតបដោយវិជ្ជមានដោយការយល់ពីសេច ក្តីស្រឡាញ់របស់ព្រះវរបិតានិងសេចក្តីស្រឡាញ់នៃការអនុវត្តដោយព្រះវិញ្ញាណ យើងអាចឆ្លើយតបដោយវិជ្ជមានទៅកាន់ព្រះ។

4. ធ្វើឱ្យគ្រោងអធិប្បាយក្លាយជាអនុមានរួម

បន្ទាប់ពីគ្រូអធិប្បាយបង្កើតគ្រោងខ្លឹមសារនៃការអធិប្បាយរួចមក។ យោងទៅតាម វិធីសាស្ត្ររបស់លោក អារីស្តូត និង លោក រ៉ាម៉ុស ដើម្បីនឹងទៅដល់គោលបំណង នៃការអធិប្បាយ គាត់អាចបង្កើតចំណុចនិងចំណុចតូចៗនៅចំកណ្តាលនៃការ សរុបសេចក្តីរបស់ការអធិប្បាយ។ វានឹងត្រូវបានបង្កើតបែបជាអនុមានរួម។ កាល ដែលយើងបង្កើតវាបែបជាអនុមានរួម គាត់អាចជាធ្លាក់ចុះទៅក្នុងសេចក្តីល្បួង ក្លែងក្លាយ ប៉ុន្តែបែបអនុមានរួមនឹងជួយបង្កើតចំណុចដែលចេញមកពីគម្ពីរ។ វិធី សាស្ត្រក្លែងក្លាយនៃការបង្ហាញឧទាហរណ៍និងការវែកញែកនឹងមិនមាន ប្រយោជន៍ប៉ុន្តែអាចជានាំឱ្យមានបញ្ហាថែមទៀតផងនៅក្នុងការយល់សេចក្តីពិត

នៅក្នុងចិត្តរបស់ក្រុមជំនុំ។ ប្រសិនបើគាត់ចង់បង្កើតចំណុចពីរ ការអធិប្បាយគួរតែត្រូវបានរៀបចំដោយគ្រូអធិប្បាយ ដែលគាត់ធ្វើឱ្យក្រុមជំនុំរបស់គាត់យល់ពីខ្លឹមសារដោយការប្រើប្រាស់ពាក្យ។ ចំនុចៗគួរតែជំនួយដល់សេចក្ដីសរុបរបស់ការអធិប្បាយនិងពង្រឹងវាផងដែរ។ ហើយគ្រោងមានការពន្យល់និងការដាក់អនុវត្ត ឬការពន្យល់ពីធាតុនានានិងធាតុដែលត្រូវដាក់អនុវត្ត។ អ្នកអធិប្បាយបកប្រែពាក្យសំខាន់ៗនិងអត្ថបទ និងធ្វើឱ្យចំណុចតូចៗអនុវត្តពួកគេទៅក្នុងស្ថានភាពពិតប្រាកដនិងពង្រឹងវា។ ដូច្នេះដោយសារចំណុចទៅកាន់គោលបំណង នោះគេអាចរៀបចំចំណុចដែលរឹងមាំ ឬធ្វើឱ្យខ្សោយអំពីខ្លឹមសារនិងបន្ទាប់មកជាចុងក្រោយគាត់គួរតែធ្វើឱ្យគោលបំណងបានមកដល់ទៅដល់ចិត្តរបស់ក្រុមជំនុំ។

អ្នកអធិប្បាយលោក Jung Am Yun Sun Park ដែលក្រុមជំនុំកូរ៉េមានបានផ្ដល់និយមន័យថាការអធិប្បាយប្រៀបដូចជាការដំដែកគោលនៅលើក្ដារបន្ទះបានយ៉ាងល្អដូច្នេះដែរ។ ក្នុងកាលដែលលោកបម្រើនៅក្នុងសាលា នៅក្នុងពេលមានវិបត្តិនៃការបែងចែកសាលា Chong Sin Theological Seminary គាត់បានអធិប្បាយព្រះបន្ទូលរបស់ព្រះទៅកាន់សិស្សៗនិងសាស្ត្រាចារ្យនៅក្នុងកន្លែងថ្វាយបង្គំដើម្បីនឹងលើកទឹកចិត្តដល់ពួកគេ ដើម្បីធ្វើឱ្យពួកគេស្គាល់ពីសេចក្ដីពិត។ បន្ទាប់មកខ្ញុំមានការកោតសរសើរដោយការអធិប្បាយដោយស្មោះត្រង់យ៉ាងខ្លាំងហើយសម្រាប់ពេលសិក្សាអស់រយៈពេលពីរឆ្នាំនៅសាលា Hapdong Theological Seminary ខ្ញុំបានទទួលព្រះគុណយ៉ាងអស្ចារ្យពីការអធិប្បាយរបស់គាត់នៅពេលនោះឯង។ ការអធិប្បាយរបស់គាត់បានជះការផ្លាស់ប្រែយ៉ាងសន្ធោរសន្ធៅទៅក្នុងចិត្តរបស់មនុស្សនៅសាលាទាំងអស់។ ហេតុផលនោះគឺ

ដើម្បីនឹងប្រតិកម្មទៅលើបទគម្ពីរពិតប្រាកដ ជាក់ស្តែងដើម្បីនឹងទំនាក់ទំនងការយល់ដឹងរបស់គាត់ទៅកាន់ចិត្តរបស់យើងដោយសាកសម ដូចជាគាត់បានទទួលអំណោយណាមួយចេញមកពីព្រះ។ ដូច្នេះខ្ញុំបានវាយតម្លៃថា គាត់ជាអ្នកបម្រើនៃព្រះបន្ទូល ដែលស្រឡាញ់ព្រលឹងរបស់ពួកជំនុំយ៉ាងជ្រាលជ្រៅ ពីព្រោះគំនិតរបស់គាត់មានបែបពួកកាល់វីននិងគំនិតបែបពួកកំណែទម្រង់បរិសុទ្ធ។ គាត់ស្រឡាញ់ពីទស្សនៈនៃបទគម្ពីររបស់លោក Herman Bavinck ហើយជឿចរិតលក្ខណៈជីវិតនៃបទគម្ពីរ។ ហើយក្នុងកាលដែលគាត់រស់នៅដូចជាបទគម្ពីរការអធិប្បាយរបស់គាត់បានផ្តល់ការកោតសរសើរមកលើយើងយ៉ាងខ្លាំង។ គាត់តែងតែប្រព្រឹត្តលើបញ្ហាខាងសាច់ឈាមយ៉ាងខ្លាំងនៅក្នុងការអធិប្បាយរបស់គាត់។ គាត់បានវាយប្រហារជានិច្ចលើខ្លួនរបស់គាត់ផ្ទាល់នៅក្នុងការអធិប្បាយរបស់គាត់ ហើយបង្ហាញពីគោលបំណងដែលដើរតាមពេលស្ងៀមស្ងាត់នៃអ្នកអធិប្បាយបរិសុទ្ធជាអ្នកពូកែខាងព្រលឹងវិញ្ញាណ។ ខ្ញុំបានរកឃើញថារូបឆ្លុះរបស់ខ្លួនរបស់គ្រូអធិប្បាយ លោក Dr. Yun Sun Park និងការអះអាងថា គាត់ជាអ្នកកំណែទម្រង់បរិសុទ្ធនោះ ពីព្រោះគាត់បានបង្ហាញពីរូបភាពនៃអ្នកអធិប្បាយនៃពួកបរិសុទ្ធដែលបានរស់នៅជីវិតនៃលទ្ធិរបស់លោកកាល់វីននៅក្នុងសតវត្សរ៍ទី ១៦ និង១៧។

នៅក្នុងឆ្នាំទីបីនៅក្នុងសាលាគម្ពីររបស់ដែលខ្ញុំរៀន គាត់បានចូលទៅក្នុងថ្នាក់ជាមួយសៀវភៅប្រវត្តិចំនួនពីរក្បាលរបស់ លោក Fox's Martyr ហើយបានស្រែកថា "ក្រុមជំនុំកូរ៉េគួរតែរៀនប្រវត្តិសាស្ត្រនៃឈាមនេះ" ហើយបានសួរនរណាជាអ្នកបកប្រែសៀវភៅពីរនោះជាភាសាកូរ៉េ ខ្ញុំបានស្តាប់ទៅកានការប្រកាសរបស់

គាត់យ៉ាងយកចិត្តទុកដាក់ ហើយបង្កើតក្រុមបកប្រែនិងធ្វើការកូពីសៀវភៅ ក្នុងកាលដែលខ្ញុំបានចេញទៅប្រទេសអាមេរិក។ វាបញ្ជាក់ថា លោក Jung Am ជាអ្នកអធិប្បាយដែលចង់បានកិច្ចការនៅក្នុងជីវិតនៅក្នុងក្រុមជំនុំ។

ចំណុចគួរតែជាទីតាំងដែលមានទំនាក់ទំនងទៅនឹងសេចក្តីបញ្ចប់នៃការអធិប្បាយ។ ក្នុងកាលដែលគាត់បង្កើតចំណុចពីរ ឬបីសម្រាប់ការអធិប្បាយ នោះគាត់គួរតែបង្កើតចំណុចតូចៗដើម្បីនឹងពង្រឹងសេចក្តីសរុបនៃការអធិប្បាយរបស់គាត់ផងដែរ។ ចំណុចត្រូវការការប្រើប្រាស់ពាក្យដែលជាការដំណើរការលូតលាស់ ប្រភេទដែលលូតបន្តិចម្តងៗ។ ការដែលសំខាន់ជាងនោះជាចំណុចនីមួយគួរតែចេញមកពីអត្ថបទខ្លួនឯងតែម្តង។

ឧទាហរណ៍ នៅពេលដែលយើងបង្កើតចំណុចជាមួយ យ៉ូហាន 3:16 យើងអាចបង្កើតសំណួរ "តើយើងអាចរីករាយនឹងសេចក្តីស្រឡាញ់ដោយរបៀបណា?" ហើយអាចផ្តល់ចម្លើយដែលស្មោះត្រង់មួយចំនួនទៅកាន់សំណួរនោះ។

ចំណុចតូចៗគួរតែបង្កើតឡើងដើម្បីនឹងពង្រឹងចំណុចទាំងនោះ។ វាគួរតែត្រូវបានបង្កើតមកពីធាតុពីរ ការពន្យល់និងការអនុវត្ត។ ការពន្យល់ជាការបកស្រាយអត្ថបទនិងបន្ទាប់មកផ្ញុំការបញ្ជាក់វាដោយផ្ទាល់ គេគួរតែអនុវត្តការទាំងនោះទៅកាន់ក្រុមជំនុំ។ គេអាចដឹកនាំទៅកាន់ការឆ្លើយតបដូចជាប្រភេទនៃសំណួរ ឬដោយការសង្ខេបការទាំងនោះ គាត់អាចសង្កត់ធ្ងន់លើអ្វីដែលពួកគេអាចធ្វើបាន។ គោលបំណងជាការបញ្ចុះបញ្ចូលក្រុមជំនុំនិងការយល់របស់គាត់និងការឆ្លើយតបរបស់ពួកគេ។

ចូរយើងផ្ដល់ឧទាហរណ៍មួយចំនួន។

5. តភ្ជាប់ការវែកញែកដែលសមស្រុបនិងឧទាហរណ៍នៅក្នុងខ្លឹមសារអធិប្បាយ

ហើយដើម្បីនឹងពង្រឹងគោលបំណង យើងអាចបញ្ចូលឧទាហរណ៍និងការវែកញែកនានាផងដែរ។ ប៉ុន្តែការនេះមិនគួរដើរមុនការបង្រៀនពីអត្ថបទនោះឡើយ។ គ្រប់ទាំងឧទាហរណ៍ទាំងអស់និងការវែកញែកទាំងអស់មានទំនាក់ទំនង ប៉ុន្តែមិនអាចទៅមុនបទគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះនោះឡើយ។

នៅពេលដែលយើងប្រាកដពីការវែកញែក ចំណុចនីមួយៗ និងចំណុចតូចៗ នោះយើងជួបនូវចំណាងជើងដើម្បីនឹងដោះស្រាយតាមរយៈការជជែកវែកញែក។ គ្រប់ពេលទាំងអស់យើងគួរតែបង្ហាញពីការជជែកវែកញែកតាមបទគម្ពីរ។ ដូចជាលោក John Frame បាននិយាយថា ការជជែកវែកញែករបស់យើងមានផ្ទុកការការពារ ការពន្យល់និងការវាយប្រហារ ប៉ុន្តែវាកាន់តែប្រសើរនៅក្នុងការជ្រើសយកប្រភេទនៃការពន្យល់។ ហើយយើងអាចដោះស្រាយបញ្ហានេះដោយការបង្ហាញពីឧទាហរណ៍ដូចជាការគូររូប។ នៅក្នុងកំឡុងពេលព័ន្ធកិច្ចដ៏រវល់របស់ខ្ញុំនៅសហរដ្ឋអាមេរិក ខ្ញុំបានបង្កើតការកូពីនៃឧទាហរណ៍ចេញពីជីវិតរស់នៅដែលត្រូវបានបោះពុម្ពនៅរោងពុម្ព Tyrannus press ហើយត្រូវបានប្រើប្រាស់ការទាំងនោះនៅគ្រប់ចំណងជើងទាំងអស់នៅក្នុងការអធិប្បាយរបស់ខ្ញុំយ៉ាងសមរម្យ។ ការផ្ដល់ឧទាហរណ៍នេះពង្រឹងដល់ចំណុចនានានិងចំណុចតូចៗជានិច្ច ដើម្បីនឹងបញ្ចុះបញ្ចូលពួកជំនុំ យើងគួរតែអនុវត្តការទាំងនោះទៅកាន់ចំណងជើងរបស់យើងឱ្យ

បានមុតមាំ ហើយគួរតែដើរតួជាអ្នកបម្រើ ប៉ុន្តែវាមិនគួរគ្រប់គ្រងការទាំងនោះទ្បើយ វាជាការនេះ ឬការនោះ។

6. បញ្ចូលសេចក្តីបញ្ចប់និងសេចក្តីផ្តើមនៃខ្លឹមសារអធិប្បាយ

បន្ទាប់ពីយើងបានសម្រេចខ្លួនរបស់ការអធិប្បាយរួចមក ពេលនេះយើងរៀបចំសេចក្តីបញ្ចប់របស់ការអធិប្បាយ ដែលគោលបំណងគួរតែត្រូវបានបង្ហាញច្បាស់និងបន្ថែមការផ្តើមដែលជាចំណុចតភ្ជាប់រវាងអ្នកអធិប្បាយនិងក្រុមជំនុំដើម្បីឱ្យការអធិប្បាយមានភាពពេញលេញ។ អ្នកអធិប្បាយគួរតែបង្កើតខ្លឹមសារដែលមានការអនុវត្ត ដើម្បីផ្តោតលើការលូតលាស់នៃក្រុមជំនុំ។ នៅក្នុងកាលដែលគាត់ព្យាយាមបង្កើតខ្លឹមសារអធិប្បាយដែលមានការអនុវត្តចេញពីបែបបទនៃការបង្រៀន នោះសរុបសេចក្តីនឹងត្រូវបានមុតថែមទៀត។ ដូច្នេះ គាត់ត្រូវតែមានបន្ទុកខាងវិញ្ញាណដើម្បីនឹងបង្កើតក្រុមជំនុំឱ្យស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ ដោយប្រកាសវាទៅកាន់អ្នក ដែលជាផ្នែករបស់ក្រុមជំនុំ។

ហើយយើងគួរតែបញ្ចប់ការអធិប្បាយបង្កើតដោយបន្ថែមការសរុបសេចក្តីនិងសេចក្តីណែនាំ។ បន្ទាប់មកយើងប្រតិកម្មទៅលើការសរុបសេចក្តី ពីព្រោះវាគួរតែត្រូវបានបង្ហាញនូវសរុបសេចក្តីនៃការអធិប្បាយ។ បន្ទាប់មកសេចក្តីណែនាំត្រូវការប្រាជ្ញាថែមទៀត ពីព្រោះសេចក្តីណែនាំនេះរាប់បញ្ចូលចំណុចទាក់ទងរវាងអ្នកអធិប្បាយនិងក្រុមជំនុំ។ វាសំខាន់ណាស់នៅក្នុងការបំពេញសេចក្តីត្រូវការរបស់ក្រុមជំនុំ វាគួរតែបាននាំយកនូវអត្ថបទនៃការអធិប្បាយចេញមក។ បើទោះជាអ្នកផ្សេងទៀតមិនសរសេរចុះពេញក៏ដោយ អ្នកខ្លះសរសេរចុះនូវសេចក្តីណែនាំយ៉ាង

ពេញលេញ ហើយបានមកកាន់ទីអធិប្បាយ។ ប្រៀបដូចជាការមួយនេះដែរ ខ្លឹមសារអធិប្បាយត្រូវបានរៀបចំទំនាក់ទំនងដូចជាល្មោននិងអាហារដែលរៀបចំរួចជាស្រេច។

បន្ទាប់មកអ្នកអធិប្បាយគួរតែរងចាំការចាក់ប្រេងតាំងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អ្នកអធិប្បាយសង្កេតពីអត្ថបទដែលត្រូវបានបណ្ដាលដោយអ្នកដឹកនាំដែលទទួលបានពីព្រះវិញ្ញាណបរិសុទ្ធ និងចូលទៅកាន់គោលបំណងនៃការលូតលាស់នៃវិញ្ញាណដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយគាត់ទាមទារការស្វែងរកព្រះគុណរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ប្រៀបដូចជាលោក អេលីយ៉ា ដែលបានទាស់នឹងហោរាក្លែងក្លាយនៅភ្នំកាមែលដោយទាមទារឱ្យបញ្ចេះអាសនាដើម្បីនឹងបញ្ជាក់ថាគាត់ជាអ្នកបម្រើពិត គាត់បានស្ដាប់បង្គាប់ការបញ្ជានិងព្រះរបស់គាត់មានតែព្រះយេហូវ៉ាប៉ុណ្ណោះ អ្នកអធិប្បាយត្រូវតែមានចិត្តដែលត្រូវការ ការលូតលាស់យ៉ាងឆេះឆួលនៅក្នុងចិត្តរបស់គាត់និងបានជះភ្លើងទៅដល់ពួកជំនុំនៅក្នុងការអធិប្បាយ។

នៅពេលដែលយើងអានពីកំណត់ហេតុប្រចាំថ្ងៃរបស់លោក Brainerid និង Whitefield យើងឃើញអត្តចរិតត្រឹមត្រូវពីរយ៉ាងរបស់អ្នកអធិប្បាយ។ លោក Brainerid បានលត់ជង្គង់ចុះនៅក្នុងព្រៃនៅក្នុងគ្រាលំបាករបស់គាត់ ហើយអធិស្ឋានដោយស្មោះត្រង់ទៅកាន់ព្រះអម្ចាស់ នៅតាមផ្លូវដើរទៅកាន់កុលសម្ព័ន្ធក្រហមរបស់អាមេរិក ឥណ្ឌាដើម្បីប្រកាសដំណឹងល្អ។ ហើយអ្នកអធិប្បាយ លោក Whitefield មិនបានចូលទៅកាន់ទីអធិប្បាយទាល់តែលោកមានអារម្មណ៍ពីសភាពដែលត្រូវបានចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែល

គាត់អធិប្បាយព្រះបន្ទូលរបស់ព្រះ ព្រះវិញ្ញាណបរិសុទ្ធឆេះឆួលចិត្តនៃក្រុមជំនុំរបស់គាត់ដោយប្រើការអធិប្បាយរបស់គាត់។

អ្នកអធិប្បាយ លោក Hak Kun Kang ដែលជាអ្នកបង្រៀនខ្ញុំដែលខ្ញុំបានស្គាល់នៅក្នុងព័ន្ធកិច្ចជាគ្រូគង្វាលរបស់ខ្ញុំ ជាអ្នកអធិប្បាយម្នាក់ដែលមានលក្ខណៈពិសេស ពីព្រោះគាត់បានរៀបចំការអធិប្បាយមួយនៅក្នុងការអធិស្ឋានយ៉ាងខ្លាំងក្លានិងការសញ្ជឹងគិតជាច្រើន។ ជួនកាលបន្ទាប់ពីគាត់បានអធិស្ឋានជាច្រើនសម្រាប់ការអធិប្បាយ នៅពេលដែលគាត់ក្រោកឈរនៅទីអធិប្បាយ គាត់មានអារម្មណ៍ពីបរិយាកាសដែលពេញដោយព្រះគុណនៅក្នុងការអធិប្បាយនិងអាចនិយាយពាក្យដែលមិនអាចវាល់បានចេញពីគំនិតរបស់គាត់នៅក្នុងកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ហើយនៅពេលដែលខ្ញុំស្តាប់ទៅកាន់ការអធិប្បាយរបស់គាត់នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាបានទទួលនូវភ្លើងដែលឆាបឆេះចេញពីចិត្តរបស់គាត់មក។ គាត់ជាអ្នកអធិប្បាយដែលស្មោះត្រង់សម្រាប់ដំណឹងល្អនៅក្នុងព័ន្ធកិច្ចរបស់គ្រូគង្វាល។ ជាចុងបញ្ចប់ ការអធិប្បាយត្រូវការប្រើភាសារបស់គ្រូអធិប្បាយ ដែលជាអត្តចរិករបស់គាត់និងការយល់ដឹងរបស់គាត់ ប៉ុន្តែវាត្រូវបានសម្រេចបំពេញដោយកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះព្រះវិញ្ញាណបរិសុទ្ធជាវិញ្ញាណនៃគ្រូអធិប្បាយនិងជាវិញ្ញាណនៃការអនុវត្តនៅក្នុងការអធិប្បាយ។

នៅក្នុងព័ន្ធកិច្ចជាទីស្រឡាញ់នៅក្នុងកម្ពុជារបស់ខ្ញុំ តើមានគ្រូអធិប្បាយប៉ុន្មានដែលបានបង្ហាញរូបរាងជាគ្រូអធិប្បាយនោះ? បើទោះជាមានរូបរាងក្លែងក្លាយមួយចំនួនត្រូវបានបង្ហាញមកនៅក្នុងព័ន្ធកិច្ច តើពួកគេពិតជាមានការផ្លាស់ប្រែដែលឆេះឆួលនៃការអធិប្បាយនៅក្នុងចិត្តរបស់ពួកគេទេ? ដូចជានៅថ្ងៃមួយ ពេល

ដែលខ្ញុំសួរសុខទុក្ខក្រុមជំនុំមួយនៅក្នុងថ្ងៃព្រះអម្ចាស់នៅតាកែវ គ្រូអធិប្បាយបានផ្គុំដៃរបស់គាត់ទាំងពីរហើយអធិស្ឋានការអ្វីមួយដោយសម្លេងតូចទៅតាមកញ្ចក់វីដេអូ។ បើទោះជាវាមានរូបរាងបែបដូចជាពេលស្ងៀមស្ងាត់ ខ្ញុំនៅតែសង្ស័យពីកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការនោះណាស់។ ពួកគេបានយល់ច្រលំពីអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ។ បន្ទាប់មកខ្ញុំមានអារម្មណ៍ថា គ្រីស្ទានត្រូវបានផ្លាស់ប្តូរទៅជាពួកជំនុំរ៉ូម៉ាំងកាតូលិក។ វាគ្រោះថ្នាក់ណាស់។ មានតែកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធប៉ុន្តែ ទើបការអធិប្បាយអាចមកដល់គោលបំណងបាន។

7. វាយតម្លៃការអធិប្បាយផ្ទាល់ខ្លួនដើម្បីអភិវឌ្ឍការអធិប្បាយ

បន្ទាប់ពីគាត់បានបញ្ចប់ខ្លឹមសារអធិប្បាយរបស់គាត់ នោះគាត់អាចពិនិត្យខ្លួនរបស់គាត់សម្រាប់ការវាយតម្លៃរបស់គាត់។ ពីព្រោះការអធិប្បាយជាព័ន្ធកិច្ចដែលត្រូវបានត្រាស់ហៅដោយព្រះជាម្ចាស់ ហើយព្រះជាម្ចាស់ជាអ្នកដែលបង្កើតនៅក្នុងក្រុមជំនុំរបស់ទ្រង់។ គាត់គួរតែព្យាយាមត្រួតពិនិត្យខ្លឹមសារអធិប្បាយរបស់គាត់ ហើយវាយតម្លៃការអធិប្បាយនោះដោយមុតមាំពីចំណុចដែលខ្លាំងនិងចំណុចដែលខ្សោយ។ ជួនកាលខ្លឹមសារអធិប្បាយរបស់គាត់ត្រូវការការវាយតម្លៃដោយចាស់ទុំនិងប្រពន្ធរបស់គ្រូគង្វាល។

លើសពីនោះទាំងអស់ការកែប្រែនេះមានទំនាក់ទំនងទៅនឹងការសញ្ជឹងគិតព្រះបន្ទូលរបស់ព្រះតាមរយៈជីវិតដែលស្ងៀមស្ងាត់។ គាត់អាចអធិប្បាយទៅតាមរបៀបរៀបរយនៃបទគម្ពីរ ហើយអាចរៀបចំវាទៅតាមអត្ថបទដែលពេញលេញនៅលើចំណាងជើងនៃការអធិប្បាយរបស់គាត់ ហើយគាត់អាចជាបង្កើតជាបែបជាស៊េ

រីនិងចំណងជើងពិសេសដែលចេញមកពីអត្ថបទដែលអាចនឹងអធិប្បាយដោយលំនាំនៃអត្ថបទ។ ខ្ញុំមានបទពិសោធន៍មួយចំនួនដែលខ្ញុំបានអធិប្បាយសៀវភៅទាំងមូលនៅក្នុងបទគម្ពីរនៅក្នុងកណ្ឌគម្ពីរមួយ។ វាមានទំនាក់ទំនងទៅនឹងបទពិសោធន៍ដែលខ្ញុំបានរៀបចំការអធិប្បាយបែបគ្រួសារសម្រាប់គ្រីស្ទានជារៀងរាល់ខែអស់រយៈពេល១៥ឆ្នាំ។

ដោយសារខ្ញុំបានរៀបចំការអធិប្បាយនៅក្នុងគំនិតដែលដឹងថា ខ្ញុំបាននាំមកនូវដំណឹងល្អមក បើទោះជាខ្ញុំបានចូលទៅក្នុងសៀវភៅណាមួយក៏ដោយនៅក្នុងគម្ពីរនោះខ្លឹមសារនៃការអធិប្បាយរបស់ខ្ញុំមានពេញជាបរិបូរណ៍។

ប៉ុន្តែ១៣ឆ្នាំមុននៅក្នុងព័ន្ធកិច្ចនៅកម្ពុជា ខ្ញុំបានផ្លាស់ប្តូរទៅកាន់មុខវិជ្ជាមួយទៀតដែលជាសាសនៈវិទ្យាតាមបទគម្ពីរ ព្រះគម្ពីរសញ្ញាចាស់និងសាសនៈវិទ្យានៅក្នុងការតាំងសញ្ញា ខ្ញុំបានមានអារម្មណ៍ថាដូចជាបាត់អ្វីម្យ៉ាងនៅក្នុងចិត្តរបស់ខ្ញុំ ប៉ុន្តែចិត្តរបស់ខ្ញុំមានភាពអស្ចារ្យគ្រប់ពេលដែលខ្ញុំត្រូវបានសុំឱ្យធ្វើការអធិប្បាយដោយអ្នកដទៃ ហើយព្យាយាមសិក្សា ហើយរៀបចំដើម្បីប្រកាសការថ្មីៗទៅកាន់ក្រុមជំនុំ។

នៅក្នុងវាលព័ន្ធកិច្ចរបស់ខ្ញុំ ដោយខ្ញុំអធិប្បាយព្រះបន្ទូលរបស់ព្រះជាភាសាអង់គ្លេស ខ្ញុំមានបន្ទុកមួយថែមទៀត។ បន្ទាប់មកខ្ញុំបានសរសេរខ្លឹមសារនៃការអធិប្បាយរបស់ខ្ញុំយ៉ាងពេញដោយការអានខ្លឹមសារនោះដោយត្រង់ៗ។ ហើយដោយសាររូបកាយរបស់ខ្ញុំមានភាពយឺតយ៉ាវនៅក្នុងការបង្ហាញពីការគិតរបស់ខ្ញុំនៅក្នុងខ្លឹមសារលម្អិតទៅកាន់ក្រុមជំនុំ នោះខ្ញុំមានអារម្មណ៍បន្ទុកមួយចំនួន។ ខ្លឹម

សារអធិប្បាយអស់រយៈពេល១៣ឆ្នាំហាក់ដូចជាទ្រព្យសម្បត្តិ។ ថ្ងៃមួយខ្ញុំនឹងចែករំលែកការទាំងនោះទៅកាន់គ្រិស្ទាននៅកម្ពុជានិងអ្នកធ្វើបេសកកម្ម។

ការបង្រៀនជាភាសាអង់គ្លេសនិងខ្លឹមសារអធិប្បាយជាភាសាអង់គ្លេសមានទំនាក់ទំនងជាមួយគ្នា។ វារវល់ណាស់ដែលមេរៀនជាភាសាអង់គ្លេសត្រូវបានប្តូរទៅជាខ្លឹមសារនៃការអធិប្បាយអង់គ្លេស។ បើទោះជាខ្ញុំបានអធិប្បាយអស់រយៈពេល៣០នាទី ខ្ញុំមិនបានស្កប់ស្កល់នៅក្នុងចិត្តរបស់ខ្ញុំឡើយ។ ពីព្រោះខ្ញុំមានខ្លឹមសារដែលជាក់ស្តែងដូចជាកម្មវត្ថុនៃការអធិប្បាយ ចិត្តដែលល្អនៅក្នុងការធ្វើឱ្យអស់ពីសមត្ថភាពរបស់ខ្ញុំទៅកាន់ព្រះអម្ចាស់ ខ្ញុំបានអធិប្បាយសេចក្តីពិតដោយក្លាហានទៅកាន់ក្រុមជំនុំ។ ខ្ញុំមានអារម្មណ៍ថាការបកប្រែសៀវភៅកូរ៉េទៅជាអង់គ្លេសលឿនដោយប្រើកុំព្យូទ័ររបស់ខ្ញុំ។ ហើយអស់រយៈពេល១០ឆ្នាំ ខ្ញុំបានបកប្រែការអធិប្បាយរបស់ខ្ញុំពីភាសាកូរ៉េទៅជាភាសាអង់គ្លេស។ ដូច្នេះបទពិសោធមានប្រយោជន៍នៅក្នុងការប្រតិកម្មលើការអធិប្បាយជាភាសាអង់គ្លេស។ ការសំខាន់មួយចំនួនគួរតែត្រូវបានបញ្ជូនទៅកាន់អ្នកជំនាញដើម្បីធ្វើការកែតម្រូវ ដែលជាលទ្ធផលនៃការអធិប្បាយជាភាសាអង់គ្លេស ដែលតែងតែមានខ្លឹមសារដែលជាក់ស្តែងនិងគោលបំណងច្បាស់លាស់។ ទ្រឹស្តីនៃការអធិប្បាយរបស់ខ្ញុំជាការញែកការបង្រៀននៃការអធិប្បាយ ប៉ុន្តែការអធិប្បាយអង់គ្លេសមានដែនកំណត់នៅក្នុងបទពិសោធន៍របស់ខ្ញុំ។

នៅពេលដែលខ្ញុំបង្វឹកបុគ្គលិក បន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សាពីសាលាព្រះគម្ពីរភ្លាម ពួកគេគួរតែអធិប្បាយព្រះបន្ទូលរបស់ព្រះពិតប្រាកដ។ ដូច្នេះព័ន្ធកិច្ចរបស់ខ្ញុំផ្តោតលើទ្រឹស្តីនៃការអធិប្បាយរបស់ពួកបរិសុទ្ធ ដែលពួកគេគួរតែដើរតាម

ព័ន្ធកិច្ចរបស់ពួកគេ។ ពីព្រោះការអធិប្បាយប្រវត្តិសាស្រ្តនៃសេចក្តីប្រោសលោះពឹងផ្អែកលើការយល់ពីសាសនៈវិទ្យាតាមបទគម្ពីរ ពួកគេត្រូវការថ្នាក់ដែលខ្ពស់បំផុត។ នៅថ្ងៃមួយ ខ្ញុំបានពិនិត្យមើលការអធិប្បាយមួយចំនួន ខ្ញុំបានរកឃើញថាពួកគេត្រូវការរៀបចំនូវសេចក្តីសរុបនៃខ្លឹមសារអធិប្បាយរបស់ពួកគេ។ បើទោះជាខ្ញុំបានត្រួតពិនិត្យសេចក្តីអធិប្បាយរបស់ពួកគេក៏ដោយ វាមិនងាយទេនៅក្នុងការកែតម្រូវវា។ ដូច្នេះខ្ញុំបានទទួលស្គាល់ថានៅពេលដែលធ្វើព័ន្ធកិច្ច ពួកគេអាចប្រើការទាំងនោះ បែបបង្រៀននិងការអធិប្បាយនោះ ពីព្រោះពួកគេគួរតែអនុវត្តព្រះបន្ទូលរបស់ព្រះ។

ជួនកាលយើងត្រូវការការអធិប្បាយដើម្បីផ្សាយដំណឹងល្អ។ កម្ពុជាមានអាកាសធាតុក្តៅ។ ជួនកាលអាកាសធាតុនាំឱ្យមានបញ្ហាមួយចំនួន នៅក្នុងកាលដែលខ្ញុំសង្កេតមើលបុគ្គលិកដែលបម្រើតួនាទីរបស់ពួកគេដោយស្មោះត្រង់ដោយការចែងចាំងរូបកាយដោយញើសយ៉ាងច្រើន ជួនកាលខ្ញុំបានគិតថាពួកគេពិតជាអ្នកបម្រើដែលស្មោះត្រង់ពិតមែនសម្រាប់ព្រះគ្រីស្ទ ហើយខ្ញុំបានសូមថាឱ្យពួកគេរស់នៅសម្រាប់ដំណឹងល្អពិតប្រាកដ។ បន្ទាប់មកខ្ញុំបានសារភាពថា វិធិសាស្រ្តដែលងាយស្រួលជាងនោះនឹងជាការអធិប្បាយរបស់ពួកបរិសុទ្ធ។ ជាការចូលទៅក្នុងអត្ថបទដែលត្រូវបានរៀបចំរួចហើយបកស្រាយវានិងដាក់អនុវត្តការទាំងនោះនៅក្នុងជីវិតរបស់ពួកគេ។ ការអធិប្បាយនៃសេចក្តីប្រោសលោះត្រូវបានដឹងនាំដោយអ្នកចាប់ផ្តើមនៅក្នុងសភាពដែលមិនច្បាស់លាស់ ពីព្រោះដោយមានការសញ្ជឹងគិតច្រើន។ ប៉ុន្តែនៅកម្ពុជានៅពេលដែលយើងអធិប្បាយ គ្រប់ទាំងភូមិចំនួន

១៩០០០ យើងត្រូវការផ្តោតលើការអធិប្បាយបែបផ្សាយដំណឹងល្អ។ វាជាការអធិប្បាយដើម្បីទទួលបានព្រលឹងមនុស្ស។

បើទោះជាវាងាយស្រួល ការលះបង់ដើម្បីទទួលបានព្រលឹងនិងការយល់ដ៏ជ្រាលជ្រៅពីព្រលឹងដោយការផ្សាយដំណឹងល្អគួរតែត្រូវបានបង្ហាញមក។ ការអធិប្បាយនៅចំពោះទីសាធារណៈ និងទីផ្ទាល់ខ្លួនត្រូវការទម្រង់ច្បាស់លាស់ ហើយគួរតែប្រកាសដំណឹងល្អ។ ព័ន្ធកិច្ចបន្តរបស់គ្រូគង្វាល អ្នកអធិប្បាយគួរតែជ្រើសរើសកណ្ឌគម្ពីរមួយហើយអធិប្បាយវាដោយជាប់លាប់។ ហើយខ្ញុំក៏ជម្រុញឱ្យប្រើការត្រួតពិនិត្យផ្ទាល់ខ្លួនដោយបញ្ជីត្រួតពិនិត្យនៃការវាយតម្លៃរបស់ខ្លួនគេ។

8. ខ្លឹមសារនៃការអធិប្បាយគំរូនៃគ្រូអធិប្បាយកម្ពុជា

ឧទាហរណ៍ទី១

(1) កាលដែលខ្ញុំវាយតម្លៃនូវគ្រោងនៃការអធិប្បាយរបស់គេ ហើយខ្លឹមសាររបស់វា ខ្ញុំមានការភ្ញាក់ផ្អើលនៅក្នុងការរៀបចំដោយស្មោះត្រង់របស់គេពីគ្រោងនៃការអធិប្បាយ ពីព្រោះគាត់ព្យាយាមទាញចេញពីអត្ថបទព្រះគម្ពីរ។ ប៉ុន្តែខ្លឹមសារបានធ្លាក់ទៅកាន់សីលធម៌របស់មនុស្សដោយងាយ។ ក្នុងកាលដែលគោលបំណងរបស់ការអធិប្បាយត្រូវបានសម្រេច នោះការអធិប្បាយរបស់គាត់នឹងនឹងមានប្រសិទ្ធិភាពជាងនោះទៀត។

(2) គ្រោង៖ លំនាំទាំងមូលនៃខ្លឹមសារអធិប្បាយរបស់គាត់បង្ហាញពីចំណងជើងនៃខ្លឹមសារទាំងមូល ហាក់បីដូចជាត្រូវបានបង្ហាញតាមរយៈការសញ្ជឹងគិតជាច្រើន។ គាត់ទាញចំណុចបីចេញពីអត្ថបទគម្ពីរ ហើយបានខិតចូលជិតការសរុបសេច

ក្ដីរបស់គាត់ ហើយបន្ទិចមកគាត់ព្យាយាមភ្ជាប់ទៅការអធិស្ឋានជាសាធារណៈ។ វាជាខ្លឹមសារមួយនៃការអធិប្បាយរបស់គ្រូគង្វាល។

ឧទាហរណ៍ទី ២

(1) ខ្លឹមសារអធិប្បាយរបស់គ្រូគង្វាយដែលជាបេសកជនកូរ៉េម្នាក់ អំពី ១កូរិនថូស 1:18-25

- ការពន្យល់របស់គាត់ទៅកាន់អត្ថបទគម្ពីរ។
- ហេតុផលដែលយើងគួរតែស្ដាប់បង្គាប់ទៅកាន់ឈើឆ្កាង។
- ការបាត់បង់នៃអំណាចនៃព្រះបន្ទូលរបស់ព្រះ។
- គាត់សង្កត់លើការបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះថាទេវតានិងអារក្ស មិនបានស្គាល់ពីអាថ៌កំបាំង។
- ដូច្នេះការផ្សាយដំណឹងល្អជាអភ័យឯកសិទ្ធដ៏អស្ចារ្យដែលមានតែអ្នកដែលត្រូវបានសង្គ្រោះប៉ុណ្ណោះអាចធ្វើបាន។

(2) ការវាយតម្លៃរបស់ខ្ញុំ

១) គាត់បានរៀបចំខ្លឹមសារនៃការអធិប្បាយនៅក្នុងលំនាំនៃព័ន្ធកិច្ចជាគ្រូគង្វាលរបស់គាត់ដ៏យូរអង្វែងសម្រាប់ក្រុមជំនុំកម្ពុជា ជាគ្រូគង្វាលនិងជាបេកកជនម្នាក់។ តាមរយៈបទពិសោធន៍ដោយយូរអង្វែងរបស់គាត់ គាត់បានបង្កើតការអធិប្បាយចេញពីអត្ថបទព្រះគម្ពីរនៅក្នុងការសញ្ជឹងគិតរបស់គាត់។ គាត់ចូលចិត្តអធិប្បាយដែលមានខ្លឹមសារដែលនិយាយទៅកាន់ក្រុមជំនុំនៅក្នុងថ្ងៃថ្វាយបង្គំព្រះអម្ចាស់ ដើម្បីធ្វើឱ្យពួកគេយល់ពីអត្ថន័យ។

២)  ខ្លឹមសារអធិប្បាយរបស់គាត់មានគ្រោងដែលត្រូវបានបង្កើតជាចំណងជើង (ការផ្សាយដំណឹងល្អ) ជាវិធីសាស្រ្តជាចំណុចកណ្តាលនៅលើគ្រឹះនៃធាតុអនុវត្តជាប្រព័ន្ធ។ គាត់បានផ្តោតលើការសម្តែងរបស់សកម្មភាពផ្សាយដំណឹងល្អ។

៣) គាត់បានទាញសេចក្តីពិតនៃការផ្សាយដំណឹងល្អចេញពីអត្ថបទព្រះគម្ពីរនិងរៀបចំតាមលំដាប់លំដោយទៅកាន់សេចក្តីសរុបនៃខ្លឹមសារអធិប្បាយ (ការផ្សាយដំណឹងល្អជាអាទិភាពរបស់អ្នកដែលត្រូវបានសង្គ្រោះ)។ គ្រោងរបស់គាត់មានភាពទាក់ទាញ មានការអភិវឌ្ឍជាបន្ត។ ការអធិប្បាយរបស់គាត់អាចផ្តល់ការយល់ដឹងមួយចំនួននូវអត្ថន័យនៃការផ្សាយដំណឹងល្អនិងការលើកទឹកចិត្តដល់អ្នកផ្សាយដំណឹងល្អ។

# ជំពូកទី ៥

## គោលបំណងអធិប្បាយរបស់គ្រូអធិប្បាយកម្ពុជា

ពេលនេះយើងមានលំដាប់លំដោយដែលយើងគួរតែប្រតិកម្មទៅលើគោលបំណងចម្បងនៃអ្នកអធិប្បាយកម្ពុជាជាទូទៅ។ អ្នកអធិប្បាយកម្ពុជាត្រូវការផ្តោតទៅលើទីកន្លែងបីដូចតទៅនេះ។ ពីព្រោះពួកគេគួរតែជម្រុញឱ្យខ្លួនពួកគេទៅដល់គោលដៅនៃបទគម្ពីរ។ ការនេះនឹងចម្រើនកម្លាំងនៅក្នុងការរៀបចំនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងក្រុមជំនុំដោយជនជាតិកម្ពុជា យើងអាចរៀបចំពួកគេនៅក្នុងទិសដៅបីពីការនោះ។

1. ការលូតលាស់នៃក្រុមជំនុំ

លើសពីការដែលក្រុមជំនុំកម្ពុជាគួរតែផ្តោតលើនោះគឺការលូតលាស់របស់ក្រុមជំនុំ។ វាមានន័យថាក្រុមជំនុំគួរតែទៅកាន់ទីកន្លែងនៃការលន់តួបាបនិងសេចក្តីជំនឿដោយនៅក្នុងវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធនោះពួកគេនឹងមានចិត្តដែលឆេះសន្ធោរសន្ធៅ។ ការមួយនេះតែងតែរាប់បញ្ចូលជានិច្ចដោយអ្នកអធិប្បាយ ពីព្រោះកម្ពុជាបានចូលទៅក្នុងសមរភូមិខាងវិញ្ញាណនៅក្នុងវាលព័ន្ធកិច្ច។ ហេតុអ្វី? ពីព្រោះការមួយនៅក្នុងចំណោមនោះជាការនៅក្នុងប្រព័ន្ធសង្គមនៅក្រោមសហគមន៍ដែលគ្រីស្ទានមិនគួរធ្វើការបន្ធូរបន្ថយ ហើយគួរតែដេញតាមវប្បធម៌នៃការផ្លាស់ប្រែ ហើយមួយទៀតជាសេចក្តីពិតដែលនៅក្រោមការសង្កត់សង្កិនខាងវិញ្ញាណ ការគិត ដូចជាគុកងងឹតរបស់ព្រះពុទ្ធសាសនា បើទោះជាពួកគេទទួលបានចំណុចដែលមានការបន្ធូរបន្ថយជាមួយការបង្រៀនរបស់គ្រីស្ទានក៏ដោយ។ លើសពីនោះទៀត ពួកគេត្រូវបានសំណូមពរថា ពួក

គេគួរតែជ្រើសរើសព្រះអម្ចាស់ ឬសម្ភារៈនិយមដើម្បីរៀបចំដោយការបង្រៀនពិតប្រាកដនៃដំណឹងល្អ។ ផ្លូវដែលបើកចំហរនៃការផ្លាស់ប្រែបែបនេះចេញមកពីការយល់បទគម្ពីរតែមួយប៉ុណ្ណោះ ជាការលូតលាស់ដែលគួរតែចេញមកពីបទគម្ពីរ។ ការនេះចេញមកពីកិច្ចការនៃការបើកសម្តែងរបស់ព្រះវិញ្ញាណជាអ្នកអធិប្បាយលើសអស់ទាំងអ្នកអធិប្បាយពីព្រះបន្ទូលរបស់ព្រះអម្ចាស់។ បើទោះជាខ្ញុំជាកូរ៉េអាមេរិកក៏ដោយ ខ្ញុំបានចាប់ផ្តើមនៅកូរ៉េខាងត្បូង។ យោងទៅតាមបរិស្ថាននៃក្រុមជំនុំកូរ៉េ ខ្ញុំបានចូលរួមការប្រជុំនៅក្រុមជំនុំ ហើយបានទទួលព្រះគុណតាមរយៈការអធិប្បាយពីបទគម្ពីរដោយស្មោះត្រង់ ខ្ញុំបានស្គាល់ព្រះយេស៊ូវហើយបានក្លាយជាគ្រូគង្វាល ហើយបន្ទាប់មកខ្ញុំចង់ស្គាល់ព្រះគម្ពីរ សេចក្តីពិត និងប្រកាសការទាំងនោះដោយស្មោះត្រង់ទៅកាន់រាស្ត្ររបស់ទ្រង់។ នៅឆ្នាំ ២០០៤ ខ្ញុំបានទទួលជម្ងឺសម្ពាធឈាមឡើងខ្ពស់យ៉ាងបន្ទាន់នៅក្នុងព័ន្ធកិច្ចនៅក្នុងក្រុមជំនុំ ហើយខ្ញុំបានក្រោកឡើងវិញដោយសារព្រះគុណរបស់ព្រះចេញពីកន្លែងអង្គុយដ៏លំបាក ហើយខ្ញុំក៏បានមកព័ន្ធកិច្ចអប់រំនៅកម្ពុជារហូតមកដល់កាលដែលខ្ញុំខ្វល់ខ្វាយចម្បងរបស់ខ្ញុំពេលនេះ នោះវាជាការលូតលាស់នៃក្រុមជំនុំ និងព័ន្ធកិច្ចផ្សេងទៀត ការកសាងព្រះវិហារសម្រាប់សុវត្ថិភាព ការបង្រៀនការយល់ដឹងរបស់ខ្ញុំទៅកាន់មនុស្សដែលនៅតាមក្រុមកោសិកានៅក្នុង២៥ខេត្ត ដែលជាប្រភេទសិក្ខាសាលាដែលជាបញ្ហាទីពីរ។ ខ្ញុំប្រាកដថាភ្លើងរបស់ព្រះវិញ្ញាណបរិសុទ្ធត្រូវបានទម្លាក់មកនៅលើក្រុមជំនុំកម្ពុជា នោះកម្ពុជានឹងត្រូវបានលូតលាស់ដោយសារព្រះអម្ចាស់។ ដូច្នេះវាជាការធម្មតាដែលអ្នកអធិប្បាយកម្ពុជាគួរតែផ្តោតលើបញ្ហាដោយយកចិត្តទុកដាក់ ពីព្រោះពួកគេធ្វើការដំបូងជាទីដែលធ្វើសង្គ្រាមសម្រាប់ព័ន្ធកិច្ច។

យើងគួរតែទំនាក់ទំនងទៅនឹងការអធិប្បាយដើម្បីបង្កើតក្រុមជំនុំរបស់ព្រះអម្ចាស់។ ហើយក្រុមជំនុំគួរតែជាធាតុសំខាន់នៅក្នុងការកសាងក្រុមជំនុំរបស់ព្រះអម្ចាស់។ នៅក្នុងចំណោមបេសកកម្មជាច្រើនរបស់ព្រះគ្រីស្ទ ការចេញទៅ ធ្វើពិធីជ្រមុជទឹក ការបង្រៀន និងការធ្វើឱ្យពួកគេរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងគួរតែស្មោះត្រង់នៅក្នុងការឱ្យចំណីដល់ក្រុមជំនុំនិងថែរក្សាវាតាមរយៈការអធិប្បាយ។ (យ៉ូហាន 21) ព័ន្ធកិច្ចនេះត្រូវបានបង្ហាញមកដោយការត្រួតពិនិត្យយើងនៅក្នុងកញ្ចក់នៃសេចក្តីបង្រៀនរបស់ព្រះអម្ចាស់របស់យើង និងសាវ័ករបស់ទ្រង់ វានឹងត្រូវបានបង្ហាញមកយ៉ាងជាក់ច្បាស់។

ម៉ាថាយ 28:19-20 ចង្អុលទៅកាន់ការបង្គាប់បួនយ៉ាងមកកាន់យើង។ ខ្ញុំបានរៀបចំធាតុទាំងនោះដូចតទៅនេះ។

1) ការផ្សាយដំណឹងល្អ

(1) ការផ្សាយដំណឹងល្អជាគន្លឹះចម្បងសម្រាប់រក្សាភ្លើងនៃការលូតលាស-ខ្ញុំរីករាយនឹងការផ្សាយដំណឹងល្អ ពីព្រោះខ្ញុំបានទទួលបទពិសោធន៍នូវភ្លើងនៃការលូតលាស់នៅក្នុងចិត្តរបស់ខ្ញុំ។ បើទោះជាខ្ញុំអស់កម្លាំងដោយសារមានការលះបង់ច្រើនដោយការស្រែកចេញនូវដំណឹងល្អជាមួយនឹងមាត់របស់ខ្ញុំនៅក្នុងផ្លូវដែលមានស្ទះចរាចរណ៍នៅផ្លូវ អន់ថារីយ៉ូនៅរដ្ឋកាលីហ្វ័រញ៉ានៅអាមេរិកក៏ដោយ ខ្ញុំមានអារម្មណ៍ថាសប្បាយ។ នៅកម្ពុជានៅពេលដែលខ្ញុំអធិប្បាយព្រះបន្ទូលរបស់ព្រះទៅកាន់ក្រុមជំនុំរបស់ខ្ញុំដោយខ្លាំងក្លា ខ្ញុំមានអារម្មណ៍អំណរយ៉ាងចម្លែកនៅក្នុងចិត្តរបស់ខ្ញុំ។ ដូច្នេះខ្ញុំអធិស្ឋានសម្រាប់ភ្លើងនៃការលូតលាស់។ ប្រសិនបើក្រុមជំនុំនិងគ្រីស្ទានបាត់បង់អំណរនៃការ

ផ្សាយដំណឹងល្អ ពួកគេនឹងត្រូវធ្លាក់ចុះនៅក្នុងភាពបាក់ទឹកចិត្តដោយឯកឯង។ បន្ទាប់មកគន្លឹះចម្បងនោះជាការស្តារឡើងវិញនូវការផ្សាយដំណឹងល្អតាមរយៈការអានព្រះបន្ទូលរបស់ព្រះនិងការអធិស្ឋានទៅកាន់ព្រះដោយស្មោះត្រង់។

ខ្ញុំគិតថាព័ន្ធកិច្ចកម្ពុជាជួបជាមួយនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរនៅក្នុងទីធ្វើព័ន្ធកិច្ចពីព្រោះមានគ្រូគង្វាលជាច្រើនបានបោះបង់ការសិក្សាព្រះបន្ទូលរបស់ព្រះ ហើយស្អប់មិនចង់ធ្វើជាគ្រូគង្វាល។ មិនមានគ្រូគង្វាលនិងក្រុមជំនុំ នោះក៏មិនមានការលូតលាស់នៅក្នុងព័ន្ធកិច្ចដែរ។ បោះទោះជាមានព្រះវិហារដ៏ធំក៏ដោយ ហើយមានប្រព័ន្ធអប់រំល្អត្រូវបានរៀបចំនៅក្នុងយើងក៏ដោយ ប្រសិនបើពួកគេមិនមានសិស្សដែលមានការត្រាស់ហៅពីព្រះ វានឹងទៅជាឥតប្រយោជន៍។ ដូច្នេះយើងត្រូវតែភ្ញាក់ឡើងដើម្បីរកដំណោះស្រាយ។ តើអ្វីទៅជាដំណោះស្រាយចម្បង? នេះជាការអនុវត្តការផ្សាយដំណឹងល្អដូចដែលព្រះគ្រីស្ទបានចង្អុលប្រាប់មកកាន់យើង។ យើងគួរតែទីមួយទៅកាន់គ្រប់ជាតិសាសន៍ទាំងអស់ ហើយបង្កើតសិស្ស ហើយបង្កើតក្រុមជំនុំ ហើយក៏បង្រៀនព្រះបន្ទូលរបស់ព្រះ។ (ម៉ាថាយ 28:19-20) និយាយដោយខ្លីវាជាការផ្សាយដំណឹងល្អ។ បន្ទាប់មកយើងអាចស្តារឡើងវិញនូវភ្លើងនៃការលូតលាស់នៅក្នុងក្រុមជំនុំ។ នៅពេលដែលយើងចេញទៅដើម្បីផ្សាយដំណឹងល្អ ព្រះវិញ្ញាណបរិសុទ្ធធ្វើការនៅក្នុងយើង។ កម្ពុជានាពេលបច្ចុប្បន្នត្រូវការសកម្មភាពទាំងនេះ។ ពួកគេគួរតែស្វែងរកភ្លើងនៅក្នុងចិត្តរបស់ពួកគេ។ ខ្ញុំចង់ឱ្យភ្លើងនៃការផ្លាស់ប្រែនោះគ្របដណ្តប់នៅលើ២៥ខេត្តទាំងអស់។

(2) ព្រះវិញ្ញាណបរិសុទ្ធជាវិញ្ញាណនៃការផ្សាយដំណឹងល្អ-ម៉ាថាយ 28:19-20 និយាយពីការបង្កើតសិស្សដែលជាការបង្គាប់ដ៏ធំបំផុតនៅលើផែនដី។ វាផ្ទុកតួនាទីបី គឺការផ្សាយដំណឹងល្អ ការជ្រមុជទឹក ការបង្រៀន និងការធ្វើឱ្យគេស្តាប់តាមព្រះបន្ទូលរបស់ព្រះ។ ដូចដែលយើងដឹងហើយ ការជ្រមុជទឹកចង្អុលទៅកាន់ការបង្កើតក្រុមជំនុំ សកម្មភាពបង្រៀនគឺដើម្បីនឹងស្រោចស្រពដល់ក្រុមជំនុំដោយព្រះបន្ទូលរបស់ព្រះ និងការធ្វើឱ្យក្រុមជំនុំរក្សាព្រះបន្ទូលរបស់ព្រះ។ ការពិតណាស់គ្រប់ទាំងក្រុមជំនុំទាំងអស់និងគ្រប់គ្រីស្ទានទាំងអស់គួរតែដើរតាមការបង្គាប់នេះនៅលើផែនដីដោយស្មោះត្រង់។ វាជាគ្រឹះនៃក្រុមជំនុំដែលឈររឹងមាំនៅលើការបង្រៀនរបស់ពួកសាវ័កនិងហោរា។ (អេភេសូ 2:20) វាមានន័យថា ក្រុមជំនុំគួរតែបង្ហាញការបង្រៀនរបស់ពួកសាវ័កនិងហោរានៅក្នុងលោកិយ។ វាជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះដែលជា គោលបំណងនៃក្រុមជំនុំ។

នៅក្នុងចំណោមបញ្ហាទាំងបួន ការផ្សាយដំណឹងល្អមានន័យថាជាបញ្ហាចម្បងរបស់ក្រុមជំនុំ។ ក្រុមជំនុំជាដំបូង គួរតែទៅកាន់គ្រប់ជាតិសាសន៍ទាំងអស់។ ការចេញទៅជាសកម្មភាពជាក់ស្តែងនិងវិជ្ជមានទៅកាន់គោលបំណងដែលច្បាស់។ បើមិនមានការចេញទៅទេ ការផ្សាយដំណឹងល្អ និងការជ្រមុជទឹក ការបង្រៀន និងការស្តាប់តាមព្រះបន្ទូលរបស់ព្រះក៏គ្មានដែរ។ និយាយម្យ៉ាងទៀតថា បើមិនមានការផ្សាយដំណឹងល្អទេ គឺគ្មានក្រុមជំនុំ។ ដូច្នេះម៉ាកុស 16:15 ក៏និយាយដែរថា "ចូរចេញទៅពាសពេញពិភពលោកទាំងមូល ហើយប្រកាសដំណឹងល្អទៅកាន់មនុស្សទាំងអស់។" វាសង្កត់ធ្ងន់លើការផ្សាយដំណឹងល្អទុកជាបញ្ហាចម្បងរបស់ក្រុមជំនុំ។ ប្រសិនបើក្រុមជំនុំ

ទៅគ្រប់ជាតិសាសន៍ទាំងអស់ តើគេអាចផ្សាយដំណឹងល្អដោយរបៀបណា? ហើយបន្ទាប់ពីសសិស្សបានទទួលព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃទី៥០ បន្តិចមក ព្រះអម្ចាស់ដែលមានព្រះជន្មរស់ពីស្លាប់ឡើងវិញបង្គាប់ថា "ប៉ុន្តែអ្នកនឹងទទួលបានចេស្តានៅពេលដែលព្រះវិញ្ញាណបរិសុទ្ធមកសន្ថិតលើអ្នក ហើយអ្នកនឹងធ្វើជាបន្ទាល់របស់ខ្ញុំនៅក្រុងយេរូសាឡិម ស្រុកយូដា ស្រុកសាម៉ារី និងពេញលោកិយទាំងមូល។" នៅទីនេះព្រះអម្ចាស់ក៏បានសង្កត់ធ្ងន់លើការផ្សាយដំណឹងល្អ "អ្នកនឹងធ្វើបន្ទាល់ពីខ្ញុំ"។ ការផ្សាយដំណឹងល្អជាការបញ្ជាក់ចម្បងនៃព្រះចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពាក្យមួយទៀត ព្រះវិញ្ញាណជាវិញ្ញាណនៃការផ្សាយដំណឹងល្អ។ គ្រីស្ទានដែលមានព្រះវិញ្ញាណបរិសុទ្ធរស់នៅជាបន្ទាល់របស់ព្រះគ្រីស្ទដែលជាអ្នកផ្សាយដំណឹងល្អ។ គ្រីស្ទានដែលមិនមានការផ្សាយដំណឹងល្អជាគ្រីស្ទានដែលស្លាប់។ ហើយគ្រីស្ទានដែលមិនមានការផ្សាយដំណឹងល្អបានស្លាប់ខាងវិញ្ញាណរួចហើយ។ ប៉ុន្តែក្រុមជំនុំដែលចាប់ផ្តើមការផ្សាយដំណឹងល្អ នោះនឹងត្រូវបានរស់ឡើងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។

2) ការជ្រមុជទឹក

ទីពីរ យើងស្តាប់ទៅការជ្រមុជ គ្រីស្ទានដែលបានកើតជាថ្មីដែលត្រូវបានបង្កើតដោយការផ្សាយដំណឹងល្អរបស់ក្រុមជំនុំពីព្រះអម្ចាស់។ វាមានន័យថាដើម្បីនឹងបង្កើតក្រុមជំនុំ ដោយដឹកនាំគ្រីស្ទានទៅកាន់ពួកជំនុំនៃអ្នកដែលត្រូវបានជ្រើសរើស។ បើមិនមានការជ្រមុជទឹកទេ ក៏មិនមានគ្រីស្ទានដែរ។ ហេតុអ្វី? ពីព្រោះការប្រកបគ្នារបស់ក្រុមជំនុំមានសារសំខាន់ណាស់សម្រាប់ការលូតលាស់របស់ក្រុម

ជំនុំ។ បើទោះជាក្រុមជំនុំមានបញ្ហាមួយចំនួនក៏ដោយ ក្រុមជំនុំគួរតែរៀនពីភាពបរិសុទ្ធនិងសេចក្ដីសុខសាន្ដនៅក្នុងព្រះគ្រីស្ទ។ នេះជាការប្រកបនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំ។

តើនរណាដែលអាចធ្វើបុណ្យជ្រមុជទឹកទៅកាន់គ្រីស្ទានដែលកើតជាថ្មីបាន? នៅទីនេះ ម៉ាថាយ 28:19-20 "អ្នក" មិនមែនសំដៅទៅលើគ្រប់គ្រីស្ទានទាំងអស់នោះទេ។ ដោយត្រង់ៗ វាសំដៅទៅលើពួកសាវ័ក ជាពួកអ្នកដែលព្រះគ្រីស្ទផ្ទាល់បានបង្រៀនឱ្យបានសរសេរពាក្យទ្រង់ចុះ (ព្រះគម្ពីរ) សម្រាប់ក្រុមជំនុំនៅលើសកលលោក។

ដូច្នេះព្រះគ្រីស្ទបានត្រាស់ហៅសិស្ស១២នាក់ជាពិសេស ហើយបរិភោគ ដេក និងធ្វើការជាមួយគ្នា ដោយអនុញ្ញាតឱ្យឃើញ ឱ្យស្គាល់ដើម្បីនឹងសង្កេតហើយប៉ះពាល់ដល់ទ្រង់ជាដើម។ នាពេលអនាគត ពួកសាវ័កមានអំណាចជាសាវ័កចេញពីព្រះយេស៊ូវ។

ហេតុអ្វី? ពីព្រោះព្រះគ្រីស្ទចង់បង្កើតក្រុមជំនុំរបស់ទ្រង់នៅលើផែនដី ព្រះគ្រីស្ទបានដាក់គ្រឹះនៃក្រុមជំនុំនៅលើនោះ។ វាជាការបង្រៀនរបស់ទ្រង់ ដែលជាព្រះគម្ពីរ។ ដូច្នេះក្រុមជំនុំទាំងអស់ គ្រីស្ទានទាំងអស់គួរតែឈររឹងមាំនៅលើគ្រឹះនោះ ដែលជាការបង្រៀនរបស់ព្រះគ្រីស្ទ។ ដូច្នេះសាវ័កប៉ូលនិយាយថា "គ្រឹះនៃពួកសាវ័កនិងហោរា" (អេភេសូ 2:20) នៅទីនេះពួកសាវ័កទាំង១២និងហោរាជាអ្នកផ្សាយដំណឹងល្អនៅក្នុងពួកជំនុំដំបូងដូចជា ម៉ាកុស លូកាជាដើម ជាអ្នកដែលមានទំនាក់ទំនងទៅនឹងហោរានៅក្នុងសញ្ញាចាស់។

ផលូវនេះតើពួកសាវ័កនិងហោរានៅឯណា? វាចង្អុលទៅកាន់ព្រះគម្ពីរនិងការបង្រៀនតែមួយប៉ុណ្ណោះ។ ដូច្នេះគ្រប់គ្រីស្ទានទាំងអស់និងក្រុមជំនុំទាំងអស់គួរតែឈរវឹងមាំលើការបង្រៀនរបស់បទគម្ពីរ (៦៦កណ្ឌ)។ ប្រសិនបើនរណាម្នាក់មិនទទួលស្គាល់ការបង្រៀនរបស់បទគម្ពីរ នោះគេដើរតាមផ្លូវដែលខុសហើយ។ បើទោះជាគេលះបង់ការជាច្រើនក៏ដោយ គេមិនអាចមកដល់គោលដៅរបស់ព្រះគ្រីស្ទឡើយ។ គេអាចនឹងធ្លាក់ចុះទៅក្នុងការបង្រៀនខុសឆ្គង ពីព្រោះគាត់មិនមែនជាក្រុមជំនុំរបស់ព្រះគ្រីស្ទ ប៉ុន្តែជាក្រុមជំនុំមនុស្សដូចជាប៉មបាបិលដែរ។ ព្រះគ្រីស្ទមិនបានបង្គាប់ឱ្យគ្រប់គ្រីស្ទានទាំងអស់ធ្វើបុណ្យជ្រមុជឱ្យគេឡើយ។ យើងគួរតែគោរពដល់ការបង្រៀនរបស់ព្រះគ្រីស្ទ។ ដូច្នេះតាមប្រពៃណីមក ក្រុមជំនុំប្រូតេស្តង់បានស្តាប់តាមការបង្គាប់ ដែលមានតែគ្រូគង្វាលដែលបានចាក់ប្រេងតាំងប៉ុណ្ណោះដែលត្រូវបានត្រាស់ហៅដោយព្រះអម្ចាស់នៅក្នុងក្រុមជំនុំដែលធ្វើ។

ប្រសិនបើនរណាម្នាក់មិនដើរតាមបទគម្ពីរ ពិតណាស់គេនឹងត្រូវវិនាសដោយសារព្រះអម្ចាស់ (វិវរណៈ 22:18-19) បើទោះជាយើងធ្វើតាមបង្គាប់នៅក្នុងព័ន្ធកិច្ចក៏ដោយ យើងគួរតែរក្សាការបង្កើតក្រុមជំនុំរបស់ទ្រង់ មិនមែនក្រុមជំនុំរបស់យើងឡើយ។

3) ការបង្រៀនព្រះបន្ទូលរបស់ព្រះ

ទីបី ការបង្គាប់ដ៏ធំបំផុតរាប់បញ្ចូល "ការបង្រៀន" នៅក្នុងក្រុមជំនុំ។

(1) តើនរណាដែលអាចបង្រៀនទៅកាន់គ្រីស្ទាន? មានតែពួកសាវ័កប៉ុណ្ណោះដែលអាចធ្វើការនោះនៅក្នុងក្រុមជំនុំបាន។ និយាយម្យ៉ាងទៀតថា មានតែ

អំណាចរបស់ពួកសាវ័កប៉ុណ្ណោះដែលអាចធ្វើវាបាន។ បន្ទាប់ពីព្រះយេស៊ូវនិងពួកសាវ័កបានចាកចេញទៅកាន់ស្ថានសួគ៌មក តើនរណាជាពួកសាវ័ក? វាជាគ្រូគង្វាលនិងគ្រូបង្រៀនដែលពឹងផ្អែកទៅលើបទគម្ពីរ ជាតួអង្គនៃសាវ័កពិតប្រាកដ។ អេភេសូ ៥មានបន្ទូលថា "″។ នៅទីនេះ ពេលនេះគ្រូគង្វាលតែមួយប៉ុណ្ណោះ-គ្រូបង្រៀនមាននៅក្នុងក្រុមជំនុំ។ តួនាទីនេះជាអំណោយពិសេសសម្រាប់ក្រុមជំនុំដែលចេញមកពីព្រះអម្ចាស់ ដែលជាសិរសារបស់ក្រុមជំនុំ។ ដូច្នេះគ្រូគង្វាលសំខាន់ណាស់នៅក្នុងសកម្មភាពរបស់ក្រុមជំនុំ។ គ្រូមួយចំនួននៅក្នុងក្រុមជំនុំនិងសាស្រ្តាចារ្យមួយចំនួននៅសាលាគម្ពីរត្រូវបានរាប់បញ្ចូលនៅក្នុងនោះដែរ។ ប៉ុន្តែដំបូងព័ន្ធកិច្ចនៃការបង្រៀនជារបស់គ្រូគង្វាល។ ដូច្នេះប៉ូលនិយាយថា "គ្រូគង្វាលនិងគ្រូបង្រៀន″ (មិនមែនជាគ្រូបង្រៀនឡើយ ប៉ុន្តែដោយមិនមានពាក្យបញ្ជាក់ច្បាស់លាស់ពីគ្រូបង្រៀន) ដែលមានន័យថាសង្កត់ទៅលើតួនាទីចម្បងរបស់គ្រូគង្វាល ជាព័ន្ធកិច្ចនៃការបង្រៀន។

(2) ក្រុមជំនុំបច្ចុប្បន្នសកម្មភាពបង្រៀនគួរតែមានការសាកល្បងដោយគ្រូគង្វាលនៅក្នុងក្រុមជំនុំ។ បើមិនមានការអនុញ្ញាតដោយគ្រូគង្វាលទេ នោះគេគួរតែបញ្ឈប់ព័ន្ធកិច្ចនៃការបង្រៀន។ ហេតុអ្វី? ពីព្រោះខ្លឹមសារនៃការបង្រៀនទាំងអស់គួរតែចេញមកពីព្រះអម្ចាស់និងពួកសាវ័កដែលជាបទគម្ពីរ។ ប្រសិនបើនរណាម្នាក់មិនធ្វើតាមលំនាំនេះ ទំនួលខុសត្រូវយ៉ាងធ្ងន់ធ្ងរនឹងមកតាមក្រោយ។ ដូច្នេះតាមប្រវត្តិសាស្រ្តមានតែគ្រូគង្វាលប៉ុណ្ណោះដែលមានអំណាចនៅក្នុងការបង្រៀន។ ក្រុមជំនុំទូទៅស្តាប់ទៅកាន់ការអធិប្បាយនិងការបង្រៀនរបស់គាត់បានល្អ ហើយសរសេរចុះនូវចំណាងជើងសំខាន់ៗ ហើយបង្រៀនការទាំងនោះទៅកាន់ក្រុមគ្រួសាររបស់គេ។ បន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធធ្វើ

ការនៅក្នុងពួកគេ ហើយរីករាយនឹងជីវិតពេញបរិបូរណ៍នៅក្នុងចិត្តរបស់ពួកគេ និងគ្រប់ច្រកនៃជីវិតរបស់ពួកគេ។ យើងជឿថាមានតែការបង្រៀនពីបទគម្ពីរប៉ុណ្ណោះដែលអាចធ្វើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះក្រុមជំនុំគួរតែបង្រៀនបទគម្ពីរ ព្រះបន្ទូលរបស់ព្រះទៅកាន់ក្រុមជំនុំខ្លួន។

ការរីករាយនឹងការអធិប្បាយនិងការបង្រៀន

ជាទូទៅខ្ញុំជាបេកកជនម្នាក់ដែលបង្រៀននៅសាលា ITCS នៅក្នុងជីវិតដែលនៅសេសសល់របស់ខ្ញុំ។ បន្ទាប់ពីខ្ញុំបានបម្រើព័ន្ធកិច្ចនៃការបង្រៀនអស់រយៈពេល១០ឆ្នាំអំពីព្រះគម្ពីរសញ្ញាចាស់ក្នុងនាមជាសាស្ត្រាចារ្យ។ ពេលនេះដោយសារបំណងព្រះហឫទ័យរបស់ព្រះ ព័ន្ធកិច្ចរបស់ខ្ញុំអាចជាត្រូវបានពង្រីកទៅកាន់ក្រុមជំនុំកម្ពុជានៅ២៥ខេត្ត។ ខ្ញុំបានរៀបចំដើម្បីនឹងចែករំលែកការយល់ដឹងរបស់ខ្ញុំពីគម្ពីរនិងសាសនៈវិទ្យាទៅកាន់ការប្រជុំ។ ជាពិសេសខ្ញុំស្រឡាញ់ការអធិប្បាយព្រះបន្ទូលរបស់ព្រះទៅកាន់ក្រុមជំនុំ។ អ្នកខ្លះព្យាយាមគេចពីឱកាសនេះ ប៉ុន្តែខ្ញុំមានចិត្តមួយដែលខុសពីគេ។ ប្រសិនបើនរណាម្នាក់មកសុំឱ្យធ្វើការអធិប្បាយ ខ្ញុំនឹងធ្វើភ្លាម។ បន្ទាប់ពីខ្ញុំបានទទួលសញ្ញាបត្របណ្ឌិតរបស់ខ្ញុំពីមុខវិជ្ជាពីការអធិប្បាយពី Westminster Theological Seminary នៅរដ្ឋកាលីហ្វ័រញ៉ា នៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៩៦។ ខ្ញុំមិនបានដាក់ពាក្យទៅច្រើនកន្លែងដោយសារការបង្រៀនផ្នែកគម្ពីរដោយមិនបង្អង់នោះទេ។ ភ្លាមៗនោះខ្ញុំបានមកលេងនៅក្រុមជំនុំកម្ពុជា ខ្ញុំមានបំណងបង្កើតសៀវភៅពីការអធិប្បាយសម្រាប់ព័ន្ធកិច្ចនៅកម្ពុជា។

ប្រហែលជាខែមករាឆ្នាំក្រោយ សៀវភៅរបស់ខ្ញុំនឹងត្រូវបានបោះពុម្ពនៅក្នុង

ពេលសម្រាកនេះ។ ខ្ញុំអធិស្ឋានសម្រាប់ព្រះគុណរបស់ព្រះសម្រាប់សិរីល្អរបស់ទ្រង់និងសម្រាប់អ្នកបម្រើនៅកម្ពុជា។

4) ធ្វើឱ្យគេស្ដាប់តាមព្រះបន្ទូលរបស់ព្រះអម្ចាស់

ទីបួន ការបង្គាប់ដ៏អស្ចារ្យរបស់ព្រះអម្ចាស់របស់យើងរាប់បញ្ចូលការធ្វើឱ្យពួកគេរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការបង្កើតសិស្សគួរតែត្រូវបានបញ្ចប់ដោយការស្ដាប់តាមព្រះបន្ទូលរបស់ព្រះ។

តើអ្វីទៅជាគោលដៅរបស់ក្រុមជំនុំ? វាជាការបង្ហាញពីរូបឆ្លុះរបស់ព្រះ ជាសេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពស្មោះត្រង់។ (អេភេសូ 4:23-24, 5:8-9 ម៉ាថាយ 23:23)។ ពាក្យម៉្យាងទៀត វាមានន័យថាជាការត្រាប់តាមព្រះគ្រីស្ទ និងលក្ខណៈរបស់ទ្រង់ ហើយគួរតែបង្ហាញការទាំងនោះនៅក្នុងលោកិយ។ ដូច្នេះព្រះគ្រីស្ទនិងព្រះបន្ទូលរបស់ទ្រង់គួរតែបានបង្ហាញដល់លោកិយទាំងមូល។ អំណាចគួរតែជាអំណាចនៅក្នុងមនុស្ស ហើយការរក្សាមានន័យថាជាការស្ដាប់បង្គាប់ ការអនុវត្តការរីករាយនឹងធ្វើ និងការកាន់កាប់ជីវិតទាំងមូល ជីវិតរបស់គេគួរតែត្រូវបានគ្រប់គ្រងដោយអំណាចរបស់ព្រះអម្ចាស់។ វាចង្អុលទៅកាន់នគររបស់ព្រះ សេចក្ដីសុចរិត អំណរ និងសេចក្ដីសុខសាន្តនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ។ (រ៉ូម 14:13)

ហើយព្រះបន្ទូលរបស់ព្រះជាការបង្រៀនរបស់ព្រះគ្រីស្ទ ការបើកសម្ដែងរបស់ទ្រង់ដែលជាបទគម្ពីរ។ ដូច្នេះក្រុមជំនុំអធិប្បាយព្រះបន្ទូល ហើយបង្រៀននិងត្រួតពិនិត្យការនោះនៅក្នុងជីវិតពិតរបស់ពួកគេតាមរយៈព័ន្ធកិច្ចរបស់គ្រូគង្វាល។

បន្ទាប់មកសេចក្តីសន្យារបស់ព្រះគ្រីស្ទជាព្រះអេម៉ាញ៉ូអែលជា ជីវិតពេញបរិបូរណ៍ និងភាពពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងពោរពេញដោយព្រះបន្ទូលរបស់ព្រះអម្ចាស់។ ការរីករាយនឹងនគររបស់ព្រះ។ នេះជាធាតុពិតនៃក្រុមជំនុំ។ ដូច្នេះ យើងស្គាល់ថាក្រុមជំនុំជាសួនច្បារអេដែនថ្មី ជាអាណាចក្ររបស់ព្រះ។

ព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ពីសុគតឡើងវិញធ្វើការនៅក្នុងនោះ ហើយបានបើកសម្តែងសិរីល្អរបស់ទ្រង់ទៅកាន់លោកិយ។ "ព្រះអម្ចាស់ទ្រង់ជាវិញ្ញាណ" (២កូរិនថូស 2:17)

ប្រសិនបើយើងមិនស្តាប់តាមការបង្រៀនទេ នោះយើងនឹងបាត់បង់ព្រះពរ ១ អំពីការធ្វើឱ្យគេរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងគួរតែបង្កើតក្រុមជំនុំរបស់ព្រះគ្រីស្ទ មិនមែនជាក្រុមជំនុំរបស់មនុស្សដូចជាប៉មបាបិលនោះទេ។ (ម៉ាថាយ 16:18) ការបង្កើតក្រុមជំនុំកោសិកានៅកម្ពុជាគួរតែជាព្រឹត្តិការណ៍មួយដ៏មានតម្លៃ ប៉ុន្តែយើងគួរតែរក្សាការដឹកនាំសម្រាប់ការបង្កើតក្រុមជំនុំរបស់ទ្រង់ផងដែរនៅក្នុងភូមិប្រមាណ ១៤000 នៅក្នុងខេត្តទាំង២៥។

2. ការធានាអះអាងនៃអ្នកអធិប្បាយខាងពួកបរិសុទ្ធនិងជីវិតរបស់គេ

ខ្ញុំបានមាននិមិត្តមួយដែលសេចក្តីជំនឿបែបកំណែទម្រង់របស់ពួកបរិសុទ្ធនឹងត្រូវបានរៀបចំនៅក្នុងក្រុមជំនុំកម្ពុជានៅក្នុងព័ន្ធកិច្ច។ ពីព្រោះខ្ញុំមានអារម្មណ៍ថាក្រុមជំនុំកម្ពុជាត្រូវទទួលបានឥទ្ធិពលពីសាសនាផ្សេងៗ តាមរយៈលំនាំខាងសាច់ឈាមនៃគំនិតរបស់ពួកគេនិងជីវិតរបស់ពួកគេអស់រយៈពេលជាយូរ ពួកគេគួរតែត្រលប់ទៅកាន់បទគម្ពីរនិងអនុវត្តនូវជីវិតបែបរបស់កាល់វីនទៅកាន់ពួកគេ ហើយ

ពួកគេមាននិមិត្តរបស់ព្រះអម្ចាស់នៅចំកណ្តាលជីវិតរបស់ពួកគេនៅគ្រប់ទីកន្លែងទាំងអស់។ នៅពេលដំបូង អ្នកអធិប្បាយ ដែលត្រូវបានបានហៅសម្រាប់ធ្វើជាអ្នកដឹកនាំខាងវិញ្ញាណបំពាក់ខ្លួនដោយគំនិតនិងជីវិតបែបនេះ នោះពួកគេនឹងអាចយកឈ្នះនូវការវាយប្រហាររបស់អំណាចសេចក្តីងងឹត ហើយធ្វើឱ្យប្រទេសមានការផ្លាស់ប្រែជាថ្មី។ សៀវភៅដែលបង្ហាញប្រាប់នោះ "សាសនៈវិទ្យានិងសេចក្តីជំនឿនៃការស្តារឡើងវិញនៃរូបឆ្លុះរបស់ព្រះ" ត្រូវបានរាប់បញ្ចូលទៅក្នុងជីវិតទូទៅរបស់គ្រីស្ទាន ដែលត្រូវបានសរសេរដោយលោក ចន កាល់វីន។ យើងគួរតែផ្តោតលើការអធិប្បាយរបស់គ្រូអធិប្បាយដើម្បីបង្កើតការនោះនៅក្នុងក្រុមជំនុំកម្ពុជា។

ខ្ញុំមានន័យថា ការបង្រៀនរបស់កាល់វីនពីជីវិតរបស់គ្រីស្ទានត្រូវបានរៀបចំនៅក្នុងសៀវភៅរបស់គាត់ ការបង្រៀនដែលត្រូវបានកែសម្រួលសម្រាប់ក្រុមជំនុំកំណែទម្រង់របស់បារាំងគួរតែត្រូវបានរៀននៅក្នុងក្រុមជំនុំកម្ពុជាដែរ។ ពីព្រោះពួកគេត្រូវការឈររឹងមាំនៅលើគ្រឹះនៃគោលលិទ្ធិការបង្រៀនដែលត្រឹមត្រូវ និងជីវិតដែលត្រឹមត្រូវដែលកាល់វីនបានបង្ហាញប្រាប់។ វាត្រូវបានសង្ខេបដោយសៀវភៅគោលជំនឿខ្លីនៅក្នុងការសារភាពសេចក្តីជំនឿរបស់វេសមីនស្ទើ ទាំងនោះមានគោលលិទ្ធិសេចក្តីជំនឿរបស់ពួកសាវ័ក ការអធិស្ឋានព្រះអម្ចាស់ និងបញ្ញាត្តិដប់ប្រការ។ ចំណេះដឹងនេះគួរតែត្រូវបានអធិប្បាយដោយគ្រូអធិប្បាយទៅកាន់ក្រុមជំនុំ មិនមែននៅក្នុងបែបបទនៃការបង្រៀនគម្ពីរនោះទេ។

ហើយយើងត្រូវការដាក់ជីវិតប្រាំរបស់គ្រីស្ទាននៃគោលបំណងរបស់កាល់វីននៅក្នុងការអធិប្បាយ។ ជីវិតរបស់អ្នកអធិប្បាយចេញមកពីការធានាអះអាងនរបស់អ្នកអធិប្បាយ។ ការនេះគួរតែចេញមកពីបទគម្ពីរ ជាប្រភពនៃការបង្រៀន។ ជីវិត

គ្រីស្ទានមានទិសដៅចុងក្រោយ នោះយើងអាចរំពឹងពីការផ្លាស់ប្រែនៅក្នុងជីវិតរបស់គ្រីស្ទានពិតប្រាកដ។

ការអធិប្បាយនិងការធានាអះអាងរបស់ពួកកំណែទម្រង់បរិសុទ្ធកម្ពុជាត្រូវបានសង្ខេបដោយជីវិតរបស់លោកកាល់វីន។ មានការប្រាំយ៉ាង។ យើងគួរតែដេញតាមទិសដៅនេះនៅក្នុងជីវិតរបស់យើង។ ការអធិប្បាយរបស់យើងផ្តោតលើជីវិតនិងការធ្វើឱ្យក្រុមជំនុំរក្សាជីវិតជាគ្រីស្ទានធម្មតាឱ្យបានជាប់លាប់។

ខ្ញុំសង្កេតឃើញថាក្រុមជំនុំកម្ពុជាមានធាតុបី ដូចជា ការនិយាយកុហក ការមិននិយាយសុំទោស និងការមិនចេះផ្តល់របាយការណ៍ដែលជាតួនាទីរបស់គេ ដែលពួកគេគួរតែកែតម្រូវទម្លាប់ទាំងនោះ។ ខ្ញុំជឿថាការនិយាយបែបនេះថាជាទម្លាប់ខុសឆ្គងដែលគួរតែត្រូវបានផ្លាស់ប្រែដោយការអធិប្បាយបែបបទគម្ពីរ មិនមែនជាការបង្រៀនដែលក្លែងក្លាយនោះឡើយ។

លោកគ្រូគង្វាល Richard Baxter បានសម្រេចចិត្តថាគាត់នឹងបម្រើតែក្រុមជំនុំតែមួយប៉ុណ្ណោះនៅក្នុងពេញមួយជីវិតរបស់គាត់។ ដូច្នេះគាត់ត្រូវបានសម្រេចនៅក្នុងទីក្រុង ខាញដើម៉ាស្ទើ ហើយបានបង្រៀនពីគោលជំនឿ ហើយអធិប្បាយព្រះបន្ទូលរបស់ព្រះទៅកាន់ពួកគេនៅក្នុងពេញមួយជីវិតរបស់គាត់។ នៅកាលដែលគាត់ចូលនិវត្តន៍ពីក្រុមជំនុំ គាត់បានឃើញការផ្លាស់ប្រែជាច្រើន ហាមមិនឱ្យមានមនុស្សប្រមឹក មានការបង្រៀនព្រះបន្ទូលរបស់ព្រះ ហើយសរសើរដំកើងព្រះអម្ចាស់ ហើយការទន្ទេញពីគោលសេចក្តីជំនឿ។ ប្រៀបបីដូចជាព័ន្ធកិច្ចរបស់លោកសាវ័កប៉ូលនៅក្រុងអេភេសូអស់រយៈពេលបីឆ្នាំប្រាំមួយខែ មានការផ្លាស់ប្រែ

ដ៏អស្ចារ្យបានកើតឡើងដោយព្រះគុណរបស់ព្រះ។ គ្រប់ទាំងពួកអាស៊ីមីណាបានស្តាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះ ហើយបានផ្លាស់ប្រែយ៉ាងអស្ចារ្យ។ ការផ្លាស់ប្រែចេញមកពីការអធិប្បាយដោយពិតប្រាកដរបស់សាវ័កប៉ូល។ ភ្លើងនៃការផ្លាស់ប្រែត្រូវបានពង្រីកទៅកាន់រដ្ឋធានីរ៉ូមនៅក្នុងលោកិយ ដើម្បីធ្វើការផ្សាយដំណឹងល្អដល់លោកិយទាំងមូល។ នៅពេលដែលក្រុមជំនុំកម្ពុជាដើរតាមការអធិប្បាយព្រះបន្ទូលរបស់ព្រះដោយស្មោះត្រង់ នោះព្រះអម្ចាស់នឹងសម្រេចបំណងរបស់ទ្រង់សម្រាប់ជាសិរីល្អរបស់ទ្រង់ និងសម្រាប់សេចក្តីសង្គ្រោះដ៏អស្ចារ្យបានកើតឡើង។

3. គោលបំណងនៃការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ

គោលបំណងដែលយើងចង់បង្កើតជីវិតរបស់អ្នកអធិប្បាយនិងការអធិប្បាយរបស់គាត់ឱ្យមានការកំណែទម្រង់ គឺដើម្បីនឹងបង្ហាញពីសីលធម៌ជីវិតនៃការផ្សាយដំណឹងល្អរបស់គាត់ ដែលត្រូវបានសង់នៅលើដំណឹងល្អដែលត្រឹមត្រូវពិតប្រាកដ។ ការផ្លាស់ប្រែនៃជីវិតបែបសីលធម៌តាមបទគម្ពីរមិនអាចបង្កើតដោយកិច្ចការរបស់មនុស្សបានឡើយ ហើយក៏មិនគួរបង្កើតដោយកិច្ចការរបស់មនុស្សនោះដែរ។ សេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់គួរតែបានបង្ហាញដោយចេស្តានៃដំណឹងល្អដែលជាផលផ្លែនៃកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំឱ្យនិយមន័យថាជាការស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះ។ ការនេះសង្កត់ធ្ងន់ថា ការផ្តោតលើការអធិប្បាយគួរតែផ្អែកលើជីវិតរបស់រាស្ត្ររបស់ព្រះអម្ចាស់ ជាសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេ។ អ្នកអធិប្បាយដែលត្រូវបង្ហាញជីវិតដែលមានសេចក្តីសុចរិត សេចក្តីមេត្តា និងភាពស្មោះត្រង់នៅក្នុងជីវិតរបស់គាត់ នឹងប្រកាសពីការនោះទៅកាន់ក្រុមជំនុំរបស់គាត់ ដែលពួកគេត្រូវតែ

បង្ហាញជីវិតបែបសីលធម៌នោះនៅក្នុងលោកិយ។ តើអ្វីទៅជាសេចក្ដីសុចរិត? វាសំដៅទៅលើសេចក្ដីសុចរិតដែលព្រះទ្រង់ទទួលយក។ ការមួយនេះជាការដែលត្រូវបង្កើតសេចក្ដីសុចរិតនៅក្នុងក្រុមជំនុំកម្ពុជាដែលបានបាត់បង់គ្រឹះដោយការបង្ហាញពីរបៀបនៃការស្ដារឡើងវិញ និងការសាងសង់សសររឹងមាំនៅក្នុងពួកគេ។ នៅពេលដែលក្រុមជំនុំត្រូវបានស្ដារឡើងវិញដោយសេចក្ដីសុចរិត នោះគេនឹងត្រូវបានពង្រឹងឡើង។

ហើយសេចក្ដីមេត្តាមានន័យថាជាសេចក្ដីស្រឡាញ់និងសេចក្ដីអាណិត។ នេះជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ។ ក្នុងពេលតែមួយផលផ្លែនេះគួរតែត្រូវបានបង្ហាញនូវភាពស្មោះត្រង់។ ដូច្នេះអ្នកអធិប្បាយគួរតែអធិប្បាយការបីយ៉ាងគឺ សេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពស្មោះត្រង់។ ជាចុងក្រោយ អ្នកអធិប្បាយគួរតែព្យាយាមបង្កើតនូវចរិតលក្ខណៈរបស់ព្រះ។ នេះជាដាវនៃសេចក្ដីសុចរិត សេចក្ដីមេត្តា និងភាពស្មោះត្រង់។ នេះជាគ្រឹះនៃក្រឹត្យវិន័យនិងការសង្ខេបនៃចរិតលក្ខណៈរបស់ព្រះអម្ចាស់។ សេចក្ដីសរុបនៃគ្រប់ការអធិប្បាយគួរតែផ្ដោតលើចំណុចនេះ។ បន្ទាប់មក អ្នកអធិប្បាយនឹងស្គាល់អ្វីជាការផ្លាស់ប្រែពិតប្រាកដ។

## សរុបសេចក្តី

នៅក្នុងពេលសម្រាកនេះ ខ្ញុំបានទៅលេងផ្ទះតាម៉ុកដែលជាកន្លែងលាក់កំបាំងចុងក្រោយសម្រាប់គេចផុតពីរាជរដ្ឋាភិបាល ហើយគាត់បានរស់នៅនិងហ្វឹកហាត់ដើម្បីទទួលបានយ៉ាងជោគជ័យ ជាមួយនឹងឈ្លើយរបស់គាត់ដែលចូលរួមនៅក្នុង

ចំណុចដែលមានការច្របូកច្របល់របស់គាត់ ដែលមានទីតាំងនៅលើភ្នំរវាងកម្ពុជានិងថៃនៅ ឧត្តុង្គមាស នៅខេត្តឧត្តរមានជ័យ។

បន្ទាប់មកខ្ញុំបានគិតថានៅក្នុងការពិសោធន៍នូវរូបរាងនិងប្រវត្តិរបស់ប៉ុលពត ជាអ្នកសម្លាប់លើទឹកដីពិឃាតនេះ ដែលថាបើសិនជាគាត់បានស្គាល់ដំណឹងល្អនោះការដឹកនាំរបស់គាត់មកលើកម្ពុជានឹងត្រូវបានផ្លាស់ប្តូរយ៉ាងអស្ចារ្យ។ ប៉ុន្តែគាត់បានទៅបរទេស ទៅបារាំងហើយបានទទួលឥទ្ធិពលដោយ គោលលិទ្ធិម៉ៅដែលបានចេញមកពីប្រទេសចិនការវិវត្តវប្បធម៌ និងបានហ្វឹកហាត់ក្រុមយុវជននៅអាយុក្រោម២០ឆ្នាំនៅក្នុងព្រៃដើម្បីប្រើពួកគេនៅគ្រាមានអាសន្នដើម្បីសម្រេចការវិវត្តន៍របស់គាត់នៅក្នុងការកាន់កាប់កម្ពុជាទាំងមូល។ បោះទោះជាគាត់បរាជ័យនូវគោលបំណងរបស់គាត់ក៏ដោយ យើងអាចសង្កេតពីបំណងរបស់គាត់នៅក្នុងការទៅដល់ចំណុចនោះ។ ប្រសិនបើគាត់ប្រើនូវបំណងដូចនោះនៅក្នុងការប្រកាសដំណឹងល្អទៅកាន់ប្រជាជនកម្ពុជាទាំងអស់ នោះយើងអាចឃើញលទ្ធផលដែលខុសគ្នានៅពេលនេះមិនខាន។ ក្រុមជំនុំកម្ពុជាត្រូវការអ្នកអធិប្បាយដែលស្មោះត្រង់ ក្នុងនាមជាគ្រូអធិប្បាយដែលស្មោះត្រង់ដែលស្គាល់ដំណឹងល្អពិតប្រាកដនឹងធ្វើឱ្យមានក្រុមជំនុំកម្ពុជាចេញមក សង្គមរបស់ពួកគេនឹងត្រូវបានផ្លាស់ប្រែទៅជាទីសង្ឃឹមស្ថានសួគ៌។

តើអ្នកណាដែលអាចធ្វើការដ៏ពេញដោយសិរីល្អនេះបាន? មានតែអ្នកដែលស្គាល់ព្រះបន្ទូលរបស់ព្រះប៉ុណ្ណោះ ដែលជាបទគម្ពីរដែលអាចធ្វើបាន។ នៅពេលដែលពួកគេរស់នៅទីសម្ងាត់ដោយការគោរពកោតខ្លាចព្រះ ហើយបម្រើក្រុមជំនុំដោយ

ស្មោះត្រង់ ហើយស្តាប់បង្គាប់ដ៏ធំរបស់ព្រះអម្ចាស់ បន្ទាប់មកកិច្ចការដ៏អស្ចារ្យនឹងកើតឡើង។ នៅក្នុងតួនាទីរបស់គ្រូអធិប្បាយជាតួនាទីសំខាន់។

ខ្ញុំបានរៀបចំការធានាអះអាងរបស់ខ្ញុំពីការអធិប្បាយដោយសាមញ្ញ ហើយបានណែនាំពីគោលការណ៍នៃការអធិប្បាយនិងការអនុវត្តផង ដែលជាទ្រឹស្តីនៃការអធិប្បាយសម្រាប់ស្តារឡើងវិញនូវរូបឆ្លុះរបស់ព្រះនៅក្នុងអ្នកអធិប្បាយនៅក្នុងក្រុមជំនុំកម្ពុជាដើម្បីបង្កើតអាណាចក្ររបស់ព្រះ។ ខ្ញុំអធិស្ឋានថាសៀវភៅនេះនឹងត្រូវបានប្រើសម្រាប់គ្រូគង្វាលកម្ពុជាសម្រាប់គោលបំណងនេះដោយបន្ទាបខ្លួនដោយបានប្រកាសសេចក្តីជំនឿរបស់ក្រុមជំនុំបែបកំណែទម្រង់បរិសុទ្ធ ហើយបង្កើតនគររបស់ព្រះនៅលើគ្រឹះសម្រាប់ការបើកសម្តែងនូវកិច្ចការដ៏ពេញដោយការច្នៃប្រឌិតនៅក្នុងព្រះគ្រីស្ទ។

"តែ ឱអ្នកសំណប់នៃព្រះអើយ ចូរឱ្យអ្នករត់ចៀសចេញពីសេចក្តីទាំងនេះ ហើយដេញតាមសេចក្តីសុចរិត សេចក្តីគោរពប្រតិបត្តិដល់ព្រះ សេចក្តីជំនឿ សេចក្តីស្រឡាញ់ សេចក្តីខ្ជាប់ខ្ជួន និងសេចក្តីសំឡូតវិញ។" (១ ធីម៉ូថេ 6:11)

"ចូរឱ្យអ្នកផ្សាយព្រះបន្ទូលចុះ ហើយទទូចជម្រុញផង ទោះត្រូវពេល ឬខុសក្តី ចូររំឭកគេឱ្យដឹងខ្លួន ព្រមទាំងបន្ទោស ហើយកំឡាចិត្តគេ ដោយចិត្តអត់ធ្មត់ និងសេចក្តីប្រៀនប្រដៅគ្រប់យ៉ាង។" (២ ធីម៉ូថេ 4:2)

# សេចក្ដីបន្ថែមទី១៖ ទម្រង់នៃខ្លឹមសារអធិប្បាយ

| អត្ថបទ | ចំណាងជើង | កាលបរិច្ឆេទ | គ្រូអធិប្បាយ | |
|---|---|---|---|---|
| សេចក្ដីផ្ដើម | | | | |
| 1. ការខ្វល់ខ្វាយ | | | | |
| 2. សេចក្ដីត្រូវការ | | | | |
| 3. ប្រយោគភ្ជាប់ | | | | |
| 4. សេចក្ដីសរុបរបស់អត្ថបទ | | | | |
| 5. សេចក្ដីសរុបនៃការអធិប្បាយ | | | | |
| គ្រោង | | | | |
| 1. ផ្នែកទី១ | | | | |
| 1) ការពន្យល់ | | | | |
| 2) ការអនុវត្ត | | | | |
| 3) ការជជែកវែកញែក | | | | |
| 4) ឧទាហរណ៍ | | | | |
| 5) សួរសំណួរ | | | | |
| 6) ប្រយោគភ្ជាប់ | | | | |
| 7) ប្រយោគភ្ជាប់ពីផ្នែក១និងផ្នែកទី២ | | | | |

| | |
|---|---|
| 2. ផ្នែកទី១ | |
| 1) សេចក្តីពន្យល់ | |
| 2) ការអនុវត្ត | |
| 3) ការជជែកវែកញែក | |
| 4) ឧទាហរណ៍ | |
| 5) សួរសំណួរ | |
| 6) ប្រយោគភ្ជាប់ | |
| 7) ប្រយោគភ្ជាប់ពីផ្នែក២និងផ្នែកទី៣ | |
| 8) ពាក្យភ្ជាប់ផ្នែកទី១និងផ្នែកទី៣ | |
| 3. ផ្នែកទី៣ | |
| 1) ការពន្យល់ | |
| 2) ការអនុវត្ត | |
| 3) ការជជែកវែកញែក | |
| 4) ឧទាហរណ៍ | |
| 5) សួរសំណួរ | |

| | |
|---|---|
| 6) ប្រយោគភ្ជាប់ | |
| 7) ពាក្យភ្ជាប់ផ្នែក១ ទៅផ្នែកទី២ | |
| សរុបសេចក្ដី | |
| 1) ការផ្ដល់ជាចក្ខុវិស័យ | |
| 2) ការសង្ខេប | |
| 3) សកម្មភាព | |
| 4) សំណូមពរ | |

# សេចក្ដីបន្ថែមទី២៖ បញ្ជីសម្រាប់ត្រួតពិនិត្យផ្ទាល់ខ្លួនសម្រាប់គ្រូអធិប្បាយ

| សំណួរ ( ១ ធីម៉ូថេ 6:11) | ចំណាងជើង | ចំណុច | ការពន្យល់ |
|---|---|---|---|
| **A អ្នកពន្យល់** | | | |
| 1. តើខ្ញុំមានចិត្តនៅក្នុងការដេញតាមបំណងព្រះហឫទ័យរបស់ព្រះអម្ចាស់ទេ? | សេចក្ដីសុចរិត | (1 2 3 4 5) | |
| 2. តើខ្ញុំឈរនៅចំពោះព្រះដោយត្រឹមត្រូវដែរឬទេ? | ភាពស្មោះត្រង់ស្មោះ | (1 2 3 4 5) | |
| 3. តើខ្ញុំមានសេចក្ដីជំនឿដែលអាចយកឈ្នះបញ្ហាសព្វថ្ងៃនេះដែរឬទេ? | ជំនឿ | (1 2 3 4 5 ) | |
| 4. តើខ្ញុំមានសេចក្ដីស្រឡាញ់ដើម្បីបម្រើដល់អ្នកជិតខាងដែរឬទេ? | សេចក្ដីស្រឡាញ់ | (1 2 3 4 5 ) | |
| 5. តើខ្ញុំមានចិត្តដែលបន្ទាបដែរឬទេ? | ការបន្ទាបខ្លួន | (1 2 3 4 5) | |
| 6. តើខ្ញុំស៊ូទ្រាំនៅក្នុងគ្រាដែលលំបាកដែរទេ? | ការអត់ធ្មត់ | (1 2 3 4 5) | |
| B **ការរៀបចំនៅក្នុងការពន្យល់** | | | |
| 1. តើខ្ញុំបានរៀនពីអត្ថបទព្រះគម្ពីរដែរឬទេ? | | (1 2 3 4 5) | |
| 2. តើខ្ញុំបានរកវត្ថុបំណងនៃការអធិប្បាយដែរទេ? | | (1 2 3 4 5) | |
| 3. តើខ្ញុំបានស្គាល់គ្រោងហើយឬនៅ? | | (1 2 3 4 5) | |
| 4. តើខ្ញុំបានពង្រឹងនូវគ្រោងនេះហើយឬនៅ? | | (1 2 3 4 5) | |
| 5. តើខ្ញុំបានបំពេញគ្រោងនៃការអធិប្បាយហើយឬនៅ? | | (1 2 3 4 5) | |
| 6. តើខ្ញុំបានដាក់សេចក្ដីសរុបនិងសេចក្ដីផ្ដើមហើយឬនៅ? | | (1 2 3 4 5) | |
| 7. តើខ្ញុំបានសម្រួចការអនុវត្តហើយឬនៅ? | | (1 2 3 4 5) | |

| C. **ការផ្តល់សេចក្តីពន្យល់** | | | |
|---|---|---|---|
| 1. តើខ្ញុំបានអធិប្បាយសាររបស់ព្រះអម្ចាស់តាមរយៈបុគ្គលិកលក្ខណៈទាំងមូលរបស់ខ្ញុំដែរឬទេ? | | (1 2 3 4 5) | |
| 2. តើខ្ញុំបានអធិប្បាយជាមួយនឹងអារម្មណ៍ពេញដោយអំណាចនៅក្នុងការគ្រប់គ្រងលើក្រុមជំនុំនិងការដំណើរការដែរទេ? | | (1 2 3 4 5) | |
| 3. តើខ្ញុំបានទទួលបានការណាមួយចេញពីក្រុមជំនុំនៅពេលដែលខ្ញុំកំពុងតែនិយាយដែរឬទេ? | | (1 2 3 4 5 ) | |
| 4. តើខ្ញុំមានអារម្មណ៍ថាមានសេរីភាពក្នុងកាលដែលកំពុងអធិប្បាយដែរទេ? | | (1 2 3 4 5 ) | |
| 5. តើខ្ញុំមានអារម្មណ៍ថាមានសេរីភាពខាងវិញ្ញាណនៅពេលដែលកំពុងអធិប្បាយដែរទេ? | | (1 2 3 4 5) | |
| 6. តើខ្ញុំមានភាពម៉ឺងម៉ាត់នៅក្នុងការអធិប្បាយដែរទេ? | | (1 2 3 4 5) | |
| 7. តើខ្ញុំមានភាពឆេះឆួល ការខ្វល់ខ្វាយនិងភាពកក់ក្តៅដែរទេ? | | (1 2 3 4 5) | |
| 8. តើខ្ញុំមានភាពបន្ទាន់នៅក្នុងការអធិប្បាយដែរទេ? | | (1 2 3 4 5) | |
| 9. តើខ្ញុំមានការទាក់ទាញចិត្តដល់អ្នកស្តាប់ដែរទេ? | | (1 2 3 4 5) | |
| 10. តើខ្ញុំមានផាតុសទេ? (Pathos) | | (1 2 3 4 5) | |

| | | | |
|---|---|---|---|
| 11. តើខ្ញុំមានអំណាចនៃព្រះបន្ទូលដែរ ឬទេ? | | (1 2 3 4 5) | |
| 12. តើខ្ញុំមានចេស្តានៅពេលដែលខ្ញុំ អធិប្បាយដែរទេ? | | (1 2 3 4 5) | |
| **D. ការឆ្លើយតបនៃការពន្យល់** | | | |
| 1.តើក្រុមជំនុំព្យាយាមយល់បទគម្ពីរដែរឬទេ? | | (1 2 3 4 5) | |
| 2. តើក្រុមជំនុំមានការប្រកបពិតប្រាកដដែរទេ? | | (1 2 3 4 5) | |
| 3. តើក្រុមជំនុំមានការអធិស្ឋានដោយខិតខំ ដែរទេ? | | (1 2 3 4 5) | |
| 4. តើក្រុមជំនុំធ្វើការដោយព្រះវិញ្ញាណបរិសុទ្ធ ដែរឬទេ? | | (1 2 3 4 5 ) | |
| 5. តើក្រុមជំនុំស្រឡាញ់អ្នកជិតខាងដែរទេ? | | (1 2 3 4 5 ) | |
| 6. តើក្រុមជំនុំប្រមូលផ្តុំគ្នាសរសើរដំកើងព្រះអម្ចាស់ដែរទេ? | | (1 2 3 4 5) | |
| 7. តើក្រុមជំនុំដេញតាមភាពបរិសុទ្ធនិងសេចក្តី សុខសាន្តដែរទេ? | | (1 2 3 4 5) | |
| 8. តើក្រុមជំនុំបានទទួលនូវព្រលឹងដែល បាត់បង់ដែរទេ? | | (1 2 3 4 5) | |
| 9. តើក្រុមជំនុំបង្ហាញភស្តុតាងនៃការ ថ្វាយបង្គំពិតដែរទេ? | | (1 2 3 4 5) | |
| 10. តើក្រុមជំនុំស្មោះត្រង់នៅក្នុងដំណែងរបស់ គេទេ? | | (1 2 3 4 5) | |

# សេចក្ដីបន្ថែមទី៣៖ ទម្រង់វាយតម្លៃលើខ្លឹមសារអធិប្បាយ

| | |
|---|---|
| I. ការអានបទគម្ពីរ | |
| A. តើខ្ញុំបានអានអត្ថបទដោយបញ្ជាក់ច្បាស់ៗទេ? | (1 2 3 4 5) |
| B. តើខ្ញុំបានអានអត្ថបទគម្ពីរច្បាស់ទេ? | (1 2 3 4 5) |
| II. សេចក្ដីផ្ដើម | (1 2 3 4 5) |
| A. តើខ្ញុំបានចាប់យកការយកចិត្តទុកដាក់របស់អ្នកដែរទេ? | (1 2 3 4 5) |
| B. តើការអធិប្បាយរបស់គាត់ត្រឹមត្រូវជាក់ច្បាស់ទេ? | (1 2 3 4 5) |
| C. តើអ្នកយល់ពីការចាំបាច់នៅក្នុងការអធិប្បាយដែរទេ? | (1 2 3 4 5) |
| D. តើសេចក្ដីណែនាំគួរឱ្យភ្ញាក់ផ្អើលទេ? | (1 2 3 4 5) |
| III. គ្រោង | (1 2 3 4 5) |
| A. តើចំណុចសំខាន់ច្បាស់ទេ? (ចូរសរសេរនៅខាងក្រោយ) | (1 2 3 4 5) |
| B. តើចំណុចសំខាន់មានលំហូរធម្មតាចេញពីអត្ថបទដែរទេ? | (1 2 3 4 5) |
| C. តើចំណុចតូចៗមានការអភិវឌ្ឍដែរទេ? | (1 2 3 4 5) |
| D. តើឧទាហរណ៍គាំទ្រចំណុចនីមួយៗទេ?(សង្ខេបនិងសរសេរ) | (1 2 3 4 5) |
| E. តើការអនុវត្តច្បាស់លាស់ទេ? (ចូរពន្យល់) | (1 2 3 4 5) |
| F. តើអ្នកបានរៀនការអ្វីថ្មីចេញពីគ្រោងនេះទេ? | (1 2 3 4 5) |
| G. តើគ្រោងមានដំណើរការរឿយៗទេ? | (1 2 3 4 5) |
| H. តើគ្រោងនេះមានចំណេះដឹងពីព្រះគ្រីស្ទទេ? | (1 2 3 4 5) |
| IV. សរុបសេចក្ដី | (1 2 3 4 5) |
| A. តើខ្ញុំបានសង្ខេបការអធិប្បាយទេ? | (1 2 3 4 5) |
| B. តើខ្ញុំបានបង្ហាញរូបភាពនៅក្នុងខ្លឹមសារដែរទេ? | (1 2 3 4 5) |

| | |
|---|---|
| C. តើការសរុបសេចក្តីបានសម្រេចដែរទេ? | (1 2 3 4 5) |
| D. តើវាបានជម្រុញអ្នកឱ្យមានការផ្លាស់ប្រែដែរទេ? | (1 2 3 4 5) |
| V. ការវាយតម្លៃទូទៅ | (1 2 3 4 5) |
| A. បែបបទនៃការអធិប្បាយ | (1 2 3 4 5) |
| 1. ពាក្យពេចន៍ដែលអាចយល់បាន | (1 2 3 4 5) |
| 2. ភាសាសម្បូណ៌បែប | (1 2 3 4 5) |
| 3. សម្លេងដែលឆ្លុះបញ្ចាំង កម្រិតសម្លេង និងភាពច្បាស់លាស់ | (1 2 3 4 5) |
| 4. កាយវិការនិងការបង្ហាញតាមទឹកមុខ | (1 2 3 4 5) |
| 5. ការប្រើភ្នែកទាក់ទងជាមួយអ្នកស្តាប់ | (1 2 3 4 5) |
| 6. អ្នកអធិប្បាយមានការទាក់ទាញចំណាប់អារម្មណ៍ | (1 2 3 4 5) |
| 7. ប្រវែងនៃការអធិប្បាយ | (1 2 3 4 5) |
| 8. អារម្មណ៍នៃការជម្រុញនៃការអធិប្បាយ | (1 2 3 4 5) |
| 9. អារម្មណ៍នៃការរួបរួមនៅក្នុងការអធិប្បាយ | (1 2 3 4 5) |
| B. ប្រសិទ្ធិភាព | (1 2 3 4 5) |
| 1. អ្នកនិយាយនិយាយដោយទំនុកចិត្តនិងការទាក់ទាញ | (1 2 3 4 5) |
| 2. អ្នកមានការប៉ះពាល់ហើយមានការទាក់ទាញដោយសារការអធិប្បាយ | (1 2 3 4 5) |
| 3. បទគម្ពីរត្រូវបានបង្រៀនដោយយកចិត្តទុកដាក់និងដាក់អនុវត្ត | (1 2 3 4 5) |
| 4. ចំណងជើងនៃការអធិប្បាយសមស្របទៅនឹងគោលការណ៍នៃការអធិប្បាយ | (1 2 3 4 5) |

❖ ការនេះពឹងផ្អែកលើការវាយតម្លៃខ្លឹមសារអធិប្បាយដែលប្រើនៅក្នុងកម្មវីធីសិក្សាថ្នាក់បណ្ឌិតនៅសាលា Westminster Theological Seminary នៅរដ្ឋកាលីហ្វ័រញ៉ានៅឆ្នាំ ១៩៩៦។

# សេចក្តីបន្ថែមទី៤៖ សំណួរសម្រាប់ការបកប្រែនូវអត្ថបទគម្ពីរសម្រាប់ការអធិប្បាយ

| អត្ថបទ: | កាលបរិច្ឆេទ: | អ្នកបកប្រែ: |
|---|---|---|
| សំណួរសម្រាប់ការបកស្រាយ | ចម្លើយ | សេចក្តីពិតដែលរកឃើញ |
| 1. តើអ្វីដែលប្រឆាំងនឹងអត្ថន័យនៃខគម្ពីរនេះ? | | |
| 2. តើចំណុចណាដែលត្រូវបានសង្កត់ធ្ងន់នៅក្នុងន័យនេះ? | | |
| 3. តើអត្ថន័យដូចគ្នានេះចេញមកពីខគម្ពីរណា? | | |
| 4. តើអ្វីទៅជាខ្លឹមសារនៃខគម្ពីរនេះ? (ជាភាសា) | | |
| 5. តើអ្វីជាគោលបំណងនៅក្នុងខគម្ពីរនេះ? (ជាភាសា) | | |
| 6. តើអ្វីជាតួនាទីនៃខគម្ពីរនេះ? (ជាភាសា) | | |
| 7. តើខគម្ពីរនេះមានកំណត់ត្រាប្រវត្តិសាស្រ្តដែរទេ? (ចំណងជើង) | | |
| 8. តើខគម្ពីរនេះមាននិមិត្តរូបនិងប្រភេទដែរទេ? (សួររកធាតុ) | | |

| | | |
|---|---|---|
| 9. តើអ្វីទៅជាបរិបទនៃខគម្ពីរនេះ? | | |
| 10. តើអ្វីជា locutionary ដែលខគម្ពីរនេះប្រើ? | | |
| 11. តើខគម្ពីរនេះត្រូវបានសរសេរនៅក្នុងភាសាអ្វី? | | |
| 12. តើខគម្ពីរនេះមានធាតុពីអារម្មណ៍ដែរទេ? | | |
| 13. តើខគម្ពីរមានធាតុដែលផ្តល់ព័ត៌មានទាក់ទងនឹងការអធិប្បាយដែរទេ? | | |
| 14. តើនរណាជាអ្នកដែលទទួលដើមនៃខគម្ពីរនេះ? | | |
| 15. តើអ្វីទៅជាវប្បធម៌ដែលជាជីវប្រវត្តិនៃខគម្ពីរនេះ? | | |
| 16. តើអ្វីទៅជាលំដាប់លំដោយនៅក្នុងប្រវត្តិសាស្ត្រនៃសេចក្តីប្រោសលោះនៃខគម្ពីរនេះ? | | |
| 17. តើអ្វីទៅជាលំដាប់លំដោយនៅក្នុងទំនាក់ទំនងទៅកាន់ជិវិតបច្ចុប្បន្ន? | | |

អ្នកនិពន្ធ បណ្ឌិត វ៉ាយ យ៉ុង ជុន ជាប្រធាននៃ *CEMF* និង *CRFI*

- Biblical Theology (O.T), Expository Preaching and Puritanism
- D. Min., Westminster Theological Seminary, CA, USA (1996)
- M.Div., Hapdong Presbyterian Theological Seminary, South Korea (1981)
- B.A., Chong Shin Theological Seminary, South Korea (1978)
- Taught in International Theological College and Seminary in Cambodia (Chairman of Old Testament)
- Taught in International Reformed Theological College & Seminary, USA ( Preaching Professor)

-----------------------------------------------------------

កាលបរិច្ឆេទបោះពុម្ភ៖ កុម្ភៈ ១៦ ២០២០ នៅកម្ពុជា
ទីបោះពុម្ភ៖ វិទ្យាស្ថានសេចក្ដីជំនឿបែបកំណែទម្រង់នៅកម្ពុជា
អ្នកកែសម្រួល៖ លោក John Park នៅសហរដ្ឋអាមេរិក
Translator: Ms. Sreyleak Kohn, CEMF staff